លេខ៤ បោះពុម្ពចំនួន ២ ០០០ ច្បាប់
បោះពុម្ពនៅរោងពុម្ព ជោគជ័យ
ផ្ទះលេខ៧៤៩  មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្រាបែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# ព្រឹត្តិបត្រ
# ក្រុមប្រឹក្សាជាតិភាសាខ្មែរ

## BULLETIN DU CONSEIL NATIONAL DE LA LANGUE KHMERE
## BULLETIN OF THE NATIONAL COUNCIL OF KHMER LANGUAGE

លេខ ៤ ឆ្នាំ២០១២ Vol. 4, 2012

អាសយដ្ឋាន: មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរសព្ទដៃ : (៨៥៥) ១២ ៩១១ ៣៨៧, (៨៥៥) ១២ ៩០៦ ៨៥៥ អ៊ីមែល : nckl.nckl@yahoo.com គេហទំព័រ : www.nckl.gov.kh

# មាតិកា

**ចំណងជើង** **ទំព័រ**


• គណៈគ្រប់គ្រងនិងក្រុមការងារ........................................................................................................ i
• បុព្វកថា........................................................................................................................................iii
• អារម្ភកថា......................................................................................................................................v
• របាយការណ៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្នុងពិធីបើកសម័យប្រជុំលើកទី១ របស់ ក.ជ.ភ.ខ. ថ្ងៃពុធ ទី១៤ ខែមីនា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី........................................................១
• សុន្ទរកថារបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធានកិត្តិយសនិងអាណាព្យាបាលក្រុមប្រឹក្សាជាតិភាសាខ្មែរ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកសម័យប្រជុំលើកទី១ របស់ ក.ជ.ភ.ខ. ថ្ងៃពុធ ទី១៤ ខែមីនា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី ........................................................................៧
• ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ....១១
• ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាព ក្រុមប្រឹក្សាជាតិភាសាខ្មែរ ការតែងតាំងឧត្តមទីប្រឹក្សា និង ទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ..............................១៥
• អនុក្រឹត្យលេខ : ១៣៨.អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ.........................................................................................២០
• បច្ចេកសព្ទរបស់គណៈកម្មការវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ដែល គ.ជ.ភ.ខ. បានអនុម័ត ....................................២៦
• បច្ចេកសព្ទរបស់គណៈកម្មការជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម ដែល គ.ជ.ភ.ខ. បានអនុម័ត..............................៣៣
• បច្ចេកសព្ទរបស់គណៈកម្មការវប្បធម៌ និង វិចិត្រសិល្បៈ ដែល គ.ជ.ភ.ខ. បានអនុម័ត...........................................៤០
• បច្ចេកសព្ទនៃគណៈកម្មការភាសាវិទ្យា និង អក្សរសិល្ប៍ ដែល គ.ជ.ភ.ខ. បានអនុម័ត ........................................៥១
  - បច្ចេកសព្ទភាសាវិទ្យា.................................................................................................................៥១
  - បច្ចេកសព្ទអក្សរសិល្ប៍.................................................................................................................៦៣
• បច្ចេកសព្ទស្នើពីមជ្ឈដ្ឋានខាងក្រៅ ...........................................................................................................៨៤
  - បច្ចេកសព្ទស្នើដោយលោកបណ្ឌិត សន ពៅ.....................................................................................៨៤
  - បច្ចេកសព្ទស្នើដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា...........................................................៨៥
  - បច្ចេកសព្ទស្នើដោយលោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា...........................៨៥
  - បច្ចេកសព្ទស្នើដោយឯកឧត្តម ង៉ែត បូរី នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន..........៨៦
  - បច្ចេកសព្ទស្នើដោយឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ អនុប្រធានគណៈកម្មការភាសាវិទ្យាខ្មែរអមទីស្តីការគណៈរដ្ឋមន្ត្រី....៨៨

• លិខិតឆ្លើយឆ្លងមួយចំនួនរវាង គ.ជ.ភ.ខ. និង សាធារណជន ....................................................................................៩១
- លិខិតរបស់អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ភ.ខ. ជូនលោក ហ៊ា ធារិត មន្ត្រីសាលាខេត្តបន្ទាយមានជ័យ...................៩៣
- លិខិតលេខ : ០០១/១១.គជភខ/បព ចុះថ្ងៃចន្ទ ទី១០ ខែមករា ឆ្នាំ២០១១ របស់អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ភ.ខ. ឆ្លើយតបទៅលោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា......................៩៤
- លិខិតលេខ : ៤១៨/១១ របសក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១១ របស់លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជាគោរពជូនឯកឧត្តមបណ្ឌិតសភាចារ្យ ពុំ ម៉ល់ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ.......៩៦
- លិខិតលេខ : ០៨៩/១១.កជភខ/រ ចុះថ្ងៃព្រហស្បតិ៍ ទី៨ ខែកញ្ញា ឆ្នាំ២០១១ របស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរឆ្លើយតបទៅលោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា................ ......៩៧
- លិខិតលេខ : ០១២/១១.គជភខ/រ ចុះថ្ងៃព្រហស្បតិ៍ ទី៣ ខែមករា ឆ្នាំ២០១១ របស់អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ភខ. ឆ្លើយតបទៅលោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា................. .....៩៨
- លិខិតឆ្លើយតបទៅលោក ខេង ទីតូ មន្ត្រីកងរាជអាវុធហត្ថលើផ្ទៃប្រទេស............................................. ...៩៩

# គណៈគ្រប់គ្រង

- គរុគណ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ប្រធានកិត្តិយស................ : ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាប្រធានកិត្តិយសនិងអាណាព្យាបាល ក.ជ.ភ.ខ.
- ប្រធាន .............................. : ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**
- អនុប្រធាន ......................... : លោកជំទាវបណ្ឌិតសភាចារ្យ **ខួត ធីតា**, ឯកឧត្តមបណ្ឌិតសភាចារ្យ **តិច សំណាង**, ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន**, ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ**, ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ីវ ច័ន**, ឯកឧត្តម **ឈន អៀម**, ឯកឧត្តម **សូ មុយឃៀង**
- អគ្គលេខាធិការ ................. : ឯកឧត្តមបណ្ឌិត **សន ពៅ**
- អគ្គលេខាធិការរង ............ : ឯកឧត្តម **ប៊ុត សុម៉េត**, ឯកឧត្តមបណ្ឌិត **ស៊ុំ ឈុំឡុង**, ឯកឧត្តមបណ្ឌិត **ជួរ គារី**

# ក្រុមការងារ

## ១- ក្រុមអ្នកផ្ទៀងផ្ទាត់

- ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** អនុប្រធាន ក.ជ.ភ.ខ.
- ឯកឧត្តមបណ្ឌិត **ជួរ គារី** អគ្គលេខាធិការរង ក.ជ.ភ.ខ. ទទួលបន្ទុកផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- លោក **សេ អឿន** ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល

## ២- ក្រុមអ្នកចាត់ការទូទៅ

- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក.ជ.ភ.ខ.
- អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន ក.ជ.ភ.ខ.
- មន្ត្រីជំនួយការនៃអគ្គលេខាធិការដ្ឋាន ក.ជ.ភ.ខ.

## ៣- ក្រុមអ្នករៀបចំ

- ឯកឧត្តមបណ្ឌិត **ជួរ គារី** អគ្គលេខាធិការរង ក.ជ.ភ.ខ. ទទួលបន្ទុកផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- លោក **សេ អឿន** ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- ឯកឧត្តម **លី សុធីរ័ត្ន** មន្ត្រីជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- លោកបណ្ឌិត **ជូ ច័ន្ទដារី** មន្ត្រីជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- លោកស្រី **តិប ស៊ីណា** មន្ត្រីជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- លោក **ឡុង សុរិទ្ធ** មន្ត្រីជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- លោក **ហួត រ៉ា** មន្ត្រីជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- លោក **សេក ចំរើន** មន្ត្រីជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
- លោកស្រីបណ្ឌិត **ហ៊ាន សុទ្ធនា** មន្ត្រីជំនួយការផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល

# បុព្វកថា

ដូចព្រឹត្តិបត្រលេខមុនៗដែរ ព្រឹត្តិបត្រលេខ៤នេះ ចុះផ្សាយបច្ចេកសព្ទស្នើចេញពីគណៈកម្មការបច្ចេកសព្ទនៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ដែលបានក្លាយទៅជាក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១។ ប៉ុន្តែ ក្រៅពីបច្ចេកសព្ទស្នើចេញពីគណៈកម្មការបច្ចេកសព្ទរបស់ខ្លួន ក.ជ.ភ.ខ.ក៏ចុះផ្សាយពាក្យមួយចំនួនស្នើមកពីមជ្ឈដ្ឋានខាងក្រៅផងដែរ។ ចំណុចសំខាន់គឺ បច្ចេកសព្ទទាំងនេះទប់ស្កាត់កុំឱ្យសាធារណជនបង្កើតពាក្យទៅតាមចំណូលចិត្តរបស់ខ្លួន ដែលជានិន្នាការផ្ទុយពីការស្វែងរកឯកភាពជូនភាសាជាតិ។

ដោយ គ.ជ.ភ.ខ./ក.ជ.ភ.ខ. មានគណៈកម្មការបច្ចេកសព្ទជាច្រើន អង្គភាព/ស្ថាប័ននេះមិនអាចអនុម័តបច្ចេកសព្ទជាច្រើនរយពាក្យសម្រាប់មុខវិជ្ជានីមួយៗក្នុងមួយលើកៗបានទេ។ ប៉ុន្តែ ជាបន្តបន្ទាប់ក.ជ.ភ.ខ.ត្រូវអនុម័តបច្ចេកសព្ទឱ្យបានកាន់តែច្រើនរយពាក្យសម្រាប់មុខវិជ្ជានីមួយៗ ហើយ នៅពេលនោះ ក.ជ.ភ.ខ.ត្រូវចងក្រងពាក្យទាំងនោះជាសទ្ទានុក្រម ដើម្បីផ្សព្វផ្សាយឱ្យសាធារណជនប្រើប្រាស់។ សទ្ទានុក្រមអាចដាក់លក់តាមបណ្ណាគារ ហើយ ការផ្សាយនឹងអាចធ្វើបានដោយទូលំទូលាយជាងតាមព្រឹត្តិបត្រ។

ចំពោះអក្ខរាវិរុទ្ធដែលនៅមិនទាន់ឯកភាពគ្នាខ្លះៗនៅឡើយ ក.ជ.ភ.ខ.ត្រូវតែបន្តសកម្មភាពរបស់ខ្លួន តាមរយៈការរៀបចំសិក្ខាសាលាសម្រាប់ពិធីករនិងគ្រូបង្រៀន ជាដើម និង តាមការបោះពុម្ពកូនសៀវភៅតូចៗ ចែកជូនគ្រប់មជ្ឈដ្ឋាន ជាពិសេសជូនទៅ ទូរទស្សន៍ វិទ្យុ និង សារព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០១២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ប្រធានកិត្តិយស និង អាណាព្យាបាល នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ**



បណ្ឌិតសភាចារ្យ **សុខ អាន**

# អារម្ភកថា

អ្វីៗដែលឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានកិត្តិយសនិងអាណាព្យាបាលនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បានចង្អុលបង្ហាញនោះ យើងនឹងខំអនុវត្តឱ្យបានជាអតិបរមា។

ជាពិសេស យើងនឹងរៀបយ៉ាងណាឱ្យប្រមូលសព្ទអនុម័តទៅពេលមុននិងនៅឆ្នាំ២០១២ នៃមុខវិជ្ជាមួយចំនួនកើនបានដល់បួនឬប្រាំរយពាក្យ ដើម្បីអាចបោះចេញជាសទ្ទានុក្រម ខ្នាត ២១ស.ម.x១៥ស.ម. (ខ្នាតរបស់សទ្ទានុក្រមនៃគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់) ក្រោសពីមួយរយទៅមួយរយហាសិបទំព័រ។ យើងសង្ឃឹមថា តាមរយៈសទ្ទានុក្រម យើងអាចផ្សព្វផ្សាយបានទូលំទូលាយជាងតាមព្រឹត្តិបត្រ។

ចំពោះបញ្ហាចម្រូងចម្រាស យើងក៏សង្ឃឹមថា យើងនឹងអាចដោះស្រាយបណ្ដើរៗ ដោយប្រើលទ្ធផលនៃការស្រាវជ្រាវផង និង ដោយធ្វើសម្បទានទៅវិញទៅមកផង ពីព្រោះលទ្ធផលនៃការស្រាវជ្រាវតែងតែទទួលឥទ្ធិពលពីនិន្នាការរបស់អ្នកស្រាវជ្រាវ ដែលនាំឱ្យលទ្ធផលនៃការស្រាវជ្រាវលើចំណុចចម្រូងចម្រាសណាមួយក្នុងភាសា មានបម្រែបម្រួលខ្លះៗរវាងអ្នកស្រាវជ្រាវ។ អាស្រ័យហេតុនេះ លទ្ធផលនៃការស្រាវជ្រាវត្រូវចាត់ទុកជាទុនសម្រាប់ពិគ្រោះ ពិចារណា ប្ដូរយោបល់គ្នា គឺមិនត្រូវយកទៅផ្សព្វផ្សាយឱ្យហួសពីរង្វង់អ្នកស្រាវ-ជ្រាវឡើយ។

ក្រៅពីការស្វែងរកឯកភាពជូនភាសា ក្រុមប្រឹក្សាជាតិភាសាខ្មែរក៏ត្រូវឆ្លើយនឹងសំណួររបស់សាធារណជនផងទៀត កាលណាលោកមានចម្ងល់ឬត្រូវការប្ដូរយោបល់ជាមួយយើង។

រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ទី២៦ ខែមករា ឆ្នាំ២០១២

ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

បណ្ឌិតសភាចារ្យ ឃុំ ទិត

# សុន្ទរកថា

**ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់**
**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)**

ក្នុងពិធីបើកសម័យប្រជុំលើកទី១ របស់ ក.ជ.ភ.ខ.

ថ្ងៃពុធ ទី១៤ ខែមីនា ឆ្នាំ២០១២ នៅទីស្ដីការគណៈរដ្ឋមន្ត្រី បន្ទប់ A, C និង D

---

ខ្ញុំព្រះករុណាខ្ញុំ ខ្ញុំបាទ ខ្ញុំ

- សូមក្រាបថ្វាយបង្គំ ព្រះមុនីកោសល **ហ៊ុល សុវណ្ណ** រាជាគណៈថ្នាក់ទោ អនុគណខណ្ឌឫស្សីកែវ សមាជិកថេរសភាសង្ឃ ចៅអធិការវត្តទួលសុវណ្ណារាម និងជាឧត្តមទីប្រឹក្សានៃក.ជ.ភ.ខ. ជាទីសក្ការៈ,
- សូមក្រាបថ្វាយបង្គំ ព្រះតេជគុណ **យស ហ៊ុត** ខេមចារោ ប្រធានស្ដីទីសមាគមធម្មទូត និង ជាប្រធានមូលនិធិពុទ្ធសាសនាខ្មែរ-វត្តឋម្មរ៉ៀ ជាសមាជិកនៃ ក.ជ.ភ.ខ. ជាទីសក្ការៈ
- សូមក្រាបថ្វាយបង្គំ ព្រះតេជគុណគ្រប់ព្រះអង្គ ជាទីសក្ការៈ,
- សូមគោរព ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានកិត្តិយសនិងអាណាព្យាបាលនៃ ក.ជ.ភ.ខ. តំណាងដ៏ខ្ពង់ខ្ពស់សម្ដេចបណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាគុរុគណនៃ ក.ជ.ភ.ខ. ជាទីគោរព,
- សូមគោរព ឯកឧត្តមបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ជាឧត្តមទីប្រឹក្សានៃ ក.ជ.ភ.ខ. ជាទីគោរព,
- សូមគោរព ឯកឧត្តម លោកជំទាវ សមាជិករាជរដ្ឋាភិបាល ជាទីគោរព,
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ នាងកញ្ញា ដែលជាភ្ញៀវកិត្តិយស ជាទីគោរព,
- សូមគោរព លោកជំទាវបណ្ឌិតសភាចារ្យ ឯកឧត្តមបណ្ឌិតសភាចារ្យ ឯកឧត្តមបណ្ឌិត ឯកឧត្តម អនុប្រធាននៃ ក.ជ.ភ.ខ. ជាទីគោរព,
- សូមគោរព ឯកឧត្តមបណ្ឌិតសភាចារ្យ ឯកឧត្តមបណ្ឌិត ឯកឧត្តម ទីប្រឹក្សានៃ ក.ជ.ភ.ខ. ជាទីគោរព,
- សូមគោរព ឯកឧត្តមបណ្ឌិតសភាចារ្យ ឯកឧត្តមបណ្ឌិត ឯកឧត្តម លោក/លោកស្រីបណ្ឌិត លោក លោកស្រី សមាជិកនៃ ក.ជ.ភ.ខ. ជាទីគោរព,

- សូមគោរព ឯកឧត្តមបណ្ឌិតសភាចារ្យ ឯកឧត្តមបណ្ឌិត ឯកឧត្តម លោក/លោកស្រីបណ្ឌិត លោក លោកស្រី ប្រធាន អនុប្រធាន សមាជិក នៃគណៈកម្មការបច្ចេកទេសនៃ ក.ជ.ភ.ខ. ជាទីគោរព,
- សូមគោរព ឯកឧត្តមអគ្គលេខាធិការ ឯកឧត្តមអគ្គលេខាធិការរង មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ជាទីគោរពរាប់អាន។

**អង្គពិធីទាំងមូល ជាទីសក្ការនិងជាទីគោរព,**

ថ្ងៃនេះ ជាថ្ងៃដ៏វិសេសក្រៃលែង ចំពោះ ក.ជ.ភ.ខ. ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានកិត្តិយសនិងអាណាព្យាបាលនៃ ក.ជ.ភ.ខ. តំណាងដ៏ខ្ពង់ខ្ពស់សម្តេចបណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាគុរុគណនៃ ក.ជ.ភ.ខ. អញ្ជើញជាអធិបតីក្នុងឱកាសបើកសម័យប្រជុំពេញអង្គលើកទី១ នៃ ក.ជ.ភ.ខ.នេះ។

ក្នុងនាម ក.ជ.ភ.ខ. ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ សូមគោរពធ្វើរបាយការណ៍ជូន ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី និង អង្គប្រជុំទាំងមូល មេត្តាជ្រាបថា ដំបូងឡើយ *ក្រុមប្រឹក្សាជាតិ ភាសាខ្មែរ* (ក.ជ.ភ.ខ.) មានឈ្មោះថា *គណៈកម្មាធិការជាតិភាសាខ្មែរ* (គ.ជ.ភ.ខ.)។ គ.ជ.ភ.ខ.បានបំពេញភារកិច្ចរបស់ខ្លួនតាំងពីចុងឆ្នាំ២០០៧ រហូតមកដល់ចុងឆ្នាំ២០១១ ហើយ បានអនុម័តយកគោលការណ៍មួយចំនួនដើម្បីប្រើជាខ្នាតក្នុងកិច្ចការរបស់ខ្លួន និង បានអនុម័តពាក្យដែលស្នើ ដោយគណៈកម្មការបច្ចេកទេស ដោយមជ្ឈដ្ឋានផ្សេងៗ និង ដោយស្ថាប័នជាតិមួយចំនួន។ ភារកិច្ច និង សេចក្តីសម្រេចទាំងនោះ មានដូចខាងក្រោម៖

**១- គ.ជ.ភ.ខ. សម្រេចនូវគោលការណ៍ធំៗ មួយចំនួនដើម្បីកែការឯកភាព ជូនភាសាជាតិយើង .**

១.១- ថ្ងៃពុធ ទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ គ.ជ.ភ.ខ.បានអនុម័តយកវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** បោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ជាមូលដ្ឋាន។

១.២- ថ្ងៃពុធ ទី២១ ខែឧសភា ឆ្នាំ២០០៨ គ.ជ.ភ.ខ.បានអនុម័តធាតុ /-កម្ម/, /-នីយកម្ម/, /-ឧបនីយកម្ម/ សម្រាប់ឲ្យប្រើក្នុងការបង្កើតពាក្យ : "ភាវូបនីយកម្ម" មិនមែនជាបច្ច័យបទទេ ប៉ុន្តែ ជាសមាសភាគកើតចេញពី "ភាព" (ព្យាង្គខាងចុងនៃពាក្យមួយចំនួន ដូចពាក្យ "**ឯកភាព/សន្តិភាព**" ជាដើម) + (បូកនឹង) "ឧបនីយកម្ម", ឧ. "សេរីភាព + ឧបនីយកម្ម > សេរីភាវូបនីយកម្ម" ប៉ុន្តែ "ឯកជន + ឧបនីយកម្ម > ឯកជនូបនីយកម្ម" គឺមិនអាចទៅជា "ឯកជនភាវូបនីយកម្ម" បានទេ។

១.៣- ថ្ងៃពុធ ទី២៨ ខែឧសភា ឆ្នាំ២០០៨ គ.ជ.ភ.ខ.បានអនុម័តបញ្ហាទាក់ទងនឹងការសរសេរ

អក្សរខ្មែរមួយចំនួនដែលកត់សូរបរទេស តាមរយៈពាក្យកម្ចី ដូចជា :

- [g] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្គ"
- [f] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្វ / ហ៊្វ"
- [ʃ] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្ស / ហ៊្ស"
- [ʒ] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ស្ហ / ស៊្ហ"
- [s] / [z] ដែលយើងត្រូវប្រើព្យញ្ជនៈ "ស / ស៊"។

១.៤- ពីថ្ងៃពុធ ទី១៥ ខែមករា ទៅថ្ងៃពុធ ទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩ គ.ជ.ភ.ខបានអនុម័តពាក្យសម្គាល់ឈ្មោះប្រទេស និង រាជធានី/រដ្ឋធានី ស្នើដោយគណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ ដែលភាគច្រើនជាពាក្យកម្ចី សរុបទាំងអស់ចំនួន ១៩៥ពាក្យ។

១.៥- ពីថ្ងៃពុធ ទី០១ ខែមេសា ទៅថ្ងៃពុធ ទី២៧ ខែឧសភា ឆ្នាំ២០០៩ គ.ជ.ភ.ខ.បានអនុម័តគោលការណ៍បង្កើតពាក្យនិងគោលការណ៍កម្ចីពាក្យ ស្នើដោយគណៈកម្មការបង្កើតពាក្យនិងកម្ចីពាក្យ។

**២- ការធ្វើសិក្ខាសាលា ការអនុម័តបទបញ្ជាផ្ទៃក្នុង និង ការអនុម័តពាក្យដែលស្នើ ដោយគណៈកម្មការបច្ចេកទេស ដោយសាធារណជន និង ដោយអង្គភាពនិងស្ថាប័ននានា :**

២.១- ថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ២០០៧ គ.ជ.ភ.ខ.បានធ្វើសិក្ខាសាលាមួយ ដើម្បីប្រមូលគំនិតសម្រាប់រៀបចំទម្រង់និងរចនាសម្ព័ន្ធរបស់ខ្លួន។

២.២- ថ្ងៃអង្គារ ទី១៨ ខែកញ្ញា ឆ្នាំ២០០៧ គ.ជ.ភ.ខ.បានបើកសម័យប្រជុំពេញអង្គ លើកទី១ ជាឱឡារិក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធាននៃ គ.ជ.ភ.ខ.។

២.៣- ថ្ងៃពុធ ទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ គ.ជ.ភ.ខ.បានអនុម័តសម្រេចបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

២.៤- ថ្ងៃពុធ ទី០៥ ខែធ្នូ ឆ្នាំ២០០៧ គ.ជ.ភ.ខ.បានធ្វើសិក្ខាសាលាមួយ ដើម្បីប្រមូលគំនិតសម្រាប់រៀបចំដំណើរការគណៈកម្មការបច្ចេកទេសរបស់ខ្លួន។

២.៥- នៅខែធ្នូ ឆ្នាំ២០០៧ គណៈកម្មការអាដហុកមួយបានបង្កើតឡើង ដើម្បីពិនិត្យសៀវភៅវេយ្យាករណ៍របស់សាស្ត្រាចារ្យ **ឃីង សុខ**។

២.៦- ថ្ងៃពុធ ទី០៥ ខែមីនា ឆ្នាំ២០០៨ គ.ជ.ភ.ខ.បានបង្កើតអង់តែនមួយ សម្រាប់ឲ្យមហាជនដែលគ្មានវចនានុក្រមប្រើ ដើម្បីឱ្យគេសួរនាំអំពីអក្ខរាវិរុទ្ធ និង និយមន័យនៃពាក្យដែលគេមិនចេះ។

២.៧- នៅខែមីនា ឆ្នាំ២០១១ គណៈកម្មការអាដហុកមួយ ទៀតត្រូវបានបង្កើតឡើង ដើម្បីពិនិត្យ

សៀវភៅវចនានុក្រមព្រះពុទ្ធសាសនារបស់លោកបណ្ឌិត **ចឺ ឡើ** តែដោយសៀវភៅវចនានុក្រមនោះ មានជាងមួយពាន់ទំព័រ ហើយ ត្រូវការពេលវេលាច្រើនឆ្នាំ ទើបប្រធានគណៈកម្មការអាជ៌ហុកបានស្នើសុំឈប់ពិនិត្យតទៅទៀត។

២.៨- ដោះស្រាយបញ្ហាផ្សេងៗ ដូចជា ពន្យល់ពាក្យ ប្រែពាក្យ បង្កើតពាក្យ សោរមងារ ជាដើម ជូនស្ថាប័ន ឥស្សរជន និង សាធារណជនពីមូលដ្ឋានផ្សេងៗ។

៣- ការផ្សព្វផ្សាយ

៣.១- គ.ជ.ភ.ខ.បានបោះពុម្ពព្រឹត្តិបត្រចំនួន៣លេខ។ ព្រឹត្តិបត្រទាំងនោះ ត្រូវបានប្រគេនថ្វាយសម្ដេចព្រះសង្ឃរាជនិងថ្នាក់ដឹកនាំគណៈទាំងពីរគណៈ និង ចែកជូន ក្រសួងព្រះបរមរាជវាំង, ព្រឹទ្ធសភា, រដ្ឋសភា, ក្រសួងនានា, ស្ថាប័នក្រោមឱវាទទីស្ដីការគណៈរដ្ឋមន្ត្រី, សាលាខេត្ត, មន្ទីរអប់រំខេត្ត/ក្រុង, ការិយាល័យអប់រំស្រុក/ខណ្ឌ, គ្រឹះស្ថានសិក្សានៅរាជធានីភ្នំពេញ ជាដើម។

៣.២- ថ្ងៃពុធ ទី១៥ ខែកញ្ញា ឆ្នាំ២០១០ គ.ជ.ភ.ខ.បានអញ្ជើញ ទូរទស្សន៍ វិទ្យុ សារព័ត៌មានទាំងអស់នៅប្រទេសខ្មែរ (ភាគច្រើនលើសលប់បានចូលរួម) ឲ្យមកទទួលព័ត៌មានទាក់ទងនឹងរបៀបធ្វើការនិងលទ្ធផលរបស់ខ្លួន ព្រមទាំងបានសុំឲ្យគេជួយផ្សព្វផ្សាយលទ្ធផលសំខាន់ៗមួយចំនួន ប៉ុន្តែ បណ្ដាញសារព័ត៌មានទាំងនោះគ្រាន់តែបាននិយាយពីព្រឹត្តិការនៃជំនួបនោះតែប៉ុណ្ណោះ។

៣.៣- ពីរបីខែក្រោយមក ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ បានសុំឱ្យកាសែតទាំងប៉ុន្មានជួយផ្សាយពាក្យដែលសរសេរជាមួយ "*ឞ*" (មិនសរសេរជាមួយ "*ន*") និង ពាក្យដែលសរសេរជាមួយ "*ឮ*" ឬ ជាព្យាង្គតម្រួត (មិនសរសេរជាមួយ "*ល*") : គឺមិនសរសេរតាមវិធីទំនាញសូរ ប៉ុន្តែ មានតែកាសែតចំនួនបួនទេដែលបានព្រមយកអាសា គឺ AKP, កោះសន្តិភាព, កម្ពុជាថ្មី និង រស្មីកម្ពុជា។ អ្វីដែលគួរកត់សម្គាល់ គឺកាសែតណាដែលធ្លាប់សរសេរតាមវិធីទំនាញសូរបានកាត់បន្ថយទម្លាប់របស់គេបានខ្លះ ប៉ុន្តែ ទម្លាប់នេះមិនអាចបំបាត់បានទាំងស្រុងនៅឡើយទេ (ទម្លាប់ជាធម្មជាតិទី២ របស់មនុស្ស)។

៤- គម្រោងនៅថ្ងៃមុខ

៤.១- បន្តបោះពុម្ពព្រឹត្តិបត្ររបស់ ក.ជ.ភ.ខ.ឲ្យបានច្រើនលេខ និង ក្នុងមួយលេខៗឱ្យបានច្រើនពាន់ច្បាប់ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយ;

៤.២- ជំរុញគណៈកម្មការបច្ចេកសព្ទណាដែលពាក្យអនុម័តរួចហើយមានចំនួនច្រើនគ្រាប់ ឲ្យស្នើពាក្យឲ្យច្រើននៅឆ្នាំ២០១២ ដើម្បីឲ្យពាក្យអនុម័តរួចកើនដល់បួនប្រាំរយពាក្យ និង

ដើម្បីអាចយកទៅបោះចេញជាសទ្ទានុក្រម;

៤.៣- បោះពុម្ពសៀវភៅស្តើងៗ (អក្ខរាវិរុទ្ធដែលទាក់ទងនឹងការប្រើព្យញ្ជនៈ ណ/ន និង ឡ/ល) ចែកតាម គ្រឹះស្ថានសិក្សា សាលាខេត្ត សាលាក្រុង សាលាស្រុក/ខណ្ឌ សាលាឃុំ/សង្កាត់ និង បណ្តាញសារព័ត៌មាន ជាដើម;

៤.៤- ធ្វើសិក្ខាសាលាសម្រាប់ពិធីករ នៃបណ្តាញវិទ្យុ ទូរទស្សន៍ និង សារព័ត៌មាននានា;

៤.៥- បន្តដោះស្រាយបញ្ហាពង្រួងចម្រាស ដើម្បីរកការឯកភាពជូនភាសាជាតិ។

**៥- ផលលំបាក(បញ្ហាប្រឈម)**

កន្លងមក គ.ជ.ភ.ខ.មានតែថវិកាសម្រាប់ឧបត្ថម្ភសមាជិកខ្លួន ឥតមានថវិកាសម្រាប់សម្ភារៈនិងការបោះពុម្ពទេ(ប៉ុន្តែ ចាប់ពីឆ្នាំ២០១២ ក.ជ.ភ.ខ.ដែលជំនួស គ.ជ.ភ.ខ. មានថវិកាធម្មតា ដូចស្ថាប័នផ្សេងៗដែរ)។

**៦- ទឹកប្រាក់សប្បុរសជន**

សប្បុរសជនមួយចំនួនបានជួយឧបត្ថម្ភថវិកាឬសម្ភារៈ ដល់គ.ជ.ភ.ខ./ក.ជ.ភ.ខ. មានដូចខាងក្រោម៖

៦.១- ឯឧត្តមបណ្ឌិតសភាចារ្យ សុខ អាន........................................៥.០០០$,

៦.២- ព្រះតេជគុណ យស ហ៊ុត ផ្តល់វចនានុក្រមធំៗដល់ ក.ជ.ភ.ខ
ចំនួន១៣ក្បាល ដែលមានតម្លៃ........................................៧៦៩$,

៦.៣- ព្រះគ្រូ ប៊ុត សាវង្ស បានផ្តល់ឱ្យ គ.ជ.ភ.ខ.នូវប្រាក់ឧបត្ថម្ភទទួលបាន
ក្នុងក្របខណ្ឌនៃកិច្ចការរបស់គាត់ក្នុងគ.ជ.ភ.ខ. ជារៀងរហូតមក... ២៣.៤២០.០០០៛,

៦.៤- ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ុល........................................៨.១២២$,

៦.៥- ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប........................................១៣.៩៦០.០០០៛,

៦.៦- លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា........................................១៣.២៣០.០០០៛,

៦.៧- ឯកឧត្តមបណ្ឌិតសភាចារ្យ គិច សំណាង........................................៣.០០០$,

៦.៨- ឯកឧត្តមបណ្ឌិត ម៉ៅ សុផាន់........................................២.០០០$,

៦.៩- ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន........................................២.០០០$,

៦.១០- ឯកឧត្តមបណ្ឌិត ឆ បុណ្ណារី........................................២.០០០$,

៦.១១- លោក មាស តាំ........................................៣.៣២៥.០០០៛,

៦.១២- លោក Doug Cooper........................................៧៥០$,

៦.១៣- លោកបណ្ឌិត ហួរ សុមេធ និង ភរិយា យិន ចន្ទ្រមណី............២.៩៦០.០០០៛,

៦.១៤- ឯកឧត្តមបណ្ឌិត អ៊ិប បុណ្ណា........................................១.២៣០.០០០៛,

៦.១៥- ឯកឧត្តមសាស្ត្រាចារ្យមហាបរិញ្ញា ប៉ែន បូនពី........................១.០០០.០០០៛,

៦.១៦- លោកជំទាវ ស៊ីណ្ណ បុទុម..........................................................១០០$.

**សរុប ៥៨.១២៥.០០០៛ និង ២៣.៧៤១$**

**( សរុបទាំងអស់ជារៀល = ១៥៣.០៤៩.០០០៛ ជាដុល្លារ = ៣៨.២៧២.២៥$ )។**

ថវិកាទាំងនោះ បានចំណាយលើការរៀបចំកែបន្ទប់ប្រជុំ បោះពុម្ពព្រឹត្តិបត្រ អិលស៊ីឌី ឯកសារស្រាវជ្រាវ ឧបករណ៍ប៉ំពងសំឡេង ម៉ាស៊ីនត្រជាក់ សម្ភារៈផ្ទៃបាល គ្រឿងអគ្គិសនី សម្ភារៈមួយចំនួនមាន តុ ទូ កៅអី មីក្រូហ្វូន ជាដើម (ដូចមានក្នុងសមតុល្យ ដែលបានចែកជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ គណៈកម្មការបច្ចេកទេសចំណុះ និង អគ្គលេខាធិការដ្ឋាន ក.ជ.ភ.ខ. : ថវិកានៅសល់ = ២៨.៨៦៦.៥៩២៛ ឬ ៧.២១៦,៦៤$)។

ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា ក្រោមការដឹកនាំរបស់សម្ដេចបណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងដែលជាគុរុគណៈនៃ ក.ជ.ភ.ខ. (ដែលខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ សុំសេចក្ដី អនុញ្ញាតប្រសិទ្ធិនាមថា "គុរុគណៈនិងអគ្គមគ្គុទេសក៍នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ") ដោយមានឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ជាគណៈព្យាបាលភាសាខ្មែរនឹងមានការរីកចម្រើនក្នុងការឯកភាព ដូចអរិយភាសាក្នុងលោកដែរ។

នៅទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ សូមប្រគេនព្រះពរ ចំពោះ ព្រះតេជគុណ និង សូមប្រសិទ្ធពរជ័យសិរីសួស្ដី ជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ នាងកញ្ញា សូមព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ នាងកញ្ញា ប្រកបនឹងសេចក្ដីសុខ សេចក្ដីចម្រើន និង ភាពសុខដុម ជារៀងរហូតទៅ។

សូម អរព្រះគុណ និង អរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

# សុន្ទរកថា

*******

**ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាប្រធានកិត្តិយសនិងអាណាព្យាបាលក្រុមប្រឹក្សាជាតិភាសាខ្មែរ តំណាងដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ក្នុងពិធីបើកសម័យប្រជុំលើកទី១ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១២

- សូមក្រាបថ្វាយបង្គំ ព្រះមុនីកោសល **ហ៊ិល សុធណ្ណ** រាជាគណៈថ្នាក់ទោ អនុគណៈខណ្ឌឫស្សីកែវ សមាជិកថេរសភាសង្ឃ ព្រះចៅអធិការវត្តទួលសុវណ្ណារាម និងជាឧត្តមទីប្រឹក្សានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាទីសក្ការៈ;
- សូមក្រាបថ្វាយបង្គំ ព្រះតេជគុណ **យស ហ៊ុត** ខេមចារោ ប្រធានស្ដីទីសមាគមធម្មទូត ប្រធានមូលនិធិពុទ្ធសាសនាខ្មែរ-វត្តធម្មរង្សី និងជាសមាជិកនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាទីសក្ការៈ;
- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ;
- ឯកឧត្តមបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាឧត្តមទីប្រឹក្សានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ;
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិការាជរដ្ឋាភិបាល;
- ឯកឧត្តមបណ្ឌិតសភាចារ្យ **ញ៉ុំ ម៉ាល់** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ;
- ឯកឧត្តមបណ្ឌិតសភាចារ្យ លោកជំទាវបណ្ឌិតសភាចារ្យ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ លោកគ្រូ អ្នកគ្រូ និងក្មួយៗនិស្សិតទាំងអស់ជាទីស្នេហា។

ថ្ងៃនេះ តាងនាមសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាគណនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ និងថ្នាក់ដឹកនាំក្រុមប្រឹក្សាជាតិភាសាខ្មែរ ខ្ញុំព្រះករុណាខ្ញុំ មានសេចក្ដីសោមនស្សរីករាយចូលរួមក្នុងពិធីបើកសម័យប្រជុំលើកទី១ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ នាពេលនេះ។ ខ្ញុំសូមយកឱកាសនេះ

សម្តែងនូវអំណរសាទរចំពោះការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ និងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រុមប្រឹក្សាជាតិភាសាខ្មែរគ្រប់លំដាប់ថ្នាក់ ក្នុងការធ្វើឱ្យស្ថាប័នថ្មីនេះមានដំណើរការឆ្ពោះទៅរកគោលសម្រេចរួចរាល់។

ដូចដែលព្រះតេជព្រះគុណ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗទាំងអស់ជ្រាបស្រាប់ហើយថា ការប្រើប្រាស់ភាសាខ្មែរនៅក្នុងសង្គមជាតិយើងនាពេលកន្លងមក ក៏ដូចជាពេលបច្ចុប្បន្ន នៅមានពាក្យមួយចំនួនពុំទាន់មានការឯកភាពគ្នា និងពុំទាន់មានវាក្យសព្ទគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងមុខជំនាញផ្សេងៗនៅឡើយ។ ដោយមើលឃើញបញ្ហាប្រឈមទាំងនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការរៀបចំបង្កើតឱ្យមានយន្តការថ្នាក់ជាតិមួយ សម្រាប់សម្របសម្រួលលើការសិក្សា ការប្រមូល និងការកំណត់ន័យរបស់បច្ចេកសព្ទដែលមានប្រើរួចមកហើយ និងការបង្កើតពាក្យថ្មីៗតាមមុខជំនាញនីមួយៗ ដើម្បីជំរុញឱ្យមានការឯកភាពគ្នាក្នុងភាសាជាតិទាំងសំណេរ អំណាន និងការនិយាយស្តី។ ជាងនេះទៅទៀត សម្តេចតេជោនាយករដ្ឋមន្ត្រី តែងផ្តល់ការគាំទ្រយ៉ាងពេញទំហឹង និងជាប្រចាំដល់សកម្មភាពអភិរក្សនិងអភិវឌ្ឍភាសា និងអក្សរខ្មែរ។

ខ្ញុំព្រះករុណាខ្ញុំ នៅចាំបានថា នៅចន្លោះពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាបានរៀបចំសិក្ខាសាលាចំនួន៤លើក ស្តីពីការអភិរក្ស និងការអភិវឌ្ឍភាសាខ្មែរ ដើម្បីឈានទៅរកការឯកភាពក្នុងការប្រើប្រាស់ភាសាជាតិ។ តាមរយៈសិក្ខាសាលាទាំងនោះ វិទ្យាស្ថានភាសាជាតិទទួលបាននូវមតិយោបល់ល្អៗពីអ្នកចូលរួម ដែលក្នុងនោះមានមតិភាគច្រើនបានស្នើសុំឱ្យយកវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ធ្វើជាមូលដ្ឋានក្នុងការប្រើប្រាស់ភាសាខ្មែរជាទូទៅ។ ទន្ទឹមនឹងនោះ ក៏មានមតិស្នើសុំឱ្យរាជរដ្ឋាភិបាលបង្កើតគណៈកម្មាធិការជាតិខាងភាសាមួយ ចំណុះឱ្យវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា។ ជាការឆ្លើយតបទៅនឹងបញ្ហាប្រឈមក្នុងការប្រើប្រាស់ភាសាខ្មែរ និងតម្រូវការដ៏ចាំបាច់បែបនេះ រាជរដ្ឋាភិបាលបានបង្កើត «គណៈកម្មាធិការជាតិភាសាខ្មែរ» នៅឆ្នាំ២០០៧ ដែលមាន ខ្ញុំព្រះករុណាខ្ញុំ ជាប្រធាន និងមានឯកឧត្តម **ឡុង សៀម** ជាអនុប្រធានអចិន្ត្រៃយ៍។ បន្ទាប់មកក្នុងឆ្នាំ២០០៨ ឯកឧត្តម **ហ៊ុំ ម៉ល់** ត្រូវបានតែងតាំងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិនេះជំនួសឯកឧត្តម **ឡុង សៀម** ដែលបានទទួលអនិច្ចកម្មទៅ។

ដោយវិសាលភាពការងាររបស់គណៈកម្មាធិការជាតិភាសាខ្មែរកាន់តែមានទំហំធំធេងជាងមុន រាជរដ្ឋាភិបាលបានសម្រេចកែសម្រួលយន្តការគណៈកម្មាធិការជាតិនេះឱ្យទៅជា «ក្រុមប្រឹក្សាជាតិភាសាខ្មែរ» នៅខែមិថុនា ឆ្នាំ២០១១ ហើយថ្មីៗនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរបានបង្កើតគណៈកម្មការបច្ចេកទេសចំនួន១៤ ដើម្បីសិក្សា ប្រមូល និងកំណត់និយមន័យបច្ចេកសព្ទទាក់ទងនឹងជំនាញនានាឱ្យបានកាន់តែទូលំទូលាយជាងមុន សំដៅឆ្លើយតបទៅនឹងតម្រូវការនៃការវិវត្តរបស់សង្គម និងការរីកចម្រើនរបស់បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ។ ខ្ញុំព្រះករុណាខ្ញុំ មានជំនឿយ៉ាងមុតមាំថា ក្រុមប្រឹក្សាជាតិភាសាខ្មែរនឹងប្រើប្រាស់តួនាទីដ៏ចម្បងរបស់ខ្លួន ក្នុងការពិនិត្យលើការប្រើប្រាស់ភាសា និងអក្សរខ្មែរ កំណត់ការសរសេរ ការអាន និងការឱ្យនិយមន័យឱ្យមានការឯកភាពគ្នា និងបង្កើតពាក្យថ្មី និងពាក្យកម្ចីពីបរទេស ក្នុងគោល

បំណងលើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍភាសា និងអក្សរខ្មែរ ប្រកបដោយនិរន្តរភាព និងរក្សាបាននូវអត្តសញ្ញាណជាតិខ្មែរ។

- ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងក្មួយៗនិស្សិតទាំងអស់ !

ការជួបជុំគ្នាយ៉ាងផុសផុលនៅថ្ងៃនេះ គឺជាសក្ខីភាពសបញ្ជាក់ឱ្យឃើញនូវទឹកចិត្តស្រឡាញ់ភាសា និងអក្សរខ្មែរ ពីសំណាក់បញ្ញវន្តខ្មែរមកពីគ្រប់មជ្ឈដ្ឋាន ហើយក៏ជាការប្រកាសជាផ្លូវការនូវការបន្តដំណើរការការងាររបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរពីគណៈកម្មាធិការជាតិភាសាខ្មែរផងដែរ។ ជាការពិតណាស់ គ្រប់ភាសានៃជាតិសាសន៍ទាំងអស់តែងតែមានពាក្យថ្មីៗកើតឡើងនៅពេលដែលសង្គមវប្បធម៌មានការប្រែប្រួល។ ដូចគ្នានេះដែរ ភាសាខ្មែរយើងក៏កំពុងមានការវិវត្តទៅតាមការអភិវឌ្ឍរបស់សង្គម ដែលធ្វើឲ្យមានពាក្យថ្មីៗកើតឡើងយ៉ាងច្រើន ដើម្បីយកមកប្រើប្រាស់ឱ្យសមស្របតាមការរីកចម្រើនរបស់បច្ចេកវិទ្យា វិទ្យាសាស្ត្រ ផលិតផលទំនើបៗ និងស្របតាមតម្រូវការផ្សេងៗទៀតរបស់សង្គម។ ក្នុងន័យនេះ យើងត្រូវកំណត់គោលការណ៍ និងក្បួនខ្នាតថ្នាក់ជាតិឱ្យបានច្បាស់លាស់ ដើម្បីធានាដល់ការបង្កើត និងប្រើប្រាស់ពាក្យថ្មីៗឲ្យការមានការឯកភាពគ្នា ហើយកិច្ចការទាំងនេះគឺជាភារកិច្ចស្នូលរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ។

ជាក់ស្តែង ការប្រើប្រាស់ភាសា និងអក្សរខ្មែរនាពេលបច្ចុប្បន្ននេះនៅមានភាពប្រទាញប្រទង់គ្នាមួយចំនួនដោយសារពុំទាន់មានការស្រុះស្រួល និងខ្វះការឯកភាពគ្នាលើគោលការណ៍ និងក្បួនខ្នាតពាក់ព័ន្ធទៅនឹងសំណេរ អំណាន និងការនិយាយស្តីជាដើម។ ដើម្បីកែលម្អនូវចំណុចអវិជ្ជមានទាំងនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរត្រូវបង្កើនការយកចិត្តទុកដាក់អនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន និងកាន់តែសកម្មក្នុងការពិនិត្យ និងសម្រេចឱ្យមានការឯកភាពនូវពាក្យ និងបច្ចេកសព្ទដែលមានប្រើក្នុងភាសាខ្មែរនាពេលកន្លងមក ព្រមទាំងកំណត់ការសរសេរ ការអាន ក៏ដូចជាការបង្កើតពាក្យថ្មី និងពាក្យកម្ចីពីបរទេសឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។ ជាងនេះទៅទៀត ក្រុមប្រឹក្សាជាតិភាសាខ្មែរត្រូវបង្កើនការផ្សព្វផ្សាយលទ្ធផលការងាររបស់ខ្លួន ជាពិសេសលទ្ធផលនៃការកំណត់ការប្រើភាសា និងអក្សរខ្មែរ ឱ្យកាន់តែទូលំទូលាយ តាមរយៈមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាក្នុងគ្រប់រូបភាព។

ជាមួយគ្នានេះដែរ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំព្រះករុណាខ្ញុំ សូមឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា ផ្តល់នូវកិច្ចសហការឱ្យបានស្អិតរមួតក្នុងការផ្សព្វផ្សាយ និងប្រើប្រាស់ភាសា និងអក្សរខ្មែរដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ ក៏ដូចជាចូលរួមផ្តល់នូវមតិយោបល់ពាក់ព័ន្ធនឹងបច្ចេកសព្ទ និងពាក្យថ្មីៗនៅក្នុងវិស័យ និងជំនាញឯកទេសរបស់ខ្លួន ដើម្បីឱ្យមានសុខដុមនីយកម្មក្នុងការប្រើប្រាស់ភាសា និងអក្សរខ្មែរក្នុងពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគត។ ខ្ញុំក៏សូមយកឱកាសនេះ អំពាវនាវដល់ជនរួមជាតិទាំងអស់ សូមចូលរួមនិងយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ភាសា និងអក្សរខ្មែរឱ្យបានត្រឹមត្រូវតាមការកំណត់របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ សំដៅលើកកម្ពស់ឧត្តមភាពនៃភាសាជាតិយើង ក៏ដូចជារួមចំណែកដល់ការអភិរក្ស និងអភិវឌ្ឍភាសា និងអក្សរខ្មែរ។

ជាថ្មីម្ដងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមសម្ដែងនូវអំណរគុណចំពោះព្រះតេជគុណ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្មួយៗនិស្សិត និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមគាំទ្រដល់ការលើកស្ទួយតម្លៃវប្បធម៌ជាតិយើង ជាពិសេសភាសា និងអក្សរខ្មែរដែលជាជំហរព្រលឹងនៃវប្បធម៌ និងជាអត្តសញ្ញាណរបស់ជាតិយើង ឱ្យសមផ្ទួចសុភាសិតខ្មែរពោលថា «វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិរុងរឿង»។ ក្នុងន័យនេះ ខ្ញុំព្រះករុណាខ្ញុំ សូមសម្ដែងនូវការគាំទ្រ និងលើកទឹកចិត្តដល់បណ្ដាក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានសិក្សាគ្រប់កម្រិត ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ជាពិសេសបណ្ដាញផ្សព្វផ្សាយព័ត៌មាន និងគ្រឹះស្ថានបោះពុម្ពផ្សាយនានា ឱ្យយកចិត្តទុកដាក់ពិនិត្យឱ្យបានដិតដល់ចំពោះការសរសេរ ការអាន ការថ្លឹងពាក្យ និងការបង្កើតពាក្យថ្មីៗ ដើម្បីធានាឱ្យបាននូវការឯកភាពគ្នាក្នុងការប្រើប្រាស់ភាសា និងអក្សរខ្មែរយើង។ ក្នុងករណីដែលមានការយល់មិនស្របគ្នាទាំងវេយ្យាករណ៍ សំណេរ អំណាន និងបញ្ហាពាក់ព័ន្ធផ្សេងទៀតក្នុងការប្រើប្រាស់ភាសា និងអក្សរខ្មែរ ខ្ញុំព្រះករុណាខ្ញុំ សូមឱ្យមានការជជែកពិភាក្សាគ្នាឱ្យបានល្អិតល្អន់ក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាជាងធ្វើការបកស្រាយជាសាធារណៈដោយអត្តនោម័តិ ដែលអាចបណ្ដាលឱ្យសាធារណជនមានការភាន់ច្រឡំ។ ការឯកភាពក្នុងភាសា ជាសញ្ញាណនៃការឯកភាពជាតិ។ ខ្ញុំព្រះករុណាខ្ញុំ សង្ឃឹមថា ក្រុមប្រឹក្សាជាតិភាសាខ្មែរនឹងខិតខំយកចិត្តទុកដាក់បង្កើនការផ្សព្វផ្សាយលទ្ធផលការងាររបស់ខ្លួនឱ្យបានជ្រួតជ្រាបដល់ស្រទាប់មហាជនយ៉ាងទូលំទូលាយ និងទាន់ពេលវេលា។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមយកឱកាសនេះអំពាវនាវដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី និងសប្បុរសជនជាតិនិងអន្តរជាតិទាំងអស់ សូមជួយឧបត្ថម្ភគាំទ្រជាស្មារតី សម្ភារៈ និងថវិកា ដល់ដំណើរការការងាររបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក៏ដូចជាការផ្សព្វផ្សាយលទ្ធផលការងារទាំងនោះជាសាធារណៈ ដើម្បីជាប្រយោជន៍របស់ជាតិយើងទាំងមូល និងជាកេរដំណែលដល់អ្នកជំនាន់ក្រោយ។

នៅទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ និងសូមជូនពរឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី និងក្មួយៗនិស្សិតទាំងអស់ មានសុខភាពល្អ ជោគជ័យគ្រប់ភារកិច្ច និងមានសុភមង្គលនៅក្នុងក្រុមគ្រួសារ។

ខ្ញុំព្រះករុណាខ្ញុំ សូមប្រកាសបើកសម័យប្រជុំលើកទី១នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ចាប់ពីពេលនេះ តទៅ។

**សូម អរព្រះគុណ និង អរគុណ !**

ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២០០

ស្តីពី

ការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ**
**ខេមរជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១

**ត្រាស់បង្គាប់**

**ជំពូកទី១**
**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.-**

ត្រូវបានបង្កើត ក្រុមប្រឹក្សាជាតិភាសាខ្មែរ សរសេរកាត់ថា "ក.ជ.ភ.ខ" ដែលជាយន្តការជាតិស្ថិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអភិវឌ្ឍនិងអភិរក្សការប្រើភាសានិងអក្សរខ្មែរប្រកបដោយនិរន្តរភាពព្រមទាំងរក្សាបាននូវអត្តសញ្ញាណជាតិខ្មែរ។

## ជំពូកទី២

## សមាសភាពរបស់ ក.ជ.ភ.ខ.

**មាត្រា ២.-**

**ក.ជ.ភ.ខ.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| - នាយករដ្ឋមន្ត្រី | | គុរុកោ |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | | ប្រធានកិត្តិយស |
| - ឥស្សរជនជំនាញនិងមានបទពិសោធខាងអក្សរសាស្ត្រ | មួយរូប | ប្រធាន |
| - ប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា | | អនុប្រធាន |
| - ឥស្សរជនជំនាញខាងអក្សរសាស្ត្រ | មួយចំនួន | អនុប្រធាន |
| - តំណាងមួយរូបពីក្រសួង ស្ថាប័នពាក់ព័ន្ធ | មួយចំនួន | សមាជិក |
| - ឥស្សរជនជំនាញខាងអក្សរសាស្ត្រ | មួយចំនួន | សមាជិក |
| - ឥស្សរជនជំនាញឯកទេស | មួយចំនួន | សមាជិក |
| - តំណាងសមាគមអ្នកនិពន្ធខ្មែរ | មួយរូប | សមាជិក |
| - អគ្គលេខាធិការ **ក.ជ.ភ.ខ.** | | សមាជិក។ |

សមាសភាព **ក.ជ.ភ.ខ.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា ៣.-**

**ក.ជ.ភ.ខ.** អាចមានទីប្រឹក្សាមួយចំនួនតាមការចាំបាច់។

## ជំពូកទី៣

## ភារកិច្ចរបស់ ក.ជ.ភ.ខ.

**មាត្រា ៤.-**

**ក.ជ.ភ.ខ.** មានភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយជាតិនៃភាសានិងអក្សរខ្មែរ
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ
- ពិនិត្យនិងសម្រេច ឲ្យមានការឯកភាពនូវពាក្យនិងបច្ចេកសព្ទដែលបានប្រើក្នុងភាសាខ្មែររួចមកហើយ
- កំណត់ការសរសេរ ការអាន និង និយមន័យឲ្យមានការឯកភាពក្នុងភាសាខ្មែរ
- បង្កើតពាក្យថ្មី និង សម្រេចអំពីការខ្ចីពាក្យ
- ត្រួតពិនិត្យការប្រើប្រាស់ភាសានិងអក្សរខ្មែរ
- ជាកំជូនប្រមុខរាជរដ្ឋាភិបាលប្រកាសឲ្យប្រើជាសាធារណៈនូវលទ្ធផលនៃការកំណត់ការប្រើភាសានិងអក្សរខ្មែរ

ចងក្រង និង ផ្សព្វផ្សាយភាសានិងអក្សរខ្មែរតាមមធ្យោបាយផ្សេងៗដែលមានសិក្ខាសាលាផង

- សហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និង រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីមានផែនការសមស្របចំពោះការប្រើភាសានិងអក្សរខ្មែរដែលបានកំណត់រួចហើយឲ្យមានប្រសិទ្ធភាព
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាពាក់ព័ន្ធនឹងការប្រើភាសា និង អក្សរខ្មែរ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## កិច្ចដំណើរការការងាររបស់ ក.ជ.ភ.ខ.

**មាត្រា ៥.-**

**ក.ជ.ភ.ខ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធាន **ក.ជ.ភ.ខ.** មានសិទ្ធិអញ្ជើញតំណាងក្រសួង និង ស្ថាប័នពាក់ព័ន្ធ ជាថ្នាក់ដឹកនាំ និង ថ្នាក់បច្ចេកទេសឲ្យមកចូលរួមប្រជុំដើម្បីជួយបំភ្លឺ និង ផ្តល់ព័ត៌មានបន្ថែមតាមការចាំបាច់។

**មាត្រា ៦.-**

**ក.ជ.ភ.ខ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **ក.ជ.ភ.ខ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៧.-**

**ក.ជ.ភ.ខ.** មានគណៈកម្មការបច្ចេកទេសសម្រាប់កិច្ចដំណើរការការងារតាមការចាំបាច់។

សមាសភាពនិងតួនាទីភារកិច្ចរបស់គណៈកម្មការបច្ចេកទេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ៨.-**

**ក.ជ.ភ.ខ.** មានសញ្ញា និង ត្រាដោយឡែករបស់ខ្លួន។

**មាត្រា ៩.-**

របៀបបំពេញការងាររបស់ **ក.ជ.ភ.ខ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១០.-**

ប្រធាន អនុប្រធាន សមាជិក និង ទីប្រឹក្សា **ក.ជ.ភ.ខ.** គណៈកម្មការបច្ចេកទេស ទទួលប្រាក់ឧបត្ថម្ភប្រជុំនិងស្រាវជ្រាវតាមការកំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា ១១.-**

ក.ជ.ភ.ខ. ត្រូវប្រើវចនានុក្រមខ្មែររៀបរៀងដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ឆ្នាំ១៩៦៧ ជាគោល។

## ជំពូកទី៥
## ប្រភពធនធានរបស់ ក.ជ.ភ.ខ.

**មាត្រា ១២.-**

ក.ជ.ភ.ខ. មានប្រភពធនធានបានមកពី ៖

- ថវិកាជាតិ ដាក់ភ្ជាប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- អំណោយ និង វិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍ជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និង សប្បុរសជននានា
- ជំនួយឥតសំណងផ្សេងៗ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤០ ខែ មិថុនា ឆ្នាំ២០១១

ពរល. ១១០៦. ៦១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ៥៦៣ ច.ល
ជើងលិខិតផ្ទុំចែក
រាជធានីភ្នំពេញ ថ្ងៃទី ៩៣ ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/[illegible]

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | កិត្តិ |
| ២- ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធានកិត្តិយស |
| ៣- ឯកឧត្តម បណ្ឌិតសភាចារ្យ **ភ្នំ ម៉ល់** | ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកផ្នែកភាសាវិទ្យានៅរាជបណ្ឌិត្យសភាកម្ពុជា | ប្រធាន |
| ៤- លោកជំទាវ បណ្ឌិតសភាចារ្យ **ខ្លូត ធីតា** | ប្រធានរាជបណ្ឌិត្យសភាកម្ពុជា | អនុប្រធាន |
| ៥- ឯកឧត្តម បណ្ឌិតសភាចារ្យ **គិច សំណាង** | ទីប្រឹក្សារាជរដ្ឋាភិបាល | អនុប្រធាន |
| ៦- ឯកឧត្តម បណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** | អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា | អនុប្រធាន |
| ៧- ឯកឧត្តម បណ្ឌិត **ច័ន្ទ សំណាង** | អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា | អនុប្រធាន |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ៨- ឯកឧត្តម បណ្ឌិតសភាចារ្យ **អ៊ឹម ច័ន** | ប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា | អនុប្រធាន |
| ៩- ឯកឧត្តម **ឈន អៀម** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | អនុប្រធាន |
| ១០- ឯកឧត្តម **សុ មុយឃៀង** | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ | អនុប្រធាន |
| ១១- ព្រះតេជគុណ **យស ហ៊ុត** ខេមចារោ | ប្រធានស្ដីទីសមាគមធម្មទូត និង ជាប្រធានមូលនិធិពុទ្ធសាសនាខ្មែរ-វត្តធម្មយុត្តិ | សមាជិក |
| ១២- ព្រះគ្រូ **ម៉ិត សាមឿន** | ទីប្រឹក្សាសមាគមកម្ពុជរដ្ឋ | សមាជិក |
| ១៣- ឯកឧត្តម បណ្ឌិតសភាចារ្យ **សេង ចន្ទ្រាបុត្រ** | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១៤- ឯកឧត្តម បណ្ឌិតសភាចារ្យ **សំ សោភាន់** | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១៥- ឯកឧត្តម បណ្ឌិតសភាចារ្យ **ជា លាង** | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១៦- ឯកឧត្តម បណ្ឌិតសភាចារ្យ **ឆយ មួន** | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ | សមាជិក |
| ១៧- ឯកឧត្តម បណ្ឌិតសភាចារ្យ **សោម សុមុនី** | ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១៨- ឯកឧត្តម បណ្ឌិត **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១៩- ឯកឧត្តម បណ្ឌិត **ណេត បារ៉ុម** | អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ២០- ឯកឧត្តម បណ្ឌិត **ណារ៉ាត ម៉ុងឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា | សមាជិក |
| ២១- ឯកឧត្តម បណ្ឌិត **ម៉ៅ សុត្ថន** | ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២២- ឯកឧត្តម បណ្ឌិត **សន ពៅ** | អគ្គលេខាធិការក្រុមប្រឹក្សាជាតិភាសាខ្មែរ | សមាជិក |
| ២៣- លោកជំទាវ បណ្ឌិត **សំ ធាវី** | ជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា | សមាជិក |
| ២៤- ឯកឧត្តមសាស្ត្រាចារ្យមហាបណ្ឌិត **ម៉ែន ម៉ុនពិច** | អនុប្រធានវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម នៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ២៥- ឯកឧត្តម **ជា គាន** | អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និង | |



| | | |
|---|---|---|
| | ជាអគ្គលេខាធិការរងទី១ក្រុមប្រឹក្សា<br>ជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍<br>មាតុភូមិកម្ពុជា | សមាជិក |
| ២៦- ឯកឧត្តម ឃុន ទិចិត្រ | ទីប្រឹក្សាក្រសួងព័ត៌មាន និង ជាអគ្គនាយករង<br>អគ្គនាយកដ្ឋានរដ្ឋបាល ព័ត៌មាន<br>និងសោតទស្សន៍ក្រសួងព័ត៌មាន | សមាជិក |
| ២៧- លោកជំទាវ ស៊ីមវណ្ណា មុទុម | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ២៨- ឯកឧត្តម ឡាយ សុខា | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ២៩- ឯកឧត្តម ឡៀង សារ៉េត | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៣០- ឯកឧត្តម សិរ ម៉ៅ | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៣១- ឯកឧត្តម ពេជ សារឿន | ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣២- ឯកឧត្តម ទី ម៉ុម | អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ៣៣- ឯកឧត្តម ស៊ី សុផាន | អគ្គលេខាធិការរងគណៈកម្មាធិការ<br>ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | សមាជិក |
| ៣៤- លោក បណ្ឌិត ទៅ ស៊ីន | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា<br>នៃក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ៣៥- លោក បណ្ឌិត អ៊ឹម ចំមុល | មេធាវី | សមាជិក |
| ៣៦- លោក សឹម ផុស | សមាជិកគណៈកម្មការបណ្ឌិត្យសភា<br>ទទួលបន្ទុកអនុម័តពាក្យច្បាប់ | សមាជិក |
| ៣៧- លោក ម៉ៀច ម៉ុណ្ណា | ទីប្រឹក្សាអមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ<br>នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ | សមាជិក |
| ៣៨- លោក ស៊ឹម សារ៉ាត់ | អតីតអគ្គនាយកក្រសួងវប្បធម៌<br>និងវិចិត្រសិល្បៈចូលនិវត្តន៍ | សមាជិក |
| ៣៩- លោក អាស តាំ | មន្ត្រីការទូតជាន់ខ្ពស់ចូលនិវត្តន៍ | សមាជិក |
| ៤០- លោក ឆន់ ហ៊ិន | មន្ត្រីការទូតជាន់ខ្ពស់ចូលនិវត្តន៍ | សមាជិក |
| ៤១- លោក អ៊ុក ប៊ុន | អតីតព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យ<br>សង្គមសាស្ត្រមនុស្សសាស្ត្រនៃសាកល<br>វិទ្យាល័យភូមិន្ទភ្នំពេញចូលនិវត្តន៍ | សមាជិក |
| ៤២- លោក ខុន ម៉ាន់មង្គី | នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ | សមាជិក |

៤៣- លោក ចាន់សូ សុខត្រ — ប្រធាននាយកដ្ឋាននីតិកម្មក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល — សមាជិក

៤៤- លោក ទៅ ពិសិដ្ឋ — អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងព័ត៌មាននៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាព អប់រំនៃកម្ពុជា — សមាជិក

៤៥- លោក ស៊ី ម៉ច់ — ប្រធានការិយាល័យតម្កល់ឯកសារ បញ្ជីពាណិជ្ជកម្មនៃនាយកដ្ឋានចុះបញ្ជី ពាណិជ្ជកម្មក្រសួងពាណិជ្ជកម្ម — សមាជិក

៤៦- លោក ឆួច គីមស្រ៊ាង — សមាជិកក្រុមជំនុំព្រះត្រៃបិដក វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ — សមាជិក

**មាត្រា ២ :** ត្រូវបានតែងតាំងឧត្តមទីប្រឹក្សា និង ទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចខាងក្រោម ៖

ក.សមាសភាពឧត្តមទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ

១- សម្តេចព្រះធម្មលិខិត **លាស់ ឡាយ** — ព្រះរាជាគណៈថ្នាក់ឯក ព្រះសង្ឃនាយករងទី១ និងជាព្រះចៅអធិការវត្តសន្សំកុសល

២- ព្រះមុនីកោសល **ហ៊ិល សុវណ្ណ** — រាជាគណៈថ្នាក់ទោ អនុគណខេត្តឬស្សីកែវ សមាជិកថេរសភាសង្ឃ និង ជាព្រះចៅអធិការវត្តខ្មុល សុវណ្ណារាម

៣- ឯកឧត្តម បណ្ឌិត **គាត ឈន់** — ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ខ.សមាសភាពទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ

១- ឯកឧត្តម បណ្ឌិតសភាចារ្យ **ស៊ិន សំណាង** — ទីប្រឹក្សាគណរដ្ឋាភិបាល

២- ឯកឧត្តម បណ្ឌិត **ច័ន្ទ សារុន** — រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

៣- ឯកឧត្តម បណ្ឌិត **អ៊ុន ចិរជាតិ** — រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

៤- ឯកឧត្តម បណ្ឌិត **ស៊ឹម មណ្ណា** — រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានសមាគមអ្នកនិពន្ធខ្មែរ

៥- ឯកឧត្តម បណ្ឌិត **ឆ ប៊ុណ្ណារិទ្ធ** — ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា

៦- ឯកឧត្តម បណ្ឌិត **ស៊ុន ហួរ** — ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីជួយកិច្ចការ

| | |
|---|---|
| | រាជបណ្ឌិត្យសភាកម្ពុជា |
| ៧- ឯកឧត្តម **ជាម អេមឃួន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល |
| ៨- ឯកឧត្តម **ម៉ៅ សុផាន់** | ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាយរងសេនាធិការចម្រុះនៃកងយុទ្ធពលខេមរភូមិន្ទ និង ជាមេបញ្ជាការកងពលតូចលេខ៧០ |
| ៩- ឯកឧត្តម **ឈួន លឹមហេង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និង ជាទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា |
| ១០- ឯកឧត្តម **មង់ សម្បត្តិ** | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា |

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នសរក.១១០៧.៧៥៣*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១*

**លេខ: ៧៤៥ ច.ល**
**...ចម្លងចេញពីច្បាប់ដើម**
**...ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១**
**...អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**... ជិនអេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ

## របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ សរសេរកាត់ថា អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ដែលជាសេនាធិការសម្រាប់កិច្ចដំណើរការការងាររបស់ **ក.ជ.ភ.ខ.**។

## ជំពូកទី២

## ភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** មានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំផែនការការងារនិងសម្របសម្រួលដំណើរការងារជូន **ក.ជ.ភ.ខ.**
- រៀបចំយន្តការត្រួតពិនិត្យនិងតាមដានការប្រើភាសានិងអក្សរខ្មែរ
- រៀបចំយន្តការសម្រាប់បណ្តុះបណ្តាលការប្រើភាសានិងអក្សរខ្មែរ
- រៀបចំយន្តការចងក្រងនិងផ្សព្វផ្សាយភាសានិងអក្សរខ្មែរ
- គ្រប់គ្រងកិច្ចការរដ្ឋបាលនៃ **ក.ជ.ភ.ខ.**
- បំពេញការងារហិរញ្ញវត្ថុជូន **ក.ជ.ភ.ខ.**
- រៀបចំផែនការបណ្តុះបណ្តាលមន្ត្រីលេខាធិការដ្ឋាន ដើម្បីពង្រឹងនិងបង្កើនសមត្ថភាពការងារ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពនិងលទ្ធផលការងារជូន **ក.ជ.ភ.ខ.**
- ជួយសម្រួលការងារស្រាវជ្រាវជូន **ក.ជ.ភ.ខ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

## ជំពូកទី៣

## របចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។ អគ្គលេខាធិការរង **ក.ជ.ភ.ខ.** បំពេញភារកិច្ចតាមការបែងចែកការងាររបស់អគ្គលេខាធិការ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

- ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
- ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល



ផ្នែកតាមដាននិងត្រួតពិនិត្យ។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន ក.ជ.ភ.ខ. ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ផ្នែកនីមួយៗ ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធានផ្នែកត្រូវតែងតាំងដោយអនុក្រឹត្យនិងអនុប្រធានផ្នែកត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ៦.-**

មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ភ.ខ. ជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ ដែលមកពីក្រសួងនិងស្ថាប័ននានា ឬបញ្ញវន្តដែលមានសមត្ថភាពខ្ពស់។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន ក.ជ.ភ.ខ. អាចមានបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយការងារ។

មន្ត្រីដែលមិនទទួលប្រាក់បៀវត្ស ទទួលប្រាក់ឧបត្ថម្ភសម្រាប់បំពេញការងារជូន ក.ជ.ភ.ខ. តាមការស្នើសុំរបស់ប្រធាន ក.ជ.ភ.ខ.។

## ជំពូកទី៤
## ភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ៧.-**

ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុមានភារកិច្ច ដូចខាងក្រោម ៖

- ទទួលបន្ទុកការងារបុគ្គលិកនិងការងារពិធីការ
- ធានាប្រសិទ្ធភាពនិងនិរន្តរភាពនៃដំណើរការរដ្ឋបាល
- រៀបចំគ្រប់គ្រងសំណុំលិខិតរដ្ឋបាលនិងទុកដាក់ឯកសាររដ្ឋបាលគ្រប់ប្រភេទ
- សហការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាពាក់ព័ន្ធនិងការប្រើភាសានិងអក្សរខ្មែរ
- ធ្វើផែនការរួមរបស់ ក.ជ.ភ.ខ
- ធ្វើទំនាក់ទំនងនិងសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីសម្រួលការងាររបស់ ក.ជ.ភ.ខ.
- ការពារសន្តិសុខ សណ្តាប់ធ្នាប់ រក្សាសុវត្ថិភាពសម្ភារៈនិងអនាម័យ ក្នុងបរិវេណអគ្គលេខាធិការដ្ឋាន
- សហការបូកសរុបរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ
- ធ្វើកំណត់ហេតុគ្រប់អង្គប្រជុំរបស់ ក.ជ.ភ.ខ.
- ទទួលខុសត្រូវលើផ្នែកហិរញ្ញវត្ថុនិងផ្គត់ផ្គង់
- រៀបចំគម្រោងថវិកា គម្រោងសម្ភារៈបរិក្ខារ និង មធ្យោបាយការងារផ្សេងៗ
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ និងរាល់ចំណូល ចំណាយរបស់ ក.ជ.ភ.ខ.
- បូកសរុបរបាយការណ៍ថវិការបស់ ក.ជ.ភ.ខ.

- ទទួលខុសត្រូវចំពោះបញ្ជីគណនេយ្យនិងបេឡា
- ធ្វើទំនាក់ទំនងលើបញ្ហាថវិកាជាមួយទីស្ដីការគណៈរដ្ឋមន្ត្រី
- ធ្វើរបាយការណ៍សកម្មភាពនិងលទ្ធផលការងារតាមការកំណត់
- ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

**មាត្រា ៨.-**

ផ្នែកបោះពុម្ព ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល មានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំចងក្រងពាក្យដែល **ក.ជ.ភ.ខ.** បានអនុម័តនិងបោះពុម្ពជាព្រឹត្តិបត្រនិងសទ្ទានុក្រម
- ចែកផ្សាយព្រឹត្តិបត្រ សទ្ទានុក្រម និងឯកសារផ្សេងៗ ដែលបានបោះពុម្ព
- រៀបចំគេហទំព័រនិងបញ្ចូលទិន្នន័យដែលត្រូវផ្សព្វផ្សាយ
- សហការជាមួយប្រព័ន្ធផ្សព្វផ្សាយនានាមាន វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ជាដើម ដើម្បីធ្វើការផ្សព្វផ្សាយលទ្ធផលរបស់ **ក.ជ.ភ.ខ.** និងសេចក្ដីសម្រេចនានារបស់រាជរដ្ឋាភិបាលទាក់ទងនឹងភាសា អក្សរខ្មែរ ឲ្យបានទូលំទូលាយ
- រៀបចំផែនការសម្រាប់សិក្ខាសាលា ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល ការប្រើភាសានិងអក្សរខ្មែរដល់អ្នកនិពន្ធ អ្នកសារព័ត៌មាន ពិធីករ ពិធីការិនី និងដល់សាធារណជនទូទៅ
- រៀបចំគម្រោងបោះពុម្ពផ្សាយនិងចាត់ចែងបោះពុម្ពផ្សាយអត្ថបទ
- រៀបចំគ្រប់គ្រងបណ្ណាល័យ
- ធ្វើរបាយការណ៍សកម្មភាពនិងលទ្ធផលការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

**មាត្រា ៩.-**

ផ្នែកតាមដាននិងត្រួតពិនិត្យ មានភារកិច្ច ដូចខាងក្រោម ៖

- តាមដាននិងត្រួតពិនិត្យការប្រើភាសានិងអក្សរខ្មែរ តាមផ្លាកផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ តាមទស្សនាវដ្ដី ព្រឹត្តិបត្រ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន សៀវភៅ និងឯកសារផ្សេងៗទៀត
- ចូលរួមសហការស្រាយបំភ្លឺចម្ងល់របស់សាធារណជន លើការប្រើភាសានិងអក្សរខ្មែរ
- ប្រមូលនិងស្រង់ពីគ្រប់មជ្ឈដ្ឋាននិងគ្រប់តំបន់នូវទិន្នន័យទាក់ទងនឹងការប្រើភាសានិងអក្សរខ្មែរ ក្រោយពេលដែលរាជរដ្ឋាភិបាល បានប្រកាសឲ្យប្រើជាសាធារណៈ
- ធ្វើរបាយការណ៍សកម្មភាពនិងលទ្ធផលការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ[illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១១
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ ក.ជ.ត.ខ



# បច្ចេកសព្ទរបស់គណៈកម្មការវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា
# ដែល គ.ជ.ភ.ខ. បានអនុម័ត

| | |
|---|---|
| **១- កុំព្យូទ័រ**<br>អ. computer,<br>បារ. ordinateur (m.) | ម៉ាស៊ីនអេឡិចត្រូនិកមួយបែបដែលអាចបញ្ចូល រក្សាទុក គណនា វិភាគ ធ្វើសេចក្តីសម្រេច និង ទាញយកទិន្នន័យ ។ |
| **២- បណ្តាញ**<br>អ. network,<br>បារ. réseau (m.) | បណ្តុំមធ្យោបាយនៃការតភ្ជាប់កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព និង ឧបករណ៍ផ្សេងៗរួមគ្នា ដើម្បីឱ្យពួកវាអាចផ្លាស់ប្តូរព័ត៌មាន ដូចជា សំឡេង រូបភាព អត្ថបទ ។ល។ ឬ ទាក់ទងគ្នាទៅវិញទៅមក ។ |
| **៣- អ៊ីនធឺណិត(បណ្តាញសកល)**<br>អ. internet (net, or cyber),<br>បារ. internet (m.) | បណ្តាញកុំព្យូទ័រពិភពលោក ដែលអាចឱ្យមនុស្សចែករំលែកព័ត៌មាន និង ទាក់ទងគ្នាទៅវិញទៅមក ។ |
| **៤- អ៊ីនត្រាណិត**<br>អ. intranet,<br>បារ. intranet (m.) | បណ្តាញរបស់ស្ថាប័នមួយ ដែលប្រើបច្ចេកវិទ្យាអ៊ីនធឺណិត ដើម្បីបញ្ជូនទិន្នន័យ ។ |
| **៥- អិចត្រាណិត**<br>អ. extranet,<br>បារ. ... | បណ្តាញរបស់ស្ថាប័នមួយ ដែលផ្តល់សិទ្ធិឱ្យអតិថិជនទាំងក្នុងឬ ក្រៅប្រទេសអាចប្រើអ៊ីនត្រាណិតបាន ។ |
| **៦- កាត់**<br>អ. cut,<br>បារ. couper (v.) | ប្តូរឯកសារ ផ្នែកខ្លះនៃអត្ថបទ រូបភាព ព័ត៌មាន ឬ កិច្ចការណាមួយពីកន្លែងមួយទៅកន្លែងមួយទៀត ។<br>លុបឯកសារ ផ្នែកខ្លះនៃអត្ថបទ រូបភាព ព័ត៌មាន ឬ កិច្ចការណាមួយ ប៉ុន្តែ អាចយកមកបង្ហាញឡើងវិញបាន ។ |
| **៧- ការបញ្ឈប់/ការបោះបង់ (អាបិត)**<br>អ. abort<br>បារ. abandon (m.) | ពាក្យឬមុខងារប្រើសម្រាប់បញ្ជាពីការបញ្ចប់នូវកម្មវិធីដំណើរការអ្វីមួយដែលកំពុងធ្វើ ។ |
| **៨- ថាសរឹង** *ន.*<br>អ. hard disk / disk drive<br>បារ. disque dur | ថាសម៉ាញេទិក ដែលត្រូវគេដាក់ជាប់ឬភ្ជាប់ក្នុងកុំព្យូទ័រ ហើយ ដែលអាចផ្ទុកព័ត៌មាន ទិន្នន័យ កម្មវិធីបានក្នុងបរិមាណច្រើន ។ |

| | |
|---|---|
| **៩- ថាសទន់**<br>អ. floppy disk / floppy drive / diskette<br>បារ. disquette (f.) | ថាសម៉ាញេទិកស្តើង ដែលត្រូវគេដាក់នៅក្នុងប្រអប់ប្លាស្ទិករាងការ៉េ ហើយ ដែលគេប្រើសម្រាប់ផ្ទុកព័ត៌មាន ទិន្នន័យ កម្មវិធីបានក្នុងបរិមាណតិចតួច ។ |
| **១០- ថាសចល័ត**<br>អ. removable disk<br>បារ. ... | ប្រភេទថាសមួយ ដែលអាចឱ្យអ្នកប្រើប្រាស់ងាយស្រួលផ្លាស់ប្តូរទិន្នន័យដោយមិនចាំបាច់ដោះកុំព្យូទ័រទេ លើកលែងតែថាសរឹងដែលភ្ជាប់ពីខាងក្រៅកុំព្យូទ័រ ។<br>ឧ. ថាសចម្រៀង ថាសវីដេអូ ថាសទន់ ។ |
| **១១- កាត**<br>អ. card<br>បារ. carte (f.) | **អត្ថន័យទីមួយ :** បន្ទះឬបណ្ណដែលអាចឱ្យមានទំនាក់ទំនងជាមួយឧបករណ៍មួយ ។<br>ឧ. កាតសំឡេង កាតបណ្តាញ ។<br>**អត្ថន័យទីពីរ :** បន្ទះសៀគ្វីអគ្គិសនីមួយ ដែលស៊កទៅក្នុងផ្នែកមួយនៃកុំព្យូទ័រ ។ |
| **១២- អន្តរបណ្តាញ**<br>អ. internetwork,<br>បារ. ... | ការតភ្ជាប់បណ្តាញពីរឬច្រើនចូលគ្នាតាមរយៈឧបករណ៍ផ្សេងៗ ដែលជាទូទៅ មានតួនាទីធ្វើឱ្យក្លាយជាបណ្តាញតែមួយ ដើម្បីអាចឱ្យទិន្នន័យនៃកុំព្យូទ័រមួយនៅលើបណ្តាញមួយអាចឆ្លងកាត់ទៅកុំព្យូទ័រមួយនៅលើបណ្តាញមួយទៀត ។ |
| **១៣- អន្តរកម្មនៃបណ្តាញ**<br>អ. internet working,<br>បារ. ... | ទំនាក់ទំនងទៅវិញទៅមករវាងបណ្តាញពីរឬច្រើន (ពាក្យនេះអាចសម្គាល់ទៅលើផលិតផល នីតិវិធី ឬ បច្ចេកវិទ្យា ) ។ |
| **១៤- តភ្ជាប់**<br>អ. connect<br>បារ. connecter (v.) | ភ្ជាប់របស់ពីរឬច្រើនចូលគ្នា ។ |
| **១៥- តំណ /ការតភ្ជាប់**<br>អ. connection,<br>បារ. connexion (f.) | - ចំពោះប្រព័ន្ធគមនាគមន៍ មានន័យថា ជាផ្លូវមួយ ដែលបានបង្កើតរវាងឧបករណ៍ពីរដើម្បីប្តូរព័ត៌មានគ្នា ។<br>- ចំពោះភាសាសរសេរកម្មវិធី មានន័យថា ជាយន្តការមួយ(ពាក្យមួយ) ដែលអាចឱ្យមានអន្តរកម្មក្នុងចំណោមមុខងារ ។ |
| **១៦- តំណភាព**<br>អ. connectivity,<br>បារ. ... | - វិធីពិពណ៌នា ថាតើឧបករណ៍ពីរឬច្រើនធ្វើការល្អជាមួយគ្នាដូចម្តេច ?<br>- ការផ្តល់បច្ចេកវិទ្យានិងប្រព័ន្ធគមនាគមន៍ ដើម្បីផ្ទៀងផ្ទាត់ការបញ្ជូនទិន្នន័យរវាងបណ្តាញពីរ ។ |
| **១៧- ឈ្នាប់**<br>អ. connector,<br>បារ. connecteur (m.) | - និមិត្តសញ្ញាមួយដែលតាងឱ្យផ្នែកដាច់ពីគ្នានៃរូបមួយ និងកំណត់ទីតាំង ដែលត្រូវភ្ជាប់បន្ត ។<br>- ឧបករណ៍ឬគ្រឿងមួយ ដែលត្រូវបានប្រើភ្ជាប់ផ្នែកអគ្គិសនីពីរឬច្រើនដទៃផ្សេងៗចូលគ្នា (ឧបករណ៍នៅខាងចុងនៃខ្សែ ដែលដោតទៅក្នុងរន្ធ ឬ ផ្ទៃញែក ក្នុងគោលបំណងភ្ជាប់ឧបករណ៍មួយទៅឧបករណ៍មួយទៀត) ។ |

| | |
|---|---|
| **១៨- ឈីប**<br>អ. chip,<br>បារ. éclat (m.) | ក្រាមស៊ីលីស្យូមស្តើងតូចៗ ដែលនៅលើនោះមានសៀគ្វីជាច្រើនជាមួយនឹងសមាសភាគរាប់រយពាន់ ។ |
| **១៩- សំណុំឈីប**<br>អ. chipset<br>បារ. ensemble de l'éclat | ក្រុមឈីប ដែលធ្វើការរួមគ្នាក្នុងកិច្ចការណាមួយ ។ |
| **២០- មេម៉ូរី**<br>អ. memory | ឧបករណ៍ គ្រឿង ឬ ផ្នែកនៃកុំព្យូទ័រដែលអាចផ្ទុកទិន្នន័យ កម្មវិធី ជាអចិន្ត្រៃយ៍ ឬ បណ្តោះអាសន្ន ។ ឧបករណ៍នេះផ្ទុកទិន្នន័យក្នុងទម្រង់ជាឈីប ។ |
| **២១- ឈីបមេម៉ូរី**<br>អ. memory chip<br>បារ. ... | ឈីបឬមីក្រូឈីប ដែលអាចដោតចូលទៅក្នុងកុំព្យូទ័រ ដើម្បីផ្តល់ជាមេម៉ូរីបន្ថែម ។ |
| **២២- ប៊ីត**<br>អ. bit (មកពីពាក្យ binary digit)<br>បារ. ... | ឯកតាតូចបំផុតនៃព័ត៌មានឬនៃតួអក្សរមួយ ដែលកុំព្យូទ័រឬឧបករណ៍ផ្សេងៗអាចដំណើរការ ហើយ វាមានតម្លៃ១(មួយ) ឬ 0(សូន្យ) ។ |
| **២៣- បៃ**<br>អ. byte<br>បារ. octet (m.) | ខ្នាតព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលជាធម្មតាមាន៨(ប្រាំបី)ប៊ីត ។ |
| **២៤- គីឡូបៃ**<br>អ. kilobyte<br>បារ. kilo-octet (m.) | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ 0២៤ បៃ ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យកមួយគីឡូបៃស្មើនឹង ១ 000 បៃ ហើយអក្សរកាត់ គឺ KB ។ |
| **២៥- មេហ្គាបៃ**<br>អ. megabyte<br>បារ. mégaoctet (m.) | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ 0២៤ គីឡូបៃ ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យកមួយមេហ្គាបៃស្មើនឹង ១ 000 គីឡូបៃ ហើយអក្សរកាត់ គឺ MB ។ |
| **២៦- ជីហ្គាបៃ**<br>អ. gigabyte<br>បារ. gigaoctet (m.) | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ 0២៤ មេហ្គាបៃ ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យកមួយជីហ្គាបៃស្មើនឹង ១ 000 មេហ្គាបៃ ហើយ អក្សរកាត់ គឺ GB ។ |
| **២៧- តេរ៉ាបៃ**<br>អ. terabyte<br>បារ. téraoctet (m.) | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រដែលស្មើនឹង ១ 0២៤ ជីហ្គាបៃ ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១តេរ៉ាបៃស្មើនឹង ១ 000 ជីហ្គាបៃ ហើយ អក្សរកាត់ គឺ TB ។ |

| | |
|---|---|
| **២៨- ផេថាបៃ**<br>អ. petabyte<br>បារ. … | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រដែលស្មើនឹង ១ ០២៤ ថេរ៉ាបៃ ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១ផេថាបៃស្មើនឹង ១ ០០០ ថេរ៉ាបៃ ហើយ អក្សរកាត់គឺ PB ។ |
| **២៩- អ៊ិចសាបៃ**<br>អ. exabyte<br>បារ. ... | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ ០២៤ ផេថាបៃ ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១អ៊ិចសាបៃស្មើនឹង ១ ០០០ ផេថាបៃ ហើយ អក្សរកាត់គឺ EB ។ |
| **៣០- សិតាបៃ**<br>អ. zettabyte<br>បារ. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រដែលស្មើនឹង ១ ០២៤ អ៊ិចសាបៃ ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១សិតាបៃស្មើនឹង ១ ០០០ អ៊ិចសាបៃ ហើយ អក្សរកាត់ គឺ ZB ។ |
| **៣១- យុតាបៃ**<br>អ. yottabyte<br>បារ. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រដែលស្មើនឹង ១ ០២៤ សិតាបៃ ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១យុតាបៃស្មើនឹង ១ ០០០ សិតាបៃ ហើយ អក្សរកាត់គឺ YB ។ |
| **៣២- អនុគមន៍**<br>អ. function/routine/ procedure/subroutine/ subprogram<br>បារ. fonction (f.) / procédure (f.) | ១-ប្រមាណវិធីនៃកុំព្យូទ័រ ដែលបានរក្សាទុកក្រោមឈ្មោះមួយ ដើម្បីទទួលបានលទ្ធផលមួយ កាលណាគេហៅឈ្មោះនោះ ហើយ ឈ្មោះនេះផ្ទុកលទ្ធផល ដែលបានបង្កើត និង យកលទ្ធផលនេះមកប្រើប្រាស់តាមតម្រូវការ ។<br>(សម្រាប់ពាក្យ function/ routine)<br>២-ក្រុមសំណើក្រោមឈ្មោះមួយ ដែលអាចគណនានិងហៅមកប្រើ ហើយទទួលបានតម្លៃមួយត្រឡប់មកវិញ ហើយ ឈ្មោះនេះផ្ទុកលទ្ធផល ដែលបានបង្កើតនិងយកលទ្ធផលមកប្រើប្រាស់តាមតម្រូវការ ។ (សម្រាប់ពាក្យ Function/ Routine)<br>៣-សំណើឬសកម្មភាពនៃភាសាសរសេរកម្មវិធី ដែលបង្កើតឡើងដើម្បីសម្រេចកិច្ចការប្រមាណវិធី...គោលដៅមួយឬច្រើន ។ |
| **៣៣- ឧបទស្សន៍ /ម៉ូនីទ័រ**<br>អ. monitor<br>បារ. .... | ឧបករណ៍សម្រាប់បង្ហាញអក្សរឬរូបភាពពីកុំព្យូទ័រ ។<br>ឧ. ឧបទស្សន៍កុំព្យូទ័រ ។ |
| **៣៤- អេក្រង់**<br>អ. screen<br>បារ. écran (m.) | ផ្នែកមួយនៃឧបទស្សន៍ឬឧបករណ៍ដែលភ្ជាប់ទៅនឹងកុំព្យូទ័រសម្រាប់បង្ហាញព័ត៌មាន ។ |
| **៣៥- ឆ្នុច/...**<br>អ. key<br>បារ. ... | គ្រាប់មួយៗនៅលើក្ដារចុច ។ |

| | |
|---|---|
| **៣៦- ក្ដារចុច/ឃីប៊ត**<br>អ. keyboard<br>បារ. clavier (m.) | ឧបករណ៍ ដែលកើតចេញពីបណ្ដុំឆ្នុចរបស់ឧបករណ៍ភ្លេង អង្គុលីលេខ ឬ កុំព្យូទ័រ ដែលអ្នកប្រើប្រាស់បញ្ជាឬចុច ។ |
| **៣៧- កណ្ដុរ**<br>អ. mouse<br>បារ. ... | ឧបករណ៍តូចមួយដែលចល័តលើផ្ទៃរាបដើម្បីត្រួតពិនិត្យទីតាំងនៃសញ្ញាចង្អុលនៅលើអេក្រង់ ។ |
| **៣៨- សញ្ញាចង្អុល**<br>អ. pointer<br>បារ. ... | សញ្ញានៅលើអេក្រង់កុំព្យូទ័រ ជាទូទៅមានរាងដូចជាក្បាលព្រួញ ដែលគ្រប់គ្រងដំណើរការដោយកណ្ដុរ ។ |
| **៣៩- ទិន្នន័យ**<br>អ. data,<br>បារ. ... | - ព័ត៌មានដែលប្រមូលបានសម្រាប់ធ្វើការពិនិត្យពិចារណា និង ត្រូវបានប្រើសម្រាប់ធ្វើការសម្រេច ។<br>- បណ្ដុំ អក្សរ លេខ និមិត្តសញ្ញា រូបភាព សំឡេង ដែលប្រើដោយកុំព្យូទ័រ ។ |
| **៤០- ដ្រាយ**<br>អ. drive<br>បារ. unité de disques | ឧបករណ៍មេកានិកម៉្យាងសម្រាប់បង្វិលថាសឬកាសែ្សត ដើម្បីទាញទិន្នន័យយកទៅប្រើប្រាស់ ។ |
| **៤១- ក្ដារ / ប៊ត**<br>អ. board | បន្ទះរូបធាតុមិនចម្លងអគ្គិសនីមួយដែលផ្ទុកសៀគ្វីនៅផ្នែកម្ខាងឬផ្នែកទាំងសងខាង ។ |
| **៤២- មូលទិន្នន័យ**<br>អ. database,<br>បារ. base de données | បណ្ដុំនៃទំនាក់ទំនងទិន្នន័យឬព័ត៌មានដែលរក្សាទុកក្នុងកុំព្យូទ័រតាមវិធីណាមួយ ដោយក្នុងនោះ គេអាចងាយស្រួលមើល បន្ថែម ស្វែងរក ឬ ផ្លាស់ប្ដូរ ។ |
| **៤៣- អ៊ីមែល**<br>អ. mail / e-mail<br>បារ. courrier électronique (m.) | ១- សារជាឯកសារ អក្សរ រូបភាព សំឡេង វីដេអូ ដែលត្រូវបញ្ជូនតាមរយៈបណ្ដាញអេឡិចត្រូនិកនានា ។<br>២- មធ្យោបាយបញ្ជូនឬទទួលទិន្នន័យ អក្សរ រូបភាព សំឡេង វីដេអូ ពីកុំព្យូទ័រមួយទៅកុំព្យូទ័រមួយទៀតលើបណ្ដាញ ។ |
| **៤៤- អាសយដ្ឋានអ៊ីមែល**<br>អ. e-mail address<br>បារ ... | អាសយដ្ឋាន ដែលសម្គាល់ឱ្យអ៊ីមែល ។ |
| **៤៥- ប្រអប់អ៊ីមែល**<br>អ. mailbox<br>បារ ... | ប្រអប់សម្រាប់ផ្ទុកអ៊ីមែល ។ |

| | |
|---|---|
| **៤៦- ហាដវែរ**<br>អ. hardware<br>បារ. | សមាសធាតុអេឡិចត្រូនិកនិងមេកានិករបស់កុំព្យូទ័រ ។ |
| **៤៧- សុសវែរ**<br>អ. software<br>បារ. | បណ្ដុំឃ្លាបញ្ជាដែលធ្វើឱ្យហាដវែរកុំព្យូទ័រដំណើរការត្រួតពិនិត្យមុខងាររបស់ហាដវែរនោះ ត្រួតពិនិត្យអ្វីដែលកុំព្យូទ័រធ្វើការនិងអាចប្រើប្រាស់វា ដើម្បីធ្វើកិច្ចការឬការងារផ្សេងៗ ។ |
| **៤៨- ក្ដារមេ / មេប៊ត**<br>អ. motherboard/ fatherboard/mainboard<br>បារ. | បន្ទះដ៏សំខាន់នៃកុំព្យូទ័រដែលជាកន្លែងផ្ទុកខួរក្បាលកុំព្យូទ័រ កាតមេម៉ូរីផ្សេងៗ ឈីបសំខាន់ៗ និង ឧបករណ៍អេឡិចត្រូនិក ដែលផ្ដល់មុខងារដល់កុំព្យូទ័រ ។ |
| **៤៩- គីឡូប៊ីត**<br>អ. kilobit<br>បា. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ ០២៤ ប៊ីត ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១គីឡូប៊ីតស្មើនឹង ១ 000 ប៊ីត ហើយអក្សរកាត់ គឺ Kb ឬ Kbit ។ |
| **៥០- មេហ្គាប៊ីត**<br>អ. megabit<br>បា. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រដែលស្មើនឹង ១ ០២៤ គីឡូប៊ីត ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១មេហ្គាប៊ីតស្មើនឹង ១ 000 គីឡូប៊ីត ហើយ អក្សរកាត់ គឺ Mb ឬ Mbit ។ |
| **៥១- ជីហ្គាប៊ីត**<br>អ. gigabit<br>បា. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ ០២៤ មេហ្គាប៊ីត ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១ជីហ្គាប៊ីតស្មើនឹង ១ 000 មេហ្គាប៊ីត ហើយ អក្សរកាត់ គឺ Gb ឬ Gbit ។ |
| **៥២- តេរ៉ាប៊ីត**<br>អ. terabit<br>បា. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រដែលស្មើនឹង ១ ០២៤ ជីហ្គាប៊ីត ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១តេរ៉ាប៊ីតស្មើនឹង ១ 000 ជីហ្គាប៊ីត ហើយ អក្សរកាត់គឺ Tb ឬ Tbit ។ |
| **៥៣- ផេថាប៊ីត**<br>អ. petabit<br>បា. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ ០២៤ តេរ៉ាប៊ីត ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១ផេថាប៊ីតស្មើនឹង ១ 000 តេរ៉ាប៊ីត ហើយអក្សរកាត់ គឺ Pb ឬ Pbit ។ |
| **៥៤- អ៊ិចសាប៊ីត**<br>អ. exabit<br>បា. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ ០២៤ ផេថាប៊ីត ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១អ៊ិចសាប៊ីតស្មើនឹង ១ 000 ផេថាប៊ីត ហើយ អក្សរកាត់ គឺ Eb ឬ Ebit ។ |
| **៥៥- សិត្តាប៊ីត**<br>អ. zettabit<br>បា. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ ០២៤ អ៊ិចសាប៊ីត ។ ជាទូទៅ ក្នុងការនិយាយ គេកំណត់យក១សិត្តាប៊ីតស្មើនឹង ១ 000 អ៊ិចសាប៊ីត ហើយ អក្សរកាត់គឺ Zb ឬ Zbit ។ |

| | |
|---|---|
| **៥៦- យុត្តាប៊ីត**<br>អ. yottabit<br>បា. | ខ្នាតនៃបន្ទុកព័ត៌មានឬទិន្នន័យកុំព្យូទ័រ ដែលស្មើនឹង ១ ០២៤ សិត្តាប៊ីត ។ ជាទូទៅក្នុងការនិយាយ គេកំណត់យក១យុត្តាប៊ីតស្មើនឹង ១ ០០០ សិត្តាប៊ីត ហើយ អក្សរកាត់គឺ Yb ឬ Ybit ។ |
| **៥៧- កម្មវិធី**<br>អ. application / application software / program,<br>បារ. application (f.) / programme (m.) | សុសវែរសម្រាប់បញ្ជាកុំព្យូទ័របំពេញការងារ ដូចជា កម្មវិធីវាយអត្ថបទ កម្មវិធីគូរប្លង់ កម្មវិធីគ្រប់គ្រងទិន្នន័យ ។ល ។ |
| **៥៨- វិធីសាស្ត្រ/អាល់ហ្គោរីត**<br>អ. algorithm<br>បារ. algorithme (m.) | បណ្ដាកម្មវិធីនិងគោលការណ៍ ដែលប្រើដើម្បីអនុវត្តឬដោះស្រាយសកម្មភាពឬបញ្ហាណាមួយ ។ |
| **៥៩- វេប**<br>អ. web/w3/www world wide web<br>បារ. | សេវា ប្រព័ន្ធ ឬ បណ្ដាញឯកសារព័ត៌មាន ដែលគេអាចស្វែងរកបាននៅលើបណ្ដាញកុំព្យូទ័រ ឬ អ៊ីនធឺណិត តាមរយៈការប្រើ HTTP, WAIS, FTP, Telnet ។ល ។ ឬ បណ្ដាញកុំព្យូទ័រដែលកើតចេញពីបណ្ដុំអាសយដ្ឋាននៅលើអ៊ីនធឺណិតដែលផ្ដល់នូវប្រភពអត្ថបទ រូបភាព សំឡេង វីដេអូ តាមរយៈការប្រើ HTTP ។ |
| **៦០- ទំព័រវេប**<br>អ. web page/ webpage/ web-page | ប្រភពឬទំព័រព័ត៌មាន ( ដូចជា អក្សរ រូបភាព សំឡេង វីដេអូ) នៅលើកុំព្យូទ័រ បណ្ដាញកុំព្យូទ័រ ឬ អ៊ីនធឺណិតស្ដីពីប្រធានបទពិសេសណាមួយ និង អាចមើលឬទិញទំនិញផ្សេងៗតាមរយៈវេប ។ |
| **៦១- អាសយដ្ឋានវេប/វេបសាយ**<br>អ. website/web site<br>បារ. | ការប្រមូលផ្ដុំ ទីតាំងប្រមូលផ្ដុំ ឬ កន្លែងប្រមូលផ្ដុំទំព័រវេបនៅលើបណ្ដាញកុំព្យូទ័រ ឬ អ៊ីនធឺណិត ដែលរក្សាទុកដោយអង្គការ ស្ថាប័នរដ្ឋ ឯកជន ឬ បុគ្គលម្នាក់ៗ ។<br>បញ្ជាក់ : ទីតាំង ឬ កន្លែងនៅទីនេះគឺជាកុំព្យូទ័រ ។<br>ឧ. http://www.rac-academy.edu.kh ជាអាសយដ្ឋានវេប/វេបសាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ។ |
| **៦២- គេហទំព័រ**<br>អ. homepage, home page | ទំព័រដំបូង ដែលគេឃើញនៅពេលបើកមើលអាសយដ្ឋានវេប ។ |
| **៦៣- យូអរិល**<br>អ. URL / uniform resource locator<br>បារ. .... | អាសយដ្ឋានធនធាន ឯកសារ កម្មវិធី ឬ ទំព័រវេប នៅលើបណ្ដាញកុំព្យូទ័រ ឬ អ៊ីនធឺណិត ។ ឧទាហរណ៍ :<br>http://www.rac-academy.edu.kh,<br>http: //www. cambodia.gov.kh,<br>http://www.google.com,<br>ftp:// info. apple.com,<br>http://www. sharpened. net/glossary/ definition.php?url,<br>http://www.webopedia.com/TERM/U/url. html,<br>ហៅថា យូអរិល ។ |

| | |
|---|---|
| **៦៤- កូដ**<br>អ. code<br>បារ. code (m.) | ប្រព័ន្ធពាក្យ លេខ សញ្ញា អក្សរ ទាំងសម្ងាត់ ទាំងចំហ ដែលគេប្រើសម្រាប់តាងឱ្យសារឬពាក្យគន្លឹះអ្វីមួយក្នុងទម្រង់ខ្លីសមស្រប ។ |
| **៦៥-** កូដនីយកម្ម<br>អ. encryption<br>បារ. ... | ការបំប្លែងព័ត៌មានឬទិន្នន័យទៅជាកូដពិសេសណាមួយ ដែលគេមិនអាចយល់ឬប្រើប្រាស់បាន ។ |
| **៦៦-** កូឌិក<br>អ. codec: coder-decoder<br>បារ. .... | គ្រឿងអេឡិចត្រូនិកមួយដែលបំប្លែងឬបង្រួមសញ្ញានៃសំឡេងឬរូបភាពឱ្យតូចមុននឹងបញ្ជូនតាមប្រព័ន្ធទូរគមនាគមន៍ ។ សញ្ញាទាំងនេះត្រូវបានពន្លាមកទ្រង់ទ្រាយដើមវិញនៅឯឧបករណ៍ទទួល ។ |

## បច្ចេកសព្ទរបស់គណៈកម្មការជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម
## ដែល គ.ជ.ភ.ខ. បានអនុម័ត

| | |
|---|---|
| ១- ក្រិស (ជំងឺ)<br>អ. rachitism<br>បារ. rachitisme (m.) | ជំងឺបណ្ដាលមកពីឆ្អឹងមិនលូតលាស់ទៅតាមដំណាក់នៃសរីរាង្គមនុស្សនិងសត្វ ដែលបណ្ដាលមកពីកត្តាផ្សេងៗជាច្រើនពិសេសកង្វះវីតាមីនឬជីវជាតិដេ(D)។<br>ឧ. ការឱ្យទារកឬសត្វទទួលបានពន្លឺព្រះអាទិត្យនៅពេលព្រឹកព្រលឹម អាចជួយកាត់បន្ថយជំងឺក្រិស។ |
| ២- ជំងឺរលាកសន្លាក់<br>អ. arthritis<br>បារ. arthrite (f.) | ជំងឺរលាកនៅត្រង់សន្លាក់បណ្ដាលឱ្យឡើងក្រហម ក្ដៅ ឈឺចាប់ និង ហើម ដែលមានលក្ខណៈស្រួចស្រាល់ឬរ៉ាំរ៉ៃ។<br>ឧ. អ្នកជំងឺរលាកសន្លាក់គប្បីទៅពិនិត្យព្យាបាល តាមការណែនាំរបស់គ្រូពេទ្យឯកទេស។ |
| ៣- ជំងឺរលាកទឹកសន្លាក់ / ស៊ីណូវីត<br>អ. synovitis<br>បារ. synovite (f.) | ជំងឺរលាកទឹកសន្លាក់មានសភាពស្រួចស្រាល់ឬរ៉ាំរ៉ៃដែលធ្វើឱ្យស្ងួតឬមានសារធាតុរាវមិនប្រក្រតី ដូចជា ឈាម ទឹករងៃ ឬ អាចមានឧស្ម័ន។<br>ឧ. បើអ្នកជំងឺសង្ស័យថាខ្លួនមានជំងឺរលាកទឹកសន្លាក់ ត្រូវទៅពិគ្រោះជាមួយនឹងគ្រូពេទ្យឯកទេស ចៀសវាងការប្រើថ្នាំដោយខ្លួនឯង។ |
| ៤- ជំងឺរលាកមាត់<br>អ. stomatitis<br>បារ. stomatite (f.) | ជំងឺរលាកភ្នាសសើមមាត់បង្កដោយបាក់តេរី វីរុស ពពួកផ្សិត,...។<br>ឧ. កង្វះអនាម័យមាត់ធ្មេញជាកត្តាបណ្ដាលឱ្យកើតជំងឺរលាកមាត់។ |
| ៥- ជំងឺរលាកសរសៃពួរសាច់ដុំ / ជំងឺរលាកតង់ដុង<br>អ. tendinitis<br>បារ. tendinite/ténosite (f.) | ជំងឺបណ្ដាលមកពីរលាកបណ្ដុំសរសៃពួរដែលភ្ជាប់សាច់ដុំទៅនឹងឆ្អឹង។ |

| | |
|---|---|
| ៦- ជំងឺក្រិន<br>អ. sclerosis<br>បារ. sclérose (f.) | សភាពរឹងឬក្រាស់នៃជាលិកាឬសរីរាង្គណាមួយដែលបណ្ដាលឱ្យបាត់បង់មុខងាររបស់វា។<br>ឧ. ការពិសាស្រាជាកត្តាមួយជំរុញឱ្យជំងឺរលាកថ្លើមវិវត្តទៅជាជំងឺក្រិនថ្លើម។ |
| ៧- ជំងឺក្រិនថ្លើម (សៀរ៉ូសថ្លើម)<br>អ. cirrhosis<br>បារ. cirrhose du foie /<br>cirrhose hépatique (f.) | ជំងឺថ្លើមម្យ៉ាងបណ្ដាលមកពីការរលាកកោសិកា(Cellule) ថ្លើម ធ្វើឱ្យជាលិកា (Tissu) ថ្លើមរឹង ក្រិន លែងបំពេញមុខងារបាន។<br>ឧ. ការព្យាបាលជំងឺរលាកថ្លើមទាន់ពេលវេលា អាចទប់ស្កាត់ការវិវត្តទៅជាជំងឺក្រិនថ្លើមបាន។ |
| ៨- ទុរាហារូបត្ថម្ភ<br>អ. malnutrition<br>បារ. malnutrition (f.) | អាការៈកើតឡើងចំពោះមនុស្សឬសត្វនៅពេលទទួលអាហារមិនត្រឹមត្រូវតាមនិយាមនៃតម្រូវការ។<br>ឧ. មនុស្សឬសត្វត្រូវទទួលអាហារឱ្យបានគ្រប់គ្រាន់ ដូចជា ៖ ប្រូទីដ លីពីដ គ្លុយស៊ីដ ជីវជាតិ (vitamine) និង សារជាតុរ៉ែខនិជ... ដើម្បីជៀសវាងទុរាហារូបត្ថម្ភ ។ |
| ៩- និស្សារណកម្ម / ដំណក ន.<br>អ. extraction<br>បារ. extraction (f.) | ដំណើរការដកយកប្រជាតុចេញពីវត្ថុអ្វីមួយ។<br>ឧ. និស្សារណកម្មគ្រាប់ល្ហុងខ្វងបានជារូបជាតុប្រេងល្ហុងខ្វង (huile de ricin)។ |
| ១០- និស្សារណ៍ / ត្រណក<br>អ. extract<br>បារ. extrait (m.) | រូបជាតុដែលបានមកពីការដកចេញពីវត្ថុអ្វីមួយ។<br>ឧ. និស្សារណ៍ម្រះព្រៅបានមកពីការចម្រាញ់ចេញពីដើមម្រះព្រៅភ្នំ។ |
| ១១- ឧស្សាហនិស្សារណកម្ម<br>អ. industrial extraction<br>បារ. extraction industrielle (f.) | ដំណើរការដកយកប្រជាតុចេញពីវត្ថុអ្វីមួយជាលក្ខណៈឧស្សាហកម្ម។<br>ឧ. ខេត្តកោះកុងនាពេលបច្ចុប្បន្ននេះមានឧស្សាហនិស្សារណកម្មស្ករ-ស ពីដើមអំពៅ។ |
| ១២- វិយាហារូបត្ថម្ភ<br>អ.<br>បារ. dénutrition (f.) | ភាពទទួលជាតិអាហារជ្រួតជ្រាបតិចជាងជាតិអាហារដែលបញ្ចេញចោល។ |
| ១៣- ឧនារូបត្ថម្ភ/កង្វះអាហារូបត្ថម្ភ<br>អ.<br>បារ. sous alimentation /<br>sous-mutrition (f.) | ភាពទទួលអាហារមិនគ្រប់គ្រាន់(របបប៉ុល ពត)។ |
| ១៤- កោសិកា<br>អ. cell<br>បារ. cellule (f.) | ឯកតាទម្រង់គ្រឹះនៃជីវិតដែលជាផ្នែកតូចបំផុតរបស់ភាវៈរស់ ហើយ ដែលអាចដំណើរជីវិតបានដោយខ្លួនឯង។ ជាតុផ្សំនៃកោសិកាមាន ស៊ីតូប្លាស ណ្វៃយ៉ូ (ជាពិសេស)...។ |
| ១៥- ជាលិកា<br>អ. tissue<br>បារ. tissu (m.) | សំណុំកោសិកាដែលមានទម្រង់រចនាសម្ព័ន្ធនិងមុខងារដូចគ្នា បង្កើតបានជាសរីរាង្គមួយឬផ្នែកមួយនៃសរីរាង្គ។ |

| | |
|---|---|
| ១៦- លីពីដ<br>អ. lipid<br>បារ. lipide (m.) | សារធាតុប្រេង ខ្លាញ់ ដែលមិនរលាយក្នុងទឹក តែរលាយក្នុងធាតុរំលាយសរីរាង្គ (solvant organique) ហើយដែលមានម៉ូលេគុលអាស៊ីដប្រេង ខ្លាញ់ (acide gras)។ |
| ១៧- ប្រូទីដ<br>អ. protid<br>បារ. protide (m.) | សារធាតុផ្សំឡើងដោយកាបោន អ៊ីដ្រូហ្សែន អុកស៊ីហ្សែន និង អាសូត ដែលឯកតាដំបូង គឺជាអាស៊ីដអាមីណេ (acide aminé) ជាច្រើន តភ្ជាប់គ្នាដោយសម្ព័ន្ធប៉ិបទីដ។<br>ឧ. សារធាតុប្រូទីដមានច្រើននៅក្នុងគ្រាប់ធញ្ញជាតិ ជាពិសេសគ្រាប់សណ្តែកសៀង ក្នុងសាច់សត្វ ក្នុងបន្លែ...។ |
| ១៨- គ្លុយស៊ីដ<br>អ. glucid<br>បារ. glucide (m.) | សារធាតុស្ករ ជាកាបោនអ៊ីដ្រាត (hydrate de carbone) ដែលក្នុងនោះមានស្ករទោល (ose = sucre simple) និង ស្ករកុំផ្លិច (oside = sucre complexe)។ |
| ១៩- ភាពស៊ាំ<br>អ. immunity<br>បារ. immunité (f.) | ដំណើរនៃសរីរាង្គដែលអាចទប់ស្កាត់មិនឱ្យឆ្លងជំងឺពីខាងក្រៅដែលបង្កឡើងដោយភ្នាក់ងារបង្កជំងឺណាមួយ។<br>ឧ. ការចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ(B) បង្កឱ្យមានភាពស៊ាំនឹងជំងឺនេះបាន។ |
| ២០- អង់ទីករ / អង្គបដិបក្ខ<br>អ. antibody<br>បារ. anticorps (m.) | សារធាតុប្រូតេអ៊ីនដែលផលិតដោយសរីរាង្គ ដើម្បីប្រឆាំងនឹងជំងឺទៅតាមប្រភេទពិសេសរបស់វា។<br>ឧ. ក្រោយពីចាក់វ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹល កុមារនឹងមានអង់ទីករទប់ទល់ទៅនឹងជំងឺកញ្ជ្រឹលបាន។ |
| ២១- តុកស៊ីកូវិទ្យា / វិសវិទ្យា<br>អ. toxicology<br>បារ. toxicologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីជាតុពុល។<br>ឧ. តុកស៊ីកូវិទ្យា / វិសវិទ្យាជាមុខវិជ្ជាមួយនៅក្នុងកម្មវិធីសិក្សា ផ្នែកវេជ្ជសាស្ត្រ។ |
| ២២- តុកស៊ីន / វិសជាតុ<br>អ. toxin<br>បារ. toxine (f.) | សារធាតុដែលកកើតឡើងពីមីក្រូសារពាង្គកាយ ហើយ បណ្តាលឱ្យមានជំងឺ។ តុកស៊ីនមានដើមកំណើតចេញពីប្រភពពីរ :<br>- ចេញពីជីវាណូ-ខ្មៅមេរោគមួយ (un germe) ដែលបង្កឱ្យមានជំងឺ។<br>- ចេញពីពួកផ្សិតពុលឬពីពិសរបស់សត្វល្អិតនិងសត្វពស់ ដែលមិនមែនជាមីក្រុប ។ |
| ២៣- អង់ទីតុកស៊ីន / បដិវិសជាតុ<br>អ. antitoxin<br>បារ. antitoxine (f.) | សារធាតុដែលអាចបន្សាបសកម្មភាពពុលរបស់តុកស៊ីន។ |
| ២៤- វ៉ាក់សាំង<br>អ. vaccine<br>បារ. vaccin (m.) | សារធាតុដែលចាក់បញ្ចូលទៅក្នុងសរីរាង្គកាយមនុស្សឬសត្វ បង្កបង្កើតបានជាអង់ទីករ អាចទប់ទល់បង្ការឬបង្កើតភាពស៊ាំនឹងជំងឺណាមួយ។<br>ឧ. ក្រសួងសុខាភិបាលមានកម្មវិធីជាតិចាក់វ៉ាក់សាំងដល់ទារកដែលទើបនឹងកើត។ |
| ២៥- ទឹកកាម<br>អ. sperm/semen<br>បារ. sperme (m.) | សារធាតុខាប់ពណ៌សដែលផលិតចេញពីសរីរាង្គបន្តពូជរបស់មនុស្សប្រុសឬសត្វឈ្មោល។ សារធាតុនេះមានសេរ៉ូម ប្លាស្មា និង ស្ពែម៉ាតូសូអ៊ីត។ |

| | |
|---|---|
| ២៦- ពងស្វាស<br>អ. testes/testicle/testis<br>បារ. testicule (m.) | ក្រពេញភេទរបស់មនុស្សប្រុសឬសត្វឈ្មោល។ នៅពេលពេញវ័យ ក្រពេញភេទនេះអាចផលិតស្ពែម៉ាតូសូអ៊ីតនិងអ័រម៉ូនតេស្តូស្តេរ៉ូន(អង់ដ្រូហ្សែន)។<br>ឧ. ការចេងបំពង់ទឹកកាមដែលចេញពីពងស្វាសជាវិធីពន្យារកំណើតមួយបែប។ |
| ២៧- អូវុល<br>អ. ovule<br>បារ. ovule (m.) | កោសិកាបន្តពូជញីដែលផលិតចេញពីសរីរាង្គបន្តពូជ(អូវែ)របស់មនុស្សស្រី សត្វញីឬរុក្ខជាតិញី។<br>ឧ. ការបង្កកំណើតរបស់មនុស្ស សត្វ ឬ រុក្ខជាតិ កើតឡើងដោយការរួមផ្សំរវាងស្ពែម៉ាតូសូអ៊ីតឬអង់តេរ៉ូសូអ៊ីតនិងអូវុល។ |
| ២៨- អូវែ<br>អ. ovary<br>បារ. ovaire (m.) | ក្រពេញភេទរបស់មនុស្សស្រី សត្វញីឬរុក្ខជាតិញី។ នៅពេលពេញវ័យ ក្រពេញភេទនេះអាចផលិតអូវុលនិងអ័រម៉ូន អឺស្ត្រូហ្សែននិងប្រូហ្សេសស្តេរ៉ូន។<br>ឧ. អូវែរបស់មនុស្សស្រីចាប់ផ្ដើមបញ្ចេញអូវុលនៅពេលស្ត្រីពេញវ័យ។ |
| ២៩- ទឹកដោះដំបូង<br>អ. colostrum/neogala/protogala<br>បារ. colostrum (m.) | ទឹកដោះចេញក្រោយពីការសម្រាលកូនរួចរយៈពេលតែពីរឬបីថ្ងៃប៉ុណ្ណោះចំពោះមនុស្ស តែចំពោះសត្វ រយៈពេលអាចខ្លីឬវែងជាងនេះ។ ទឹកដោះនេះមានពណ៌លឿង ដែលសម្បូរដោយសារជាតិប្រូតេអ៊ីន ជាពិសេស អាល់ប៊ុយមីនដែលមានតួនាទីទប់ស្កាត់ជំងឺរលាកក្រពះ ពោះវៀន បន្សាត់អាចម៍ព្រៃ និងនាំអង់ទីករពីម្ដាយទៅកូន។<br>ឧ. ម្ដាយក្រោយពីការសម្រាលកូនចាំបាច់ត្រូវបំបៅកូនភ្លាមដោយទឹកដោះដំបូង។ |
| ៣០- ខ្ញី<br>អ. ginger<br>បារ. gingembre (m.)<br>ឡា. zingiber officinale | តិណជាតិប្រើជាគ្រឿងទេសមានរសជាតិហឹរនិងមានក្លិន ពិសេស ដុះនៅតំបន់ក្ដៅ។ មើមវាគេប្រើធ្វើជាម្ហូប បង្អែម តំណាប់ផ្សេងៗ និង ជារុក្ខជាតិឱសថ ព្រម-ទាំងជារូបជាតុដើមឱសថផងដែរ។<br>ឧ. ដំណាំខ្ញីមានផលប្រយោជន៍ក្នុងផ្នែកឱសថសាស្ត្រ និង ជាគ្រឿងទេសដ៏ល្អប្រសើរ។ វាអាចជួយដើរខ្យល់ ធ្លាក់ ហើមពោះ ជួយរំលាយអាហារ តឹងច្រមុះ ឈឺបំពង់ក ជាដើម។ |
| ៣១- រមៀត / ល្មៀត<br>អ. turmeric<br>បារ. curcuma/safran des indes m.<br>ឡា. curcuma domestica / curcuma longa | តិណជាតិមានមើមពណ៌លឿងមានក្លិនប្រហើរ ប្រើជាគ្រឿងទេស ជាឱសថ ជាគ្រឿងសម្អាងកាយ និង ជាពណ៌ជ្រលក់ផងដែរ។<br>ឧ.នារីខ្មែរនិយមយកល្មៀតលាបមុខនិងដងខ្លួន ដើម្បីឱ្យស្បែកមានសម្រស់ល្អ។ រមៀតអាចជួយព្យាបាលជំងឺសើស្បែក រលាកក្រពះ ពោះវៀន សម្រួលការរំលាយអាហារនិងជំរុញការបញ្ចេញទឹកប្រមាត់ជាដើម ។ |
| ៣២- រំដេង<br>អ. galangal<br>បារ. galanga (m.)<br>ឡា. alpinia galanga | តិណជាតិមានមើមពណ៌លឿងខ្ចីប្រើជាគ្រឿងទេសមានក្លិនហឹរឆួលប្រើជាគ្រឿង-ទេស និង ជាឱសថ។<br>ឧ. ជនជាតិខ្មែរប្រើរំដេងសម្រាប់បង់សម្លដើម្បីកាត់ចម្អាបនិងបង្កើនរសជាតិ។ មើមហាលឱ្យស្ងួត កិនជាម្សៅមានប្រសិទ្ធភាពជួយរំលាយអាហារ ព្យាបាលរោគ ហើមពោះ ផ្ដាសាយ ឈឺធ្មេញ ចុកធ្លល់ពោះ។ |
| ៣៣- ខ្ចាយ<br>អ. lesser ginger | តិណជាតិប្រើជាគ្រឿងទេស មើមពណ៌លឿងខ្ចីមានក្លិនប្រហើរ។ មើម ស្លឹកគេប្រើជាគ្រឿងផ្សំក្នុងម្ហូបនិងប្រើជាឱសថ។ |

| | |
|---|---|
| បារ. petits doigts (m.)<br>ឡា. boesenbergia rotunda<br>kaempferia pandurata | ឱ.គេយកមើមខ្ចាយធ្វើជាគ្រឿងផ្សំក្នុងសម្លប្រហើរ។ វាអាចជួយបន្ថយការឈឺមាត់ ឈឺបំពង់ក។ |
| ៣៤- ពន្លៃ<br>អ. cassumar ginger<br>បារ. gingembre cassumunar<br>ឡា. zingiber purpureum /<br>zingiber cassumunar | តិណជាតិមានមើមពណ៌លឿងខ្ចីមានក្លិនប្រហើរ។ គេច្រើនដាំជិតផ្ទះសម្រាប់ប្រើជាឱសថ។<br>ឱ. នៅតាមជនបទគេនៅនិយមបុកស្លឹកឬមើមពន្លៃសម្រាប់បិទលើបង្កើយកូនខ្ចី។ ម្យ៉ាងទៀត គេបុកមើមពន្លៃត្រាំក្នុងស្រា សម្រាប់លាបឬបំពោកលើសន្លាក់ឆ្អឹងឬកន្លែងជាំសាច់ដោយសារការប៉ះទង្គិច។ តាមទម្លាប់ គេប្រើថៃរក្សាស្បែក និង មើមបុកជាម្សៅអាចប្រើជាថ្នាំទម្លាក់ព្រូននិងអៀន។ |
| ៣៥- គូឆាយ<br>អ. chinese chives<br>បារ. ciboule de chine (f.)<br>ឡា. allium odorum /<br>allium tuberosum | តិណជាតិអម្បូរខ្ទឹមមានប្រភពដុះនៅតំបន់អាស៊ី។ ស្លឹកគេប្រើធ្វើជា ម្ហូប បន្លែ និង នំ។ ស្លឹកនិងគ្រាប់វា គេអាចយកទៅប្រើជាឱសថ។<br>ឱ. ស្លឹកនិងគល់គូឆាយគេនិយមប្រើជាម្ហូបអាហារសម្រាប់ឱ្យដើរខ្យល់ អាចជួយសម្រួលផ្លូវដង្ហើមសម្រួលការរំលាយអាហារ និង ព្យាបាលការហើមពោះ។ គ្រាប់ហាលឱ្យស្ងួត កិនផឹកបំបាត់ជំងឺហូរទឹកកាម។<br>- អ្នកខ្លះហៅ ‹‹ ជីឆាយ ឬ ស្លឹកឆាយ ឬ កាឆាយ ›› |
| ៣៦- ខ្ទឹមស<br>អ. garlic<br>បារ. ail (m.)<br>ឡា. allium sativum | តិណជាតិអម្បូរខ្ទឹមមានប្រភពដុះនៅតំបន់អាស៊ី។ ស្លឹករាងសំប៉ែត ពណ៌បៃតង។ មើមផ្ដុំឡើងដោយកំពឹសពណ៌ស មានក្លិនឆួល ប្រើជាគ្រឿងទេសនិងជាឱសថ។<br>ឱ. ប្រជាជនខ្មែរនិយមប្រើខ្ទឹមស យកទៅបុកលាបឬបិទកន្លែង ដែលខ្ទួយទិច ឬក៏ក្អែបខាំ ហើយ វាអាចជួយបន្ថយសម្ពាធឈាម ក្រិនសសៃឈាម និង រំងាប់មេរោគតាមសសៃឈាម។ គេអាចប្រើវាទប់ទល់ផ្សែងនៃគ្រាប់បែកផ្សែង ដោយបុកឬបំបែក ហិត ឬ លាបភ្នែក កុំឱ្យចេញទឹកភ្នែក។ |
| ៣៧- ខ្ទឹមក្រហម<br>អ. shallot<br>បារ. échalote (f.)<br>ឡា. allium ascalonicum | តិណជាតិអម្បូរខ្ទឹមមានប្រភពដុះនៅតំបន់អាស៊ី។ ស្លឹកពណ៌បៃតង រាងជាបំពង់ស្រួចចុង ។ មើមផ្ដុំឡើងដោយកំពឹសពណ៌ក្រហមស្វាយឬមើមផ្ដុំឡើងជាស្រទាប់ មានក្លិនឆួលស្រាលជាងខ្ទឹមស ប្រើជាគ្រឿងទេស។<br>ឱ. ខ្ទឹមក្រហមស្រស់មានក្លិនឆួល ប៉ុន្តែ នៅពេលឆ្អិន មានរសជាតិឈ្ងុយឆ្ងាញ់។ |
| ៣៨- ខ្ទឹមបារាំង<br>អ. onion<br>បារ. oignon (m.)<br>ឡា. allium cepa | តិណជាតិអម្បូរខ្ទឹមមានប្រភពដុះនៅមជ្ឈិមបូព៌ាប្រទេសមានមើមរាងមូលធំជាងខ្ទឹមស ប្រើជាគ្រឿងទេសនិងឱសថ។<br>ឱ. ទឹកខ្មេះអាចបំបាត់ក្លិនឆួលរបស់មើមខ្ទឹមបារាំង នៅពេលគេហាន់វា ធ្វើជាម្ហូប។<br>- អ្នកស្រី ឌី ផុន ហៅ ‹‹ខ្ទឹមក្រហម››។ |
| ៣៩- ខ្ទឹមគល់/ស្រឹង<br>អ. leek<br>បារ. poireau (m.)<br>ឡា. allium porrum /<br>allium ampelopra sum | តិណជាតិអម្បូរខ្ទឹមមានគល់ពណ៌សវែងៗ ហើយ ស្លឹកពណ៌បៃតង រាងសំប៉ែតវៀវចុង។ គល់ប្រើជាបន្លែមានរសជាតិស្រដៀងខ្ទឹមបារាំង។<br>ឱ. គេនិយមយកខ្ទឹមគល់មកឆាជាមួយនឹងគ្រឿងក្នុងជ្រូកឬស្ងោរស៊ុប។ វាជួយរំលាយអាហារ។<br>អ្នកខ្លះប្រើ៖ ខ្ទឹមគល់ ស្រឹង ខ្ទឹមខ្យល់ ខ្ទឹមល័ក្ត។ |

| | |
|---|---|
| ៤០- ខ្ទឹមស្លឹក/ខ្ទឹមខ្យល់<br>អ. welsh onion<br>បារ. ciboule (f.)<br>ឡ. allium fistulosum | តិណជាតិអម្បូរខ្ទឹមមានគល់ពណ៌សរាងមូល ស្លឹកពណ៌បៃតង រាងជាបំពង់។ គេប្រើជាគ្រឿងទេសក្នុងម្ហូបអាហារ និង ប្រើជាឱសថ អាចជួយសម្រួលផ្លូវដង្ហើម ធ្វើឱ្យដើរខ្យល់និងសម្រួលសរសៃឈាម។<br>អ្នកស្រី ឌី ផុន ហៅ « ខ្ទឹមសន្លឹក ឬ ខ្ទឹមសណ្ដែក» |
| ៤១- ឃ្លោក<br>អ. gourd<br>បារ. courge (f.)<br>ឡ. lagenaria longissima | ប្រភេទលតាជាតិវារលើដីឬឡើងទ្រើងដុះនៅតំបន់ត្រូពិក។ ផ្លែរាងមូលទ្រវែងស្រដៀងនឹងផ្លែត្រឡាច។ ផ្លែខ្ចីប្រើជាបន្លែសម្បូរដោយជីវជាតិ។ គេអាចយកសាច់និងគ្រាប់ប្រើជាឱសថសម្រាប់ជួយរំលាយអាហារ។ |
| ៤២- ឃ្លោកសាជៀវ<br>អ. calabash<br>បារ. calebasse (f.)<br>ឡ. lagenaria siceraria | ប្រភេទឃ្លោកម្យ៉ាងរាងដូចក្អមមួយជាន់ឬពីរជាន់។ ផ្លែខ្ចីប្រើជាបន្លែ សំបកផ្លែទុំប្រើសម្រាប់ដាក់ទឹក ជាគ្រឿងលម្អនិងធ្វើស្នូកសាជៀវ។<br>អ្នកខ្លះហៅ ឃ្លោកពួង។ |
| ៤៣- ឃ្លោកដប<br>អ. bottle gourd<br>បារ. gourde /courge bouteille (f. ) | ប្រភេទឃ្លោកម្យ៉ាងរាងដូចដប។ ផ្លែខ្ចីប្រើជាបន្លែ។ សំបកផ្លែទុំប្រើសម្រាប់ដាក់ទឹក និង សម្ភារៈផ្សេងៗ។ |
| ៤៤- ត្រឡាច<br>អ. white gourd/wax gourd<br>បារ. courge cireuse (f.)<br>ឡ. benincasa hispida<br>benincasa cerifera | ប្រភេទលតាជាតិវារលើដីឬឡើងទ្រើងដុះនៅតំបន់ត្រូពិក។ សំបកផ្លែខ្ចីពណ៌បៃតងស្រាលនិងមានរោមឆ្មារៗ សំបកផ្លែចាស់ឡើងម្សៅពណ៌ស ។ ផ្លែខ្ចីប្រើជាបន្លែ ផ្លែចាស់ធ្វើនំនិងតំណាប់។ ម្យ៉ាងទៀត ឫស ផ្លែ និង គ្រាប់ ប្រើជាឱសថ។ |
| ៤៥- ត្រឡាចស្រូវ | ប្រភេទលតាជាតិវារលើដីមានផ្លែតូចជាងត្រឡាចធម្មតា។ គេនិយមដាំនៅរដូវសម្រក ចំពោះអ្នកចម្ការ និង អ្នកស្រែដាំនៅពេលច្រូតរួច។ ត្រឡាចនេះ គេប្រើតែផ្លែខ្ចីប៉ុណ្ណោះ សម្រាប់ធ្វើបន្លែ។<br>អ្នកខ្លះគេហៅ ត្រឡាចឃ្មើន។ |
| ៤៦- ននោងជ្រុង<br>អ. ridged gourd<br>បារ. papangay (f.)<br>ឡ. luffa acutangula | ដំណាំវល្លិវារឡើងទ្រើងមានប្រភពដុះនៅឥណ្ឌា។ ផ្លែរាងទ្រវែងមានជ្រុងច្រើនប្រើជាបន្លែបានច្រើនមុខ។ ស្លឹកនិងផ្លែននោងជ្រុង ប្រើជាឱសថ។ |
| ៤៧- ននោងមូល/ននោងសាញ<br>អ. sponge gourd<br>បារ. éponge végétale (f.)<br>ឡ. luffa cylindrica /<br>luffa aegyptiaca | ដំណាំវល្លិវារឡើងទ្រើង មានប្រភពដុះនៅតំបន់ត្រូពិក។ ផ្លែមូលទ្រវែង មានធ្នូតតាមបណ្ដោយផ្លែ។ ផ្លែខ្ចីប្រើជាបន្លែ ផ្លែទុំហាលឲ្យស្ងួតប្រើសម្រាប់ជូតផ្ទះ ដុសលាងសម្អាតសម្ភារៈប្រើប្រាស់ផ្សេងៗ។ ម្យ៉ាងទៀត ផ្លែ ស្លឹក ឫស ប្រើជាឱសថ។<br>អ្នកខ្លះហៅថា « ននោងប្រហើរ »។ |
| ៤៨- ននោងទេស/ននោងពស់<br>អ.<br>បារ.<br>ឡ. | ប្រភេទននោងម្យ៉ាង មានផ្កាពណ៌សខុសពីននោងផ្សេងទៀតដែលមានផ្កាពណ៌លឿង។ ផ្លែមានរាងមូលតូចវែងមានធ្នូតពណ៌សពព្លាក់តាមបណ្ដោយផ្លែ។ ននោងទាំងនេះគ្មានស្រកីដូចជាននោងជ្រុងនិងននោងមូលទេ។ ផ្លែប្រើជាអន្លក់និងបន្លែធ្វើជាសម្លបានច្រើនមុខ។ |

| | |
|---|---|
| ៤៩- ជីរនាងវង<br>អ. basil<br>បារ. basilic commun (m.)<br>ឡា. ocimum basilicum | តិណជាតិមួយប្រភេទ មានប្រភពដុះនៅតំបន់ក្តៅឬត្រជាក់មធ្យម។ ស្លឹកនិងត្រួយ ប្រើជាបន្លែឬអន្លក់ដែលផ្តល់ក្លិនប្រហើរ និង អាចបំបាត់ក្លិនឆ្អាប។ គ្រាប់ទុំអាចប្រើជាភេសជ្ជៈឬជាឱសថ។ |
| ៥០- ជីរណារ/ជីរបន្លា<br>អ. fitweed<br>បារ. panicaut (m.)<br>ឡា. eryngium foetidum | តិណជាតិមួយប្រភេទ មានប្រភពពីទ្វីបអាម៉េរិកនៃតំបន់អាកាសធាតុក្តៅ។ ស្លឹកមានរាងទ្រវែង រឹមស្លឹកមានរាងជាធ្មេញរណារដុះចេញពីគល់គ្មានមែក។ ស្លឹកប្រើជាបន្លែ គ្រឿងទេស និង ឱសថ។<br>អ្នកខ្លះហៅថា ‹‹ ជីរបារាំង ឬ ជីរស្លឹកវែង ឬក៏ ជីរក្រពើ ›› ។ |
| ៥១- ជីរអង្កាម<br>អ. mint<br>បារ. menthe (f.)<br>ឡា. mentha arvensis | តិណជាតិមានស្លឹករាងមូលជ្រួញៗ មានទងពណ៌ស្វាយនិងមានក្លិនប្រហើរឆ្ងួលតិចៗ។ ស្លឹកប្រើជាបន្លែនិងជាឱសថ។<br>ឱ. និស្សារណកម្មជីរអង្កាមផ្តល់នូវសារជាតិប្រេងម៉ង់ត៍ (menthe) និង ម៉ង់តូល (menthol )។<br>- អ្នកខ្លះហៅថា ‹‹ជីរសង្កើច››។ |
| ៥២- ជីរស្លឹកក្រាស់/ជីរត្រចៀកជ្រូក<br>អ. cuban oregano / coleus<br>បារ. coleus (m.)<br>ឡា. coleus amboinicus/ coleus aromaticus | តិណជាតិម្យ៉ាងមានស្លឹកមូលធំក្រាស់ រឹមស្លឹកមានរាងជាធ្មេញរណារ។ ដើមនិងស្លឹកមានរោមឆ្មារៗ គេប្រើជាគ្រឿងទេសនិងជាឱសថ។<br>អ្នកខ្លះហៅថា ‹‹ជីរក្រអូប ជីរត្រចៀកដំរី ជីរទ្រមឹង ជីរទ្រមាំង››។ |
| ៥៣- ជីរក្រសាំងទំហំ<br>អ. persicaria odorata<br>បារ. polygone odorante (f.)<br>ឡា. polygonum odoratum / persicaria odorata | តិណជាតិមួយប្រភេទមានប្រភពនៅប្រទេសកម្ពុជា វៀតណាម ឡាវ មានស្លឹកទ្រវែងវៀវស្រួចខាងចុង ផ្ទៃស្លឹកខាងលើពណ៌បៃតង ផ្ទៃស្លឹកខាងក្រោមពណ៌ក្រហមការ ឬ ក្រហមស្រាល។ ស្លឹកប្រើជាបន្លែ អន្លក់ ឬ បង់ក្នុងសម្ល។<br>- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ៖ ‹‹ជីរសាំងគ្រហ៊ុម››,<br>- អ្នកខ្លះហៅថា ‹‹ជីរប្រហើរ››។ |
| ៥៤- ជីរម្រះព្រៅ<br>បារ. basilic des moines (m.)<br>ឡា. ocimum tenuiflorum / ocimum sanctum | តិណជាតិមួយប្រភេទដុះនៅតំបន់ក្តៅ ដើមនិងស្លឹកតូចមានរោមឆ្មារៗ។ ស្លឹកមានក្លិនហាងប្រហើរឆ្ងួល ប្រើជាបន្លែ គ្រឿងទេស និង ជាឱសថ ។ |
| ៥៥- ជីរតាំងឱ<br>អ. celery<br>បារ. céleri doux (m.)<br>ឡា. apium graveolens | តិណជាតិមួយប្រភេទច្រើនដុះនៅតំបន់ក្តៅ ស្លឹកឆែកៗស្រដៀងនឹងស្លឹកស្ពៃ-រឿង។ គេប្រើជាបន្លែឬជាគ្រឿងទេស។<br>- អ្នកខ្លះហៅថា ‹‹តាំងឱ››។ |
| ៥៦- ជីរថ្ពាល់ត្រី<br>អ. chameleon plant<br>បារ. houttuynie (f.)<br>ឡា. houttuynia cordata | តិណជាតិស្មើរវារ មានកម្ពស់ពី១០-៣០សង់ទីម៉ែត្រ ដុះនៅតំបន់ត្រូពិក ដែលមានដីសើម។ ស្លឹករាងមូលស្រួចខាងចុងស្រដៀងនឹងស្លឹកពោធិ៍។ ស្លឹកប្រើជាបន្លែស្រស់ អន្លក់ ញាំភ្លា និង ជាឱសថ។<br>- អ្នកខ្លះហៅថា ‹‹ជីរយ៉ោបកា ឬ ជីរយួន››។ |
| ៥៧- ជីរលីងល័ខ<br>អ. sweet basil<br>បារ. basilic de ceylan (m.)<br>ឡា. ocimum gratissimum | តិណជាតិមានសណ្ឋានដូចជីរនាងវង ប៉ុន្តែដើមមានពណ៌ស្វាយ ក្លិនស្រដៀងនឹងជីរម្រះព្រៅ។ គេនិយមយកជីរលីងល័ខមកផ្សំធ្វើជា ប្រហុកកប់ ឬ ព្រហក់ខ្ទប់។<br>- អ្នកខ្លះហៅថា ‹‹ជីរនាងលាក់››។ |

| | |
|---|---|
| **៥៨- ជីវ៉ាន់ស៊ុយ**<br>អ. coriander<br>បារ. coriandre (f.)<br>ឡា. coriandrum sativum. | តិណជាតិម្យ៉ាងមានដើមតូចឆ្មារនិងស្លឹកផែកៗ ហើយមានសភាពទន់ មានក្លិនក្រអូបប្រហើរ ប្រើជាគ្រឿងទេស សម្រាប់យកក្លិនឬលម្អម្ហូបអាហារ។<br>- អ្នកខ្លះហៅថា «អ្វាន់ស៊ុយឬអួនស៊ុយ»។ |
| **៥៩- ជីត្រចៀកក្រាញ់**<br>អ.<br>បារ.<br>ឡា. centella asiatica | តិណជាតិដុះនៅតំបន់ក្ដៅ ស្លឹករាងមូលមានទងវែងៗ រឹមស្លឹករាងជាធ្មេញរណារ មានក្លិនក្រអូបពិសេសម្យ៉ាង។ គេនិយមបុកស្លឹកត្រចៀកក្រាញ់ ច្របាច់ច្រោះយកទឹកធ្វើជាភេសជ្ជៈនិងជាឱសថ។ |

## បច្ចេកសព្ទរបស់គណៈកម្មការវប្បធម៌ និង វិចិត្រសិល្បៈ ដែល គ.ជ.ភ.ខ. បានអនុម័ត

| | |
|---|---|
| **១- របាំព្រះរាជទ្រព្យខ្មែរ / របាំក្បាច់បុរាណខ្មែរ**<br>អ. royal ballet of Cambodia | ទម្រង់សិល្បៈទស្សនីយភាព ដែលសម្ដែងឡើងជារបាំដាច់ៗតែឯង មានលក្ខណៈសក្ការៈ អភិរក្សនិយម មានសោភណភាពនិងប្រណីតភាពខ្ពស់តំណាងឱ្យវប្បធម៌ និង អត្តសញ្ញាណជាតិខ្មែរ ។ (របាំនេះពីដើម គេរាំតែនៅក្នុងព្រះរាជពិធីតែប៉ុណ្ណោះ)<br>ឧ. របាំអប្សរា, របាំជូនពរ, របាំទេពមនោរម្យ ។ |
| **២- ល្ខោនព្រះរាជទ្រព្យខ្មែរ / ល្ខោនក្បាច់បុរាណខ្មែរ** | ទម្រង់សិល្បៈទស្សនីយភាព ដែលសម្ដែងឡើងដោយប្រើក្បាច់របាំបុរាណខ្មែរ ជារឿងល្ខោន មានលក្ខណៈសក្ការៈ អភិរក្សនិយម មានសោភណភាពនិងប្រណីតភាពខ្ពស់ តំណាងឱ្យវប្បធម៌និងអត្តសញ្ញាណជាតិខ្មែរ ។<br>ឧ. ល្ខោនព្រះរាជទ្រព្យ "រឿងរាមកេរ្តិ៍", "រឿងព្រះថោង នាងនាគ" ។ |
| **៣- តួនាយរោង** | ពាក្យសម្រាប់ហៅអ្នកសម្ដែងជាតួប្រុសនៅក្នុងល្ខោនព្រះរាជទ្រព្យខ្មែរនិងរបាំព្រះរាជទ្រព្យខ្មែរ។ ព្រះរាម ព្រះលក្ស្មណ៍ ជាតួនាយរោង។ |
| **៤- តួនាង**<br>អ. Tour Neang (female role dancer)<br>បារ. danseur role (m.) | ពាក្យសម្រាប់ហៅអ្នកសម្ដែងជាតួស្រី នៅក្នុងល្ខោនព្រះរាជទ្រព្យខ្មែរ ឬ ល្ខោនក្បាច់បុរាណខ្មែរ និង របាំព្រះរាជទ្រព្យខ្មែរឬរបាំក្បាច់បុរាណខ្មែរ ។ ដើម្បីដើរតួនាង គ្រូបង្ហាត់ល្ខោនព្រះរាជទ្រព្យខ្មែរជ្រើសរើសសិល្បការិនី ដែលមានរាងតូចស្ដើងនិងមានសម្ផស្សជានារីខ្មែរ ។<br>ឧ. សិល្បការិនីនេះសម្ដែងជាតួនាង ក្នុងរឿងរាមកេរ្តិ៍ជាព្រះនាងសីតា ។ |
| **៥- របាំប្រពៃណីខ្មែរ**<br>អ. khmer folk dance<br>បារ. danse folklorique khmère (f.) | របាំទាំងឡាយដែលស្ថិតជាប់នឹងពិធី ជាប្រពៃណីទំនៀមទម្លាប់ ជំនឿ សាសនា ឬពិធីជាតំណាត្រកូលដ៏យូរលង់របស់ជនជាតិខ្មែរនិងជនជាតិដើមភាគតិចនៅកម្ពុជា ។<br>ឧ. របាំត្រុដិ, របាំគោះត្រឡោក, របាំកាប់ក្របីផឹកស្រា (ជនជាតិគ្រឹង, របាំបេះក្រវាញ (ជនជាតិព័រ, របាំវាយគួយ(ជនជាតិគួយ)ជារបាំប្រពៃណីខ្មែរ ។ |

| | |
|---|---|
| **៦- របាំប្រជាប្រិយខ្មែរ**<br>អ. khmer popular dance<br>បារ. danse populaire khmère (f.) | ប្រភេទរបាំដែលជាប់ទាក់ទងទៅនឹងពិធីប្រពៃណីសម្រាប់កំលេងកម្សាន្ត ដើម្បីបំបាត់ការនឿយហត់ ក្រោយពីសម្រាកពីការងារផ្សេងៗ ឬ ពេលបានទទួលជោគ-ជ័យថ្មីៗឬក្នុងពេលជួបជុំញាតិមិត្តជិតឆ្ងាយជាដើម ។<br>ឧ. រាំវង់, រាំក្បាច់, សារ៉ាវ៉ាន់ ជារបាំប្រជាប្រិយខ្មែរ ។ |
| **៧- បេតិកភណ្ឌវប្បធម៌**<br>អ. cultural heritage<br>បារ. patrimoine culturel (m.) | ទ្រព្យសម្បត្តិរូបីនិងអរូបី ដែលជាកេរដំណែលមរតកវប្បធម៌របស់មនុស្សជាតិ បង្ហាញនូវសក្ខីភាពនៃស្នាដៃរបស់មនុស្សមានសារប្រយោជន៍និងតម្លៃខាងបុរាណវត្ថុវិទ្យា ប្រវត្តិវិទ្យា សិល្បៈ វិទ្យាសាស្ត្រ សាសនា សោភណភាព ជាតិពន្ធុវិទ្យា នរវិទ្យាឬក៏បច្ចេកទេស ជាដើម ។<br>ឧ. ប្រាសាទអង្គរវត្តជាបេតិកភណ្ឌវប្បធម៌រូបី ( ទ្រព្យសម្បត្តិរូបីដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ ។<br>របាំព្រះរាជទ្រព្យឬរបាំក្បាច់បុរាណខ្មែរ ជាបេតិកភណ្ឌវប្បធម៌អរូបី ( ទ្រព្យ-សម្បត្តិអរូបី) ជាស្នាដៃឯកនៃបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ ចុះបញ្ជីនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ។ |
| **៨- បេតិកភណ្ឌវប្បធម៌រូបី**<br>អ. tangible cultural heritage<br>បារ. patrimoine culturel matériel (m.) | ស្នាដៃបង្កើតដោយមនុស្ស ជាទ្រព្យសម្បត្តិដែលអាចមើលឃើញ ប៉ះពាល់បានងាយយល់ និង មានតម្លៃប្រវត្តិសាស្ត្រ សោភណភាព សិល្បៈ សាសនា វិទ្យាសាស្ត្រ បុរាណវត្ថុវិទ្យា ជាតិពន្ធុវិទ្យា ឬ នរវិទ្យា រួមមាន ប្រាសាទ វិមាន វិហារ អគារ ផ្ទះសម្បែង វត្តអារាម រមណីយដ្ឋានវប្បធម៌ ជាដើម ។<br>ឧ. ប្រាសាទអង្គរវត្ត ។ |
| **៩- បេតិកភណ្ឌវប្បធម៌អរូបី**<br>អ. intangible cultural heritage<br>បារ. patrimoine culturel immatériel (m.) | មរតកបង្កើតដោយមនុស្ស បានផ្ទេរបន្តពីជំនាន់មួយទៅជំនាន់មួយតាមរយៈការប្រតិបត្តិ ការបង្ហាញ ការសម្ដែង ការនិយាយ ឬ ការតំណាប់តៗគ្នា ដែលមិនអាចមើលឃើញ មិនអាចប៉ះពាល់បាននិងពិបាកយល់ ដូចជា : ចំណេះដឹង បំណិន ភាសា សិល្បៈ សាសនា ជំនឿ ទំនៀមទម្លាប់ ប្រពៃណី ឧបករណ៍សម្ភារៈ វត្ថុសិល្បៈ ជាដើម ។<br>ឧ. របាំអប្សរា ចម្លាក់ គំនូរ សិលាចារឹក ជាមរតកបេតិកភណ្ឌវប្បធម៌អរូបី ។ |
| **១០- សិល្បៈទស្សនីយភាព**<br>អ. performing arts<br>បារ. arts d'interprétation (arts du spectacle, arts de représentation) (m.) | ទម្រង់សិល្បៈសម្ដែងគ្រប់ប្រភេទ កើតពីការប្រតិបត្តិ ពីទេពកោសល្យ និង ការប្រឌិតញាណដ៏អស្ចារ្យរបស់មនុស្ស ដែលគួរឱ្យរំភើប គួរឱ្យចង់មើល គួរឱ្យចង់ស្ដាប់ និង គួរគិត ។<br>ឧ. តន្ត្រី របាំ ល្ខោន ការនិទានរឿង ការសូត្រកំណាព្យ... ជាសិល្បៈទស្សនីយភាព ។ |
| **១១- ល្ខោន / សិល្បៈនាដកម្ម**<br>អ. theatre<br>បារ. art dramatique, théâtre (m.) | ទម្រង់សិល្បៈទស្សនីយភាព ដែលសម្ដែងអំពីរឿងមួយតាមរយៈពាក្យសម្ដី និង សកម្មភាពតួអង្គនៅក្នុងសាច់រឿង នៅចំពោះមុខទស្សនិកជន ។<br>ឧ. ល្ខោនរឿង ថ្មរាំ ។ |

| | |
|---|---|
| **១២- នាដកថា**<br>អ. script of the play<br>បារ. pièce de théâtre (f.) | អត្ថបទរឿងល្ខោន ដែលពណ៌នាលម្អិតអំពីចំណងជើងរឿង ឈ្មោះអ្នកនិពន្ធ កាល-បរិច្ឆេទនិពន្ធ រាយតួសម្ដែង ឆាក ឈុត ការកាត់កងឆាក ពាក្យពេចន៍ សន្ទនា ឯកវាទ (ការនិយាយម្នាក់ឯង) បទចម្រៀង ភ្លេងកំដរ...។<br>ឧ. នាដកថារឿង "ចៅកែចិត្តចោរ" របស់អ្នកនិពន្ធ អ៊ំ ឈឺន និង ពៅ យូឡេង។ |
| **១៣- ល្បែងនាដកម្ម**<br>បារ. jeu dramatique (m.) | មុខវិជ្ជាបច្ចេកទេសសម្រាប់ហាត់សម្ដែងសិល្បៈនាដកម្ម ដែលគ្រូបង្ហាត់ល្ខោនកំណត់ឱ្យសិស្សហាត់សម្ដែងឈុតខ្លីៗ។<br>ឧ. ល្បែងនាដកម្មឈុតខ្លីមួយ *"ចូលព្រៃដើរជាន់ពស់"*។ |
| **១៤- សោកនាដកម្ម**<br>អ. tragedy<br>បារ. tragédie (f.) | ប្រភេទរឿងល្ខោន ដែលបង្ហាញពីបញ្ហាទាក់ទងទៅនឹងគ្រោះកម្មវាសនា ទុក្ខសោក ទុក្ខវេទនា សេចក្ដីវិនាសអន្តរាយ ហើយ តួឯកត្រូវស្លាប់នៅចុងបញ្ចប់នៃសាច់រឿង ដែលធ្វើឱ្យអ្នកស្ដាប់ អ្នកទស្សនាក្ដុកក្ដួល រំជួលចិត្តអាណិតអាសូរ និង ភ័យរន្ធត់។<br>ឧ. សោកនាដកម្ម : *រឿងទុំទាវ, រឿងម៉ាក់ធឺង...*។ |
| **១៥- ហាសនាដកម្ម**<br>អ. comedy<br>បារ. comédie (f.) | ប្រភេទរឿងល្ខោនដែលធ្វើឱ្យអ្នកស្ដាប់ អ្នកទស្សនាផ្ទុះសំណើច អាចទទួលបាននូវការកម្សាន្តសប្បាយផង និង ទាំងការទិតៀនរិះគន់ផង តាមរយៈនៃការសម្ដែង ការអធិប្បាយ ការក្លែងធ្វើពុត ធ្វើពើ ធ្វើភ្លីភ្លើ ធ្វើល្ងីល្ងើរបស់ជនល្ងង់ខ្លៅ តួត្លុក តួក្រមាច់ ជាដើម។<br>ឧ. ហាសនាដកម្មរឿង "*ជនកំណាញ់ក្រៅគម្រា*" និពន្ធដោយ លោក Molière។ |
| **១៦- សោកហាសនាដកម្ម**<br>អ. tragicomedy<br>បារ. tragi-comédie (f.) | ប្រភេទរឿងល្ខោន ដែលផ្ដោតខ្លាំងទៅលើរឿងរ៉ាវដ៏ក្រៀមក្រំ ទុក្ខសោកផង និង សប្បាយរីករាយផង។<br>ឧ. សោកហាសនាដកម្មរឿង "*សំបុកឥតមេបា*"។ |
| **១៧- សង្វេគនាដកម្ម**<br>អ. melodrama<br>បារ. mélodrame (m.) | ប្រភេទរឿងល្ខោនកម្សត់ ជាប់ទាក់ទងទៅនឹងទំនាស់ខាងផ្នែកចរិយាធម៌ (Morality) រវាងអំពើល្អនិងអំពើអាក្រក់ហួសពីភាពសាមញ្ញ កើតឡើងក្នុងស្ថានការណ៍ប្រថុចញ៉ុច ប្រផិតប្រផើយឬចៃដន្យ ហើយ នៅចុងបញ្ចប់នៃសាច់រឿង តួអង្គអាចស្រាយបញ្ហាបាន។<br>ឧ. សង្វេគនាដកម្មរឿង "ធនញ្ជ័យ"។ |
| **១៨- រចនាសម្ព័ន្ធសំណង់ (បុរាណវត្ថុវិទ្យា)**<br>អ. structure<br>បារ. structure (f.) | សំណង់ដែលមនុស្សបង្កើតឡើង មានគ្រឹះនៅជាប់នឹងដី ដូចជា ផ្ទះ, ប្រាសាទ, អគារជាដើម។ |
| **១៩- បុរាណវត្ថុ**<br>អ. antique<br>បារ. antiquité (f.) | វត្ថុដែលបន្សល់ពីអតីតកាល។ |

| | |
|---|---|
| **២០- បុរាណវត្ថុសិល្បៈ**<br>អ. artifact<br>**បារ.** objet d’art antique ( m.) | បុរាណវត្ថុដែលបង្កើតនិងកែច្នៃដោយមនុស្ស និង អាចផ្លាស់ប្តូរទីតាំងបាន ដូចជា កុលាលភាជន៍ គ្រឿងអលង្ការ និង គ្រឿងសស្ត្រាវុធ (ដាវ លំពែង ធ្នូ ស្នា...) ជាដើម ។ |
| **២១- កុលាលភាជន៍**<br>អ. pottery<br>បារ. poterie (f.) | បុរាណវត្ថុសិល្បៈមានដូចជា ភាជន៍ដី, ចាន, ឆ្នាំង ឬក្អមដែលធ្វើដោយដីឥដ្ឋដុត ក្នុងសីតុណ្ហភាពខ្ពស់ សម្រាប់ដាក់ភោជនាហារមានបាយ ទឹកជាដើម ។ |
| **២២- ពរ្សឺទ្បែន**<br>អ. porcelain/china<br>បារ. porcelaine (f.) | ប្រភេទមួយនៃសេរ៉ាមិក មានពណ៌ស សាច់ម៉ដ្ឋ ភ្លឺរលោង មានភាពរឹងខ្លាំង និង ដុតនៅក្នុងកម្តៅខ្ពស់ពី ១ ២៥០ - ១ ៤០០ អង្សាសេ ធ្វើឡើងយ៉ាងផ្ចិតផ្ចង់ និង ដោយប្រណីត ព្រមទាំងមានតម្លៃខាងសោភណភាព។ ជាគ្រឿងប្រដាប់ប្រើប្រាស់ មាន ចាន និង ពែងជាដើម ។ ឧ. ចានពរ្សឺទ្បែន ។ |
| **២៣- គ្រឿងដីដុតរឹង**<br>អ. stoneware | ប្រភេទមួយនៃសេរ៉ាមិក ដែលមានលក្ខណៈរឹង និង មិនជ្រាបទឹក ដែលដុតក្នុង សីតុណ្ហភាពពី ១ ២០០-១ ៣៥០ អង្សាសេ ។ |
| **២៤- សេរ៉ាមិក**<br>អ. ceramic<br>បារ. céramique (f.) | បុរាណវត្ថុសិល្បៈធ្វើពីដីឥដ្ឋដុត មានលក្ខណៈរឹង ធន់នឹងកម្តៅ និង សារធាតុគីមី ។ សេរ៉ាមិករួមមានកុលាលភាជន៍ ពរ្សឺទ្បែន ទែរ៉ាកូតា និង ផលិតផលធ្វើពីដីដុត ផ្សេងៗទៀត ។ |
| **២៥- ទែរ៉ាកូតា**<br>អ. terra cotta<br>បារ. terre cuite (f.) | សេរ៉ាមិកមួយប្រភេទ ជាគ្រឿងដីដុត ដែលដុតនៅក្នុងសីតុណ្ហភាពក្រោម ៩០០ អង្សាសេ ហើយមានភាពស្លោត(មិនហាប់) ។ គេប្រើវាសម្រាប់ផលិតវត្ថុសិល្បៈ ដូចជា ផើងផ្កា ផែនរូបភាពផ្សេងៗ គ្រាប់លញ្ជ្រ ត្រល់ ជើងសំណាញ់ ជាដើម ។ បច្ចុប្បន្ន ទែរ៉ាកូតា ជាវត្ថុសិល្បៈធ្វើដីឥដ្ឋ មាន ដូចជា បដិមានិងសម្ភារៈសំណង់ ជាដើម ។ |
| **២៦- កុលាលភាជន៍រឹង**<br>អ. stoneware (pottery)<br>បារ. poterie en grès (f.) | កុលាលភាជន៍មួយប្រភេទដែលមានលក្ខណៈរឹងនិងមិនជ្រាបទឹក ដែលដុតក្នុង សីតុណ្ហភាពពី ១ ២០០ ទៅ ១ ៣៥០ អង្សាសេ ។ |
| **២៧- កុលាលភាជន៍ស្រួយ**<br>អ. earthenware (pottery)<br>បារ. poterie en faience (f.) | កុលាលភាជន៍មួយប្រភេទដែលមានលក្ខណៈស្រួយនិងជ្រាបទឹក ដែលដុតក្នុង សីតុណ្ហភាពពី ៩០០ ទៅ ១ ២០០ អង្សាសេ ។ |
| **២៨- បន្ទាយគូ**<br>អ. circular earthwork<br>បារ. fortification circu-laire en terre (f.) | ឈ្មោះស្ថានីយបុរាណវត្ថុវិទ្យា មានសំណង់ដីរាងមូល ដែលមនុស្សបានកសាងឡើង ដោយជីកគូ(គូទឹក)និងលើកកំពែងព័ទ្ធជុំវិញ ដូចជា បន្ទាយគូនៅមេមត់ បន្ទាយគូ នៅជើងឯក ជាដើម ។ អ្នកស្រាវជ្រាវបារាំងឈ្មោះ Bernard Philippe Groslier ហៅ បន្ទាយគូមេមត់ ថា rond village ។ |
| **២៩- គូ /គូទឹក**<br>អ. moat<br>បារ. douve (f.) | សំណង់ស្នាមភ្លោះបុរាណព័ទ្ធជុំវិញបន្ទាយ, វាំង, ប្រាសាទ, វត្តឬភូមិ; ពាក្យបុរាណ ហៅ កសិណ ដូចយ៉ាង កសិណព័ទ្ធជុំវិញអង្គរវត្ត ជាដើម ។ |

| | |
|---|---|
| **៣០- កំពែង**<br>អ. rampart<br>បារ. rempart (m.) | សំណង់ការពារធ្វើពីដី ពីឥដ្ឋឬពីថ្ម ដែលលើកព័ទ្ធជុំវិញក្រុង, បន្ទាយ, វាំង, ប្រាសាទ ជាដើម។ ឧ. កំពែងក្រុងអង្គរបុរីសង់ពីឥដ្ឋ។ |
| **៣១- រោងថែវ / រោងទង**<br>អ. gallery<br>បារ. galerie (f.) | រោងជួរមានសណ្ឋានវែង ជាបរិវេណព័ទ្ធជុំវិញប្រាសាទឬវិហារជាដើម មានទ្វារធំទាំង៤ទិស ដែលមានល្វែងច្រើនបាំងជញ្ជាំងខណ្ឌដោយសង្កាត់ៗ មានទ្វារខាងទទឹងរោង សម្រាប់ដាក់តាំងបង្ហាញពីវត្ថុសិល្បៈ ដូចជា គំនូរ, ចម្លាក់ ជាដើម។<br>ឧ. រោងថែវប្រាសាទអង្គរវត្ត, រោងថែវប្រាសាទព្រះវិហារ, រោងថែវព្រះវិហារព្រះកែវមរកត ។ល។ |
| **៣២- ស្ពានហាល**<br>អ. causeway | សំណង់ស្ពានថ្មបុរាណឆ្លងកាត់កសិណទឹកឬកាត់ថ្លាដីគោកឆ្ពោះទៅកាន់ប្រាសាទបុរាណ។<br>ឧ. ទេសចរចូលទស្សនាប្រាសាទអង្គរវត្តដោយដើរឆ្លងកាត់ស្ពានហាលពីទិសខាងលិច។ |
| ៣៣- រូត (ប្រាសាទ)<br>អ. temple gradin | ជាន់ ឬ ថ្នាក់នៃប្រាសាទ។<br>ឧ. រូតបាកាននៃប្រាសាទអង្គរវត្ត។ |
| ៣៤- តដាក<br>អ. water reservoir | បឹងធំដែលកើតឡើងដោយការលើកដីជាទំនប់ព័ទ្ធជុំវិញរាងបួនជ្រុង។ លុះតយូរមកដល់សព្វថ្ងៃនេះ តដាកហៅក្លាយជា ប៉ដាកឬប្រដាក។ ពាក្យ តដាក ជាពាក្យបុរាណមានចារក្នុងសិលាចារឹកសម័យអង្គរ (K. 598 B: 7, K. 933:24, K. 265 N: 5)។<br>ឧ. ព្រះរាជាក្នុងសម័យអង្គរបានកសាងតដាកជាច្រើននៅក្នុងតំបន់អង្គរ។ |
| ៣៥- ឥន្ទ្រតដាក<br>អ. Indratataka | ឈ្មោះតដាកដែលសាងនៅក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័ន (៨៧៧-៨៨៩) មានទំហំ ៣.៨ គ.ម. x ៨០០ គ.ម. ទាញពីទឹកស្ទឹងរលួសមកបញ្ចូល។ |
| ៣៦- យសោធរតដាក<br>អ. Yasodharatataka | ឈ្មោះតដាកដែលសាងនៅក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ (៨៨៩-៩១០) ទំហំ ៧ គ.ម. x ២ គ.ម. ដែលមានប្រាសាទមេបុណ្យខាងកើតនៅចំកណ្តាល បច្ចុប្បន្នគេច្រើនហៅថា បារាយណ៍ខាងកើត (Eastern Baray)។ |
| ៣៧- ជ័យតដាក/ វាលរាជដាក<br>អ. Jayatataka | ឈ្មោះតដាកដែលសាងនៅសតវត្សរ៍ទី១២ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២២០?) ទំហំ ៣.៥ គ.ម. x ១ គ.ម. ដែលមានប្រាសាទនាគព័ន្ធសង់នៅចំកណ្តាល។ បច្ចុប្បន្ន អ្នកស្រុកនៅតំបន់អង្គរច្រើនហៅ វាលរាជដាក។ |
| **៣៨- បាកាន**<br>អ. Bakan | - តួប៉មទាំងប្រាំនៅរូតទីបីនៃប្រាសាទអង្គរវត្ត។<br>ឧ. មានរូបបីជាន់ ល្អល្អះគ្រាប់គ្រាន់ ត្រសោលត្រសំ<br>ជាសារពើសួត រហូតដល់កំ- ពូលពេជ្រឧត្តម<br>បាកានទាំងប្រាំ។ (ដកស្រង់ពីល្បើកអង្គរ ក្នុងវគ្គទី១២០)<br>- ឈ្មោះប្រាសាទមួយនៅក្នុងឃុំតាសែង ស្រុកកំពង់ស្វាយ ខេត្តព្រះវិហារ។ មានឯកសារស្រាវជ្រាវខ្លះហៅបាកាន ឬ ប្រាសាទព្រះខ័ន (កំពង់ស្វាយ)។<br>- ឈ្មោះស្រុកមួយនៅក្នុងខេត្តពោធិ៍សាត់។ |

| | |
|---|---|
| **៣៩- ក្ដារបែន**<br>អ. Kda Ben<br>(cruciform platform) | ឈ្មោះព្រះលានមួយដែលមានសណ្ឋានជាជើងក្អែកតភ្ជាប់ពីស្ពានហាលទៅគោបុរនៃខ្លោងទ្វារធំប្រាសាទ ។ ក្ដារបែន គឺសម្រាប់ព្រះមហាក្សត្រទទួលនាម៉ឺនសព្វមុខមន្ត្រី និង សម្រាប់ទតក្បួនដង្ហែផ្សេងៗ ក្នុងពិធីបុណ្យ ។<br>ឧ. ប្រដាប់ជាឋាន ក្ដារបែនសោតមាន បស្ចិមទិសា<br>រោងរម្យកក្លាក ស្អាងស្អាតសោភា សឹងថ្មសិលា<br>ប្រកិតក្រាស់ក្រៃ ។ (ដកស្រង់ពីល្បើកអង្គរ ក្នុងវគ្គទី១៣៣) |
| **៤០- ហោត្រៃ** (ប្រាសាទ)<br>អ. Hortrai (library) | សំណង់អគារបុរាណនៅក្នុងបរិវេណប្រាសាទ ជាទូទៅបែរមុខបញ្ច្រាសទិសនឹងតួប៉មកណ្ដាលនៃប្រាសាទនោះ ។<br>ឧ. ជាប្រាង្គប្រាសាទ ល្អល្អះស្អាងស្អាត សុទ្ធសឹងតែថ្ម<br>មានរោងជំនុំ ទាំងស្រះបួនល្អ ហោត្រៃសឹងថ្ម<br>ឆ្វេងស្ដាំផងណា ។ (ដកស្រង់ពីល្បើកអង្គរ ក្នុងវគ្គទី១១៥) |
| **៤១- ហានិភ័យ**<br>អ. risk<br>បារ. risque (m.) | ហេតុ ឬ បញ្ហាប្រឈមផ្សេងៗដែលអាចនាំឱ្យបាត់បង់ ឬ ខូចខាត នូវបុរាណវត្ថុសិល្បៈ ប្រាសាទបុរាណនិងស្ថានីយបុរាណវត្ថុវិទ្យា ។<br>ឧ. ជណ្ដើរថ្មភក់នៃប្រាសាទភ្នំបាខែងទទួលរងហានិភ័យដោយកត្តាធម្មជាតិ ដូចជាទឹកភ្លៀងហូរច្រោះ ឫសឈើដុះចាក់ និង មនុស្សដើរឡើងចុះជាន់ផ្ទាល់ ។ |
| **៤២- យថាគ្រោះ**<br>អ. hazard<br>បារ. danger (m.) | បាតុភូតដែលបង្កឱ្យមានបញ្ហាប្រឈម នាំទៅដល់ការបំផ្លាញ និង ឈានដល់ការវិនាសបុរាណវត្ថុសិល្បៈ ប្រាសាទបុរាណ និង ស្ថានីយបុរាណវត្ថុវិទ្យា ។<br>ឧ. ទឹកទន្លេ **មេគង្គ** ហូរច្រោះបាក់ដីបណ្ដាលឱ្យមានគ្រោះថ្នាក់ រហូតដល់បាត់រូបរាង ។ ប្រាសាទ **បាចុង** ក្នុងខេត្តស្ទឹងត្រែង ត្រូវបានចាត់ទុកជាយថាគ្រោះ ។ |
| **៤៣- យថាភូតភាព**<br>អ. authenticity<br>បារ. authenticité (f.) | លក្ខណៈឬសណ្ឋានដើមនៃសម្ភារៈ ប្លង់ ទេពកោសល្យ ស្នាដៃ បច្ចេកទេស ស្ថាបត្យ-កម្ម បច្ចេកទេសវិស្វកម្ម និង ការរៀបចំនគរូបនីយកម្ម ដែលបង្កប់នៅក្នុងធនធានបេតិកភណ្ឌវប្បធម៌ ទៅតាមដំណាក់កាលប្រវត្តិសាស្ត្រ ។<br>ឧ. ការជួសជុលនិងអភិរក្សប្រាសាទព្រះវិហារដែលជាបេតិកភណ្ឌពិភពលោក ត្រូវរក្សាឱ្យបានល្អតាមយថាភូតភាព ។ |
| **៤៤- ការអភិរក្ស**<br>អ. conservation<br>បារ. conservation (f.) | ការគ្រប់គ្រង ថែរក្សា ការពារ ដើម្បីប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវបុរាណវត្ថុសិល្បៈ ប្រាសាទបុរាណ ស្ថានីយបុរាណវត្ថុវិទ្យា និង ធនធានបេតិកភណ្ឌ ឱ្យមានសុវត្ថិភាពដើម្បីបញ្ចៀសហានិភ័យផ្សេងៗ ។ ទស្សនៈទូទៅនៃពាក្យ "អភិរក្ស" ផ្ដោតលើការការពារផ្សេងៗ ដល់អគារ ស្ថានីយបុរាណ ទីក្រុងបុរាណ រួមមាន ការថែទាំ ការជួសជុល ការពង្រឹង និង ការបន្ថែមកម្លាំង ។ |
| **៤៥- ការបង្ការ**<br>អ. preservation<br>បារ. prévention ( f.) | ការចាត់វិធានការចាំបាច់ផ្សេងៗ ដើម្បីថែរក្សាបុរាណវត្ថុសិល្បៈ ប្រាសាទបុរាណ ស្ថានីយបុរាណវត្ថុវិទ្យា និង ធនធានបេតិកភណ្ឌ ឱ្យនៅគង់វង្ស ។ |

| | |
|---|---|
| **៤៦- ការការពារ**<br>អ. protection<br>បារ. protection ( f.) | សកម្មភាពដែលតម្រូវឱ្យមានការកំណត់លក្ខខណ្ឌផ្សេងៗ ដើម្បីសង្គ្រោះបុរាណវត្ថុ-សិល្បៈ ប្រាសាទបុរាណ ស្ថានីយបុរាណវត្ថុវិទ្យា តំបន់ប្រវត្តិសាស្ត្រ និង ធនធានបេតិកភណ្ឌ ដើម្បីទប់ស្កាត់អំពើចោរកម្ម ការរំលោភ ការបំផ្លិចបំផ្លាញ រួមទាំងការបំផ្លាញពីធម្មជាតិ ។<br>ឧ. អាជ្ញាធរជាតិព្រះវិហាររៀបចំតំបន់ការពារ ដើម្បីអភិរក្សនិងអភិវឌ្ឍតំបន់ប្រាសាទព្រះវិហារ ។ |
| **៤៧- ការពង្រឹង**<br>អ. consolidation<br>បារ. consolidation ( f.) | ការបិទ ការភ្ជិត ការលាប... លើបុរាណវត្ថុផ្សេងៗ តាមរយៈការប្រើប្រាស់សារធាតុផ្សេងៗ ដើម្បីរក្សាទម្រង់បុរាណវត្ថុនោះឱ្យស្ថិតនៅគង់វង្ស ។<br>ឧ. ការពង្រឹងកុលាលភាជន៍បែកបាក់ មុននឹងយកទៅដាក់តាំងបង្ហាញ ។ |
| **៤៨- អាណាស្ទីឡូស**<br>អ. anastylosis<br>បារ. anastylose ( f.) | បច្ចេកទេសជួសជុលសំណង់ប្រាសាទ ឬ អគារដែលត្រូវរុះរើទាំងស្រុង រួចរៀបសង់ជាថ្មីឡើងវិញ ដោយប្រើប្រាស់រចនាសម្ព័ន្ធដើម(សម្ភារៈដើម) ក្នុងករណីបាត់បង់ ឬ ខ្វះខាតត្រូវបន្ថែមសម្ភារៈថ្មី ។<br>ឧ. បុរាណវិទូជនជាតិបារាំង Henry Marchal ប្រើប្រាស់បច្ចេកទេសអាណាស្ទីឡូសដើម្បីជួសជុលប្រាសាទបន្ទាយស្រី ។ |
| **៤៩- វិចិត្រករ**<br>អ. creative artist<br>បារ. créateur artistique (m.) | អ្នកដែលមានអាជីពប្រកបដោយទេពកោសល្យ ក្នុងការបង្កបង្កើត រចនា តុបតែង រំលេចពណ៌ គូរ ឆ្លាក់ ថតរូប ។<br>ឧ. រូបគំនូរស្រីកណ្ដៀតក្អមមួយផ្ទាំងនេះ គឺជាស្នាដៃឯករបស់លោក ***ញ៉ិក អ៊ឹម*** ដែលជាវិចិត្រករខ្មែរម្នាក់ដ៏ល្បី ក្នុងទសវត្សរ៍ទី៧ នៃសតវត្សរ៍ទី២០ ។ |
| **៥០- សិល្បករ**<br>អ. artist<br>បារ. artiste (m.) | អ្នកដែលមានវិជ្ជាជីវៈខាងសិល្បៈ ដូចជា របាំ ចម្រៀង ភ្លេង ល្ខោន គំនូរ ស្ទូនរូប ។ល។ អាចបង្កើតបានជាស្នាដៃចេញពីការស្រមៃ និង ការច្នៃប្រឌិតប្រកបដោយ សោភណ-ភាព តាមរយៈកាយពលកម្មនិងបញ្ញាពលកម្ម ធ្វើឱ្យមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់មើល ចង់ឃើញ ចង់ស្ដាប់ និង ចង់ស្គាល់ ។ បើស្ត្រីហៅថា **សិល្បការិនី** ។<br>ឧ. ភិរម្យ **ប្រាជ្ញ ឈួន** ជាសិល្បករចម្រៀងចាប៉ី ។ នៅឆ្នាំ ២០០១ លោកបានទទួលវិញ្ញាបនបត្រជាព្រឹទ្ធសិល្បករ ពីរាជបណ្ឌិត្យសភាកម្ពុជា ។ |
| **៥១- តួសម្ដែង**<br>អ. actor, actress<br>បារ. acteur (m.), actrice (f.) | សិល្បករ សិល្បការិនី ដែលសម្ដែងនៅលើឆាក ទូរទស្សន៍ វិទ្យុ និង ភាពយន្ត... ដោយប្រើប្រាស់ ចលនាកាយវិការ ពាក្យពេចន៍ ចម្រៀង ការរាំ និង ការប្រគំតន្ត្រី បង្កើតឡើងដោយអ្នកដឹកនាំរឿង ។ តួសម្ដែងប្រុស **(actor)** តួសម្ដែងស្រី **(actress)** ។<br>ឧ. លោក ***សាំង សារុន*** សម្ដែងជាតួព្រះធិនវង្ស នៅក្នុងល្ខោនបាសាក់ រឿងព្រះធិនវង្ស និង នាងពៅ ។ |
| **៥២- តួ**<br>អ. character<br>បារ. personage (m.) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលសម្ដែងដោយតំណាងឱ្យសភាវៈផ្សេងៗ នៅក្នុងរឿង ល្ខោន ភាពយន្ត នៅក្នុងទម្រង់សិល្បៈណាមួយ ដែលបង្កើតឡើងដោយអ្នកនិពន្ធ ។<br>ឧ. លោក អៀង ស៊ីថុល ដើរតួជាតួនេនទុំ ក្នុងរឿងទុំទាវ ។ |

| | |
|---|---|
| **៥៣- តួឯក**<br>អ. principle role<br>បារ. rôle principal,<br>premier rôle (m.) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលសម្ដែងជាតួសំខាន់ជាងគេ នៅក្នុងរឿងណាមួយ ។<br>ឧ. លោក **សាំង សារុន** សម្ដែងជាតួឯក ( ឈ្មោះព្រះធិនវង្ស) នៅក្នុងល្ខោនបាសាក់ រឿងព្រះធិនវង្ស និង នាងពៅ ។ |
| **៥៤- តួរង**<br>អ. second role<br>បារ. second rôle (m.)<br>rôle secondaire ( m. ) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលសម្ដែងជាតួសំខាន់បន្ទាប់ពីតួឯក នៅក្នុងរឿងណាមួយ ។<br>ឧ. លោក **សម ម៉ាលី** ជាអតីតសិល្បករនៅនាយកដ្ឋានសិល្បៈនិងទស្សនីយភាព សម្ដែងជាតួរង ( តួនេនពេជ្រ) នៅក្នុងល្ខោនយីកេរឿងទុំទាវ ក្នុងទស្សវត្សរ៍ទី៨ នៃសតវត្សរ៍ទី២០ ។ |
| **៥៥- តួបន្ទាប់បន្សំ**<br>អ. extra role<br>បារ. figurant (m.) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលសម្ដែងជាតួក្រៅពីតួឯកនិងតួរង នៅក្នុងរឿងណាមួយ ។<br>ឧ. នៅក្នុងល្ខោនយីកេរឿងទុំទាវ មានតួបន្ទាប់បន្សំជាច្រើន ដូចជា តួភីលៀង តួអាមាត្យ តួអ្នកស្រុក ជាដើម ។ |
| **៥៦- តួត្លុក**<br>អ. comedian, comic<br>បារ. comédien (m.) | មនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលធ្វើឱ្យអ្នកស្ដាប់ អ្នកទស្សនាសើចសប្បាយ តាមរយៈការសម្ដែងកាយវិការ ពាក្យសម្ដី បទចម្រៀង... ដែលកំណត់ដោយអ្នកនិពន្ធ និង អ្នកដឹកនាំរឿង នៅក្នុងសិល្បៈទស្សនីយភាព ជាពិសេស ល្ខោនយីកេ និង ល្ខោនបាសាក់ ។<br>ឧ. លោកគ្រូ អ៊ុច សំអុល ហៅ តាប៉ោក និង លោក ព្រីង សាឃន គឺជាតួត្លុកដ៏ល្បី នៅក្នុងល្ខោនយីកេរឿងទុំ ទាវ ( នាទសវត្សរ៍ទី៨ នៃសតវត្សរ៍ទី២០) ។ |
| ៥៧- ថ្នាំងដៃ ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមចុងចង្អុលដៃមកត្រឹមគន្លាក់ដំបូង។<br>ឧ. *សំណាបទើបដុះបានមួយថ្នាំងដៃ។* |
| ៥៨- ចង្អុលដៃ ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមចុងមកដល់គល់ម្រាមចង្អុលដៃ។<br>ឧ. *យប់មិញទឹកស្រកមួយចង្អុលដៃ។* |
| ៥៩- ទោម ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមចុងមេដៃទៅចុងចង្អុលដៃ ដែលញែកឱ្យតឹងកន្ទែកពីគ្នា។ (វចនានុក្រមខ្មែរ បោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧)<br>ឧ. *កំណាត់សំពត់ប្រវែងប្រាំពីរទោម។* |
| ៦០- ចំអាម ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតត្រឹមចុងមេដៃទៅចុងម្រាមដៃកណ្ដាល ដែលញែកតឹងកន្ទែកពីគ្នា។ មួយចំអាមប្រវែងកន្លះហត្ថឬ ប្រហែល២៥សង់ទីម៉ែត្រ។ |
| ៦១- គក់ ឬ ហត្ថក្រពុំ ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមកែងដៃទៅដល់គល់ម្រាមកូនដៃ ដែលក្ដាប់ ក្ដោបចូល ដោយមានប្រវែងប្រហាក់ប្រហែល ១៦អង្គុលី (ប្រហែល ៤០,៦២៤ សង់ទីម៉ែត្រ)។<br>បញ្ជាក់ : *១អង្គុលី ប្រវែងប្រហែល ២, ៥៣៩ សង់ទីម៉ែត្រ* |

| | |
|---|---|
| ៦២- ហត្ថ ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ គិតប្រវែងពីត្រឹមកែងដៃដល់ចុងម្រាមដៃកណ្ដាល (ចង្អុលខ្មោច)។ មួយហត្ថ គឺប្រហែលពីរចំអាម។ |
| ៦៣- ហត្ថខ្នាត ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមកែងដៃទៅដល់ចុងម្រាមដៃកណ្ដាល (ចង្អុលខ្មោច) ដែលមានប្រវែងស្មើនឹងកន្លះម៉ែត្រ។<br>សម្គាល់ មួយហត្ថខ្នាត គឺកំណត់ដោយប្រវែងជាក់លាក់ដែលមនុស្សម្នាក់កំណត់ចំណាំខ្លួនឯងឱ្យស្មើនឹងកន្លះម៉ែត្រ។<br>ឧ. ដៃខ្ញុំខ្លី ដើម្បីបានមួយហត្ថខ្នាត ខ្ញុំត្រូវវាស់មួយហត្ថដៃខ្ញុំ ហើយថែមពីរធ្នាប់។ |
| ៦៤- លូក ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីត្រឹមក្លៀកទៅដល់ចុងម្រាមដៃកណ្ដាល (ចង្អុលខ្មោច)។<br>ឧ. រន្ធក្ដាមនេះមានជម្រៅមួយលូក។ |
| ៦៥- ព្យាម ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ស្មើមួយកាងដៃ ដោយគិតពីចុងម្រាមដៃកណ្ដាល (ចង្អុលខ្មោច)នៃដៃខាងឆ្វេងទៅចុងម្រាមដៃកណ្ដាល(ចង្អុលខ្មោច) នៃដៃខាងស្ដាំ។ មួយព្យាមមានប្រវែងប្រហែលប្រមាណជាពីរម៉ែត្រ។ |
| ៦៦- ព្យាមដំរី ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដោយគិតពីចុងម្រាមមេជើងឆ្វេងទៅចុងម្រាមដៃកណ្ដាល(ចង្អុលខ្មោច)នៃដៃស្ដាំស្របតាមបណ្ដោយដងខ្លួនដែលដេកផ្កាប់មុខ ហើយសណ្ដូកដៃ ជើងឱ្យត្រង់។ |
| ៦៧- យដ្ឋិ (យ័ត-ឋិ)ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង៧ហត្ថខ្នាត ស្មើនឹង៣ម៉ែត្រកន្លះ។ |
| ៦៨- អព្ភន្តរ (អ័ប-ភ័ន-តៈ-រៈ ឬ អ័ប-ភ័ន-ដ) ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ (ពាក្យប្រើក្នុងព្រះវិន័យព្រះពុទ្ធសាសនាសម្រាប់កំណត់គោលអពទ្ធសីមា) ដែលមានប្រវែង៧ព្យាមឬប្រវែង២៨ហត្ថខ្នាត ស្មើនឹង ១៤ម៉ែត្រ។ |
| ៦៩- សិន ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង២០ព្យាម ស្មើនឹង៤០ម៉ែត្រ។ |
| ៧០- ឧសភ (អ៊ុសប់)ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង១៤០ហត្ថខ្នាត (២០យដ្ឋិ) ឬ ៣៥ព្យាម ស្មើនឹង៧០ម៉ែត្រ (ចម្ងាយស្មើនឹងសំឡេងគោឧសភរាជរោទ៍)។ |
| ៧១- គាវុត ន. | រង្វាស់ប្រវែងខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង២ ០០០ព្យាម ឬ ១០០សិន ស្មើនឹង៤ ០០០ម៉ែត្រ។ |
| ៧២- យោជន៍ ន. | ១- រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង៤០០សិន ឬ ៤គាវុត ស្មើនឹង ១៦ ០០០ម៉ែត្រ (១៦គីឡូម៉ែត្រ)។<br>២- រង្វាស់កម្ពស់នៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែង៧ហត្ថខ្នាត ស្មើនឹង ៣ម៉ែត្រកន្លះ។ |
| ៧៣- ជំហាន ន. | រង្វាស់ប្រវែងនៃខ្នាតខ្មែរពីបុរាណ ដែលមានប្រវែងមួយជំហានឈានដើរ ដោយគិតពីត្រឹមកែងជើងក្រោយទៅដល់កែងជើងមុខ (ជំហានមានពីរ គឺជំហានធម្មតា |

| | |
|---|---|
| | និង ដំហានតឹង)។<br>ឧ. ក្បាលដីនេះមាន១៥ដំហាន។ |
| ៧៤- ធ្នាប់ ន. | ខ្នាតរង្វាស់ប្រវែងខ្មែរពីបុរាណ ដោយគិតតាមទទឹងម្រាមដៃនីមួយៗ។<br>មួយធ្នាប់ស្មើមួយភាគដប់ពីរនៃចំអាមឬប្រហែល(២៥/១២ សង់ទីម៉ែត្រ)។<br>- មួយធ្នាប់ គិតប្រវែងទទឹងម្រាមចង្អុលដៃ។<br>- ពីរធ្នាប់ គិតប្រវែងទទឹងម្រាមចង្អុលដៃនិងម្រាមចង្អុលខ្មោច។<br>- បីធ្នាប់ គិតប្រវែងទទឹងម្រាមចង្អុលដៃ ម្រាមចង្អុលខ្មោច និង ម្រាមនាងដៃ។<br>- បួនធ្នាប់ គិតប្រវែងទទឹងម្រាមចង្អុលដៃ ម្រាមចង្អុលខ្មោច ម្រាមនាងដៃ និង ម្រាមកូនដៃ។ |
| ៧៥- ទះ ន. | ខ្នាតរង្វាស់ប្រវែងខ្មែរពីបុរាណ ដោយគិតប្រវែងទទឹងបាតដៃផ្កាប់។<br>ឧ. កំណាត់សំពត់រហែកប្រវែងមួយទះដៃ។ |
| ៧៦- ចាប់ ន. | ខ្នាតរង្វាស់ទំហំខ្មែរពីបុរាណ ដែលគេអាចក្ដោបពេញបាតដៃ(ដោយគិតពីចុងម្រាមមេដៃ ដល់ចុងម្រាមចង្អុលខ្មោច ទៅលើរបស់ផ្សេងៗបានមួយជុំ ហៅមួយចាប់។<br>ឧ. ស្មៅមួយចាប់។ |
| ៧៧- ឱប ន. | ខ្នាតរង្វាស់ទំហំខ្មែរពីបុរាណ ដែលគិតជារង្វង់ ដោយយកដៃទាំងពីរព័ទ្ធរួបចូលជិតដល់ទ្រូងដោយប្រទល់ចុងម្រាមដៃចង្អុលខ្មោច។<br>ឧ. ដើមឈើមួយឱប។ |
| ៧៨- រ៉ៃ ន. | ខ្នាតរង្វាស់ផ្ទៃក្រឡាពីបុរាណ ស្មើចំនួនផ្ទៃដី ៤ងារ គឺប្រវែង ២០ព្យាម ៤ជ្រុង ត្រូវជា៤០០ព្យាមក្រឡា ឬ មួយជ្រុងៗប្រវែងប្រហែល ៤០ម៉ែត្រ បើគិតជាផ្ទៃក្រឡាប្រហែល ១ ៦០០ម៉ែត្រការ៉េ (ម៉ែត្រទ្វេគុណ)។<br>ឧ. ដីដាំដំណាំទំហំមួយរ៉ៃ។ |
| ៧៩- ងារ ន. | ខ្នាតរង្វាស់ពីបុរាណ ដែលមានផ្ទៃដីទំហំ ១០ព្យាម៤ជ្រុង ត្រូវជា ១០០ព្យាមក្រឡា ប្រហែល ២០ម៉ែត្រ៤ជ្រុង ឬ ៤០០ម៉ែត្រការ៉េ។<br>ឧ. ភ្ជួរស្រែមួយព្រឹកបានពីរងារ។ |
| ៨០- ទ្រទ្វង ន. | ខ្នាតរង្វាស់កម្ពស់ខ្មែរពីបុរាណ ដែលគិតពីចុងជើងជំទើតត្រង់ទៅចុងម្រាមដៃដែលលើកឡើងលើ។<br>ឧ. ទឹកជម្រៅពីរទ្រទ្វង។ |
| ៨១- នឹម ន. | ខ្នាតឯកតាខ្មែរពីបុរាណ ដែលកំណត់ចំនួនសត្វពាហនៈមានគោឬក្របីចំនួនពីរដែលនៅក្នុងនឹមរទេះឬនង្គ័លតែមួយ។<br>ឧ. គោមួយនឹមកំពុងភ្ជួរស្រែ។ |

| | |
|---|---|
| ៨២- គូ ន. | ខ្នាតឯកតាខ្មែរពីបុរាណ ដែលកំណត់ចំនួនពីរផ្ទឹមគ្នា។<br>ឧ. សត្វលលកមួយគូ ស្បែកជើងមួយគូ ចង្កឹះមួយគូ។ |
| ៨៣- ដំប ន. | ខ្នាតឯកតាខ្មែរពីបុរាណ ដែលជាទូទៅកំណត់ចំនួនពីរគូឬចំនួន៤។ ពាក្យសម្រាប់ប្រើរាប់ផ្លែឈើ កណ្តាប់សំណាប ឬ សត្វតូចៗ។<br>ឧ. ផ្លែស្វាយបីដំបឬស្វាយ១២ផ្លែ។ |
| ៨៤- ផ្លូន ន. | ខ្នាតឯកតាខ្មែរពីបុរាណដែលរាប់ចំនួន១០ដំបស្មើនឹងចំនួន៤០។<br>ឧ. ពោតមួយផ្លូន។ |
| ៨៥- ស្លឹក ន. | ខ្នាតឯកតាខ្មែរពីបុរាណដែលរាប់ចំនួន១០ផ្លូនស្មើនឹងចំនួន៤០០។<br>ឧ. ពោតមួយស្លឹក។ |
| ៨៦- ស្ទើ ន. | ខ្នាតឯកតាខ្មែរពីបុរាណសម្រាប់រាប់ស្លឹកម្លូ ដែលចាប់ផ្តួបត្រួតលើគ្នាចំនួនពីរសន្លឹក។<br>ឧ. ម្លូពីរស្ទើ (បួនសន្លឹក)។ |
| ៨៧- ត្របក ន. | ខ្នាតឯកតាខ្មែរពីបុរាណសម្រាប់រាប់ស្លឹកម្លូមួយដុំ ដែលមានចំនួន១០ស្ទើ គឺ២០សន្លឹក។<br>ឧ. ម្លូមួយត្របក។ |
| ៨៨- ឡូ ន. | ខ្នាតឯកតាខ្មែរពីបុរាណដែលមានចំនួន១២។<br>ឧ. ចានមួយឡូ, សៀវភៅមួយឡូ។ |
| ៨៩- នាលិ ឬ នាឡិ ន. | រង្វាល់ខ្មែរពីបុរាណ ធ្វើពីត្រឡោកដូង ប្រើសម្រាប់វាល់គ្រាប់ធញ្ញជាតិ មានអង្ករ សណ្តែក ល្ង ជាដើម។ |
| ៩០- តៅ *ន.* | រង្វាស់រង្វាល់ខ្មែរពីបុរាណ សម្រាប់វាល់គ្រាប់ធញ្ញជាតិ មានស្រូវ អង្ករ ជាដើម។ ស្រូវមួយតៅមានទម្ងន់ ១២គីឡូក្រាម, អង្ករមួយតៅមានទម្ងន់ ១៥គីឡូក្រាម។ |
| ៩១- ថាំង *ន.* | រង្វាស់រង្វាល់ខ្មែរពីបុរាណ ដែលមានចំណុះស្មើពីរតៅ។<br>ឧ. ស្រូវបីថាំង។ |
| ៩២- ដឹក *ន.* | រង្វាស់រង្វាល់ខ្មែរពីបុរាណ សម្រាប់វាល់ស្រូវ ចំណុះ ២០ថាំង ដែលអាចដឹកបានដោយរទេះគោឬក្របី។<br>ឧ. ស្រូវមួយដឹក។ |
| ៩៣- ខ្នាញ់ *ន.* | ខ្នាតឯកតាខ្មែរបុរាណ ដែលរាប់ចំនួន ១០ស្លឹក ស្មើនឹងចំនួន ៤ ០០០។<br>ឧ. ស្លាមួយខ្នាញ់។ |
| ៩៤- ហាប *ន.* | ខ្នាតខ្មែរបុរាណ ដែលមានទម្ងន់ ១០០នាឡិឬពីរចុង(ប្រហែល ៦០គីឡូក្រាម)។<br>ឧ. ប្រហុកមួយហាប, ជ្រូកមួយហាប, ស្រូវមួយហាប។ |

| | |
|---|---|
| ៩៥- ចុង *ន.* | ខ្នាតខ្មែរបុរាណ ដែលមានទម្ងន់ កន្លះហាបឬ៥០នាឡិ(ប្រហែល ៣០គីឡូក្រាម)។<br>ឧ. អង្ករមួយចុង។ |
| ៩៦- តម្លឹង *ន.* | ខ្នាតខ្មែរពីបុរាណ ដែលមានទម្ងន់ ១/១៦នាឡិឬ១០ជី ប្រមាណ ៣៧,៥ក្រាម ។<br>ឧ. មាសពីរតម្លឹង។ |
| ៩៧- ជី *ន.* | ខ្នាតខ្មែរពីបុរាណ ដែលមានទម្ងន់ ១/១០តម្លឹងឬ១០ហ៊ុន ប្រមាណ៣,៧៥ក្រាម។<br>ឧ. មាសមួយជី។ |
| ៩៨- ហ៊ុន *ន.* | ខ្នាតខ្មែរពីបុរាណ ដែលមានទម្ងន់ ១/១០ជីឬ១០លី ប្រមាណ ០,៣៧៥ក្រាម។<br>ឧ. មាសពីរហ៊ុន។ |

# បច្ចេកសព្ទរបស់គណៈកម្មការភាសាវិទ្យា និង អក្សរសិល្ប៍ ដែល គ.ជ.ភ.ខ. បានអនុម័ត

## I- បច្ចេកសព្ទភាសាវិទ្យា :

| | |
|---|---|
| ១- សទិសសព្ទ<br>អ. homonym<br>បារ. homonyme (m.) | ពាក្យដែលមានន័យផ្សេងគ្នា តែមានរូបដូចគ្នា ឬ មានសូរដូចគ្នា។ សទិសសព្ទ អាចចែកជាពីរក្រុម គឺ<br>- សទិសលេខ (homographe) : ពាក្យដែលមានសំណេរដូចគ្នា<br>ឧ. *លិច* (ទិសខាងលិច) និង *លិច* (ថ្ងៃលិច)<br>- សទិសសូរ (homophone) : ពាក្យដែលមានសូរដូចគ្នា<br>ឧ. *លិច* (ថ្ងៃលិច) និង *លេច* (លេចចេញ, លេចឡើង)<br>*គុន* (គុនដាវ, គុនដំបង) និង *គុណ* (គុណមាតាបិតា, គុណគ្រូ), ...។<br><u>កំណត់សម្គាល់</u> : សទិសសព្ទ អាចជាសទិសសូរផង អាចជាសទិសលេខផងទៀត។<br>ឧ. *ភ្លឺ* (ភ្លឺស្រែ) និង *ភ្លឺ* (ជំងឺភ្លឺ), ...។ |
| ២- ន័យតា<br>អ. component<br>បារ. sème (m.) | ពាក្យ *ន័យតា* ជាបម្រែនៃពាក្យ "sème" របស់លោក ប៉ែរណា ប៉ូជេ (Bernard Pottier) ដែលភាសាវិទូអាមេរិកាំងហៅថា "component"។ ន័យតាជាបំណែកន័យ ដែលអាចវិភាគចេញពីវចនតា/ពីពាក្យទោលណាមួយ។<br>ឧទាហរណ៍ :<br>• ចូល → + ក្នុង<br>+ កិរិយាសព្ទ<br>- កម្មបទ (C.d'objt)<br>+ ចលនា |

• ចេញ →
- ក្នុង
+ កិរិយាសព្ទ
- កម្មបទ (C.d'objt)
+ ចលនា

## ៣- **វេវចនសព្ទ**

អ. synonym

បារ. synonyme (m.)

ពាក្យពីរម៉ាត់ឬវាចាវិលាស (locution) ពីរម៉ាត់ ឬក៏ ច្រើនម៉ាត់ ជាវេវចនសព្ទនឹងគ្នា កាលណាពាក្យឬវាចាវិលាសនោះមានប្រភេទដូចគ្នានិងអាចជំនួសគ្នាបានក្នុងល្បះដោយឥតបណ្ដាលឱ្យល្បះមានន័យផ្សេង, ឧទាហរណ៍ :

- *គាត់បាន__**លាចាកលោក**__ច្រើនឆ្នាំហើយ ។*
- *គាត់បាន__**ទទួលមរណភាព**__ច្រើនឆ្នាំហើយ ។*

តាមធម្មតា ពាក្យពីរម៉ាត់ដែលជាវេវចនសព្ទនឹងគ្នា មិនមានន័យដូចគ្នាបេះបិទទេ : គេមិនអាចប្រើវាជំនួសគ្នាបានគ្រប់ករណីទេ ឬ វាជំនួសគ្នាបាន ប៉ុន្តែ សណ្ឋានភាសា (registres) មានកម្រិតខុសគ្នា, ឧទាហរណ៍ :

__ករណីដែលគេមិនអាចជំនួសវេវចនសព្ទជាទូទៅបាន__ :

- __ភាសាបារាំង__ :
  - Le bec aigu = Le bec pointu (aigu = pointu)
  - Le son aigu គ្មាន * le son pointu ជាវេវចនសព្ទទេ (aigu ≠ pointu)
- __ភាសាខ្មែរ__ :
  - ធ្វើការលឿន = ធ្វើការរហ័ស,
  - រត់លឿន ≠ * រត់រហ័ស ។

__ករណីដែលវេវចនសព្ទមានសណ្ឋានភាសាខុសគ្នា__ :

- *ប្ដី* (សណ្ឋានភាសាធម្មតា), *ស្វាមី* (សណ្ឋានភាសាខ្ពស់)
- *ស៊ី* (សណ្ឋានភាសាទាប), *ហូប* (សណ្ឋានភាសាធម្មតា), *ពិសា* (សណ្ឋានភាសាខ្ពស់), ...។

## ៤- **បដិសព្ទ**

អ. antonym

បារ. antonyme (m.)

ពាក្យទាំងឡាយដែលមានន័យផ្ទុយគ្នា , ឧទាហរណ៍ :

- __ក្នុងភាសាខ្មែរ__ :
  - • ពាក្យ *ញី* ជាបដិសព្ទរបស់ពាក្យ *ឈ្មោល,*
  - • ពាក្យ *ទិញ* ជាបដិសព្ទរបស់ពាក្យ *លក់ ,...*
- __ក្នុងភាសាបារាំង__ :
  - • ពាក្យ *mâle* ជាបដិសព្ទរបស់ពាក្យ *femelle ,*
  - • ពាក្យ *acheter* ជាបដិសព្ទរបស់ពាក្យ *vendre ,...*

បដិសព្ទមានព្រំដែនមិនជាក់លាក់ ព្រោះវាអាចជា :

-បដិសព្ទសម្គាល់ភាពប្រៀបធៀប (opposition) : *តូច* និង *ធំ ,*

-បដិសព្ទសម្គាល់ប្រតិភាព ឬ ទៅវិញទៅមក (réciprocité) : *ទិញ* និង *លក់ , ប្ដី* និង *ប្រពន្ធ ,...*

-បដិសព្ទសម្គាល់ភាពដៃគូនឹងគ្នា (complémentarité) : *រស់* និង *ស្លាប់ ,*

| | |
|---|---|
| **៥- មហាសព្ទ**<br>អ. superordinate<br>បារ. hyperonyme (m.) | ពាក្យដែលមានន័យគ្របដណ្ដប់លើពាក្យផ្សេងទៀតដែលជាអនុសព្ទ , ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>• ពាក្យ *សត្វ* ជាមហាសព្ទ ព្រោះវាមានន័យគ្របដណ្ដប់លើពាក្យ *ឆ្មា ឆ្កែ សេះ ខ្លា មាន់* ,... ។ ពាក្យ *ឆ្មា ឆ្កែ សេះ មាន់ ខ្លា* ជាអនុសព្ទ ។<br>• ពាក្យ *រុក្ខជាតិ* ជាមហាសព្ទ ព្រោះវាមានន័យគ្របដណ្ដប់លើពាក្យ *ស្វាយ ដូង ខ្នុរ ចេក*,...។ ពាក្យ *ស្វាយ ដូង ខ្នុរ ចេក* ជាអនុសព្ទ ។<br>- <u>ក្នុងភាសាបារាំង</u> : ពាក្យ rouge ជាមហាសព្ទ ឯពាក្យ *écarlate , cramoisi , vermillon, pourpre* ជាអនុសព្ទ ។ |
| **៦- អនុសព្ទ**<br>អ. hyponym<br>បារ. hyponyme (m.) | ពាក្យដែលមានន័យចំណុះឱ្យពាក្យមួយទៀតដែលជាមហាសព្ទ , ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>• ពាក្យ *ឆ្កែ* ជាអនុសព្ទ ធៀបនឹងពាក្យ *សត្វ* ដែលជាមហាសព្ទ ,<br>• ពាក្យ *ម៉ូតូ* ជាអនុសព្ទ ធៀបនឹងពាក្យ *យានយន្ត* ដែលជាមហាសព្ទ ,...<br>- <u>ក្នុងភាសាបារាំង</u> :<br>• ពាក្យ *écarlate* ជាអនុសព្ទ ធៀបនឹងពាក្យ *rouge* ដែលជាមហាសព្ទ ,<br>• ពាក្យ *chat* ជាអនុសព្ទ ធៀបនឹងពាក្យ *animal* ដែលជាមហាសព្ទ ។ |
| **៧- ពាក្យសម្រាល/ប្រិយសព្ទ**<br>អ. euphemism<br>បារ. euphémisme (m.) | ការប្រើពាក្យឬឃ្លាដែលមានន័យមិនទ្រគោះ ដើម្បីជំនួសពាក្យឬឃ្លាដែលមានន័យទ្រគោះ, ឧទាហរណ៍ :<br>- <u>ភាសាបារាំង</u> :<br>•*Pierre n'est pas très courageux* ជាពាក្យសម្រាល (ដែលមានន័យមិនទ្រគោះ) សម្រាប់ជំនួស *Pierre est un lâche* (ឃ្លាដែលមានន័យទ្រគោះ ចំពោះ *Pierre*) ។<br>- <u>ភាសាខ្មែរ</u> :<br>• *មិនប្រក្រតី* ជា **ពាក្យសម្រាល**ជំនួសវិញ្ញត្តិដែលមានន័យទ្រគោះមួយចំនួនធំ,<br>• *ស្រីមេអំបៅ/ស្រីប្រកបរបរផ្លូវភេទ/ស្រីរកស៊ីផ្លូវភេទ* ជំនួស *ស្រីពេស្យា*,... ។ |
| **៨- សូរសម្រួល**<br>អ. euphony<br>បារ. euphonie (f.) | សូរដែលកើតពីការប្រែប្រួលសូរណាមួយក្នុងពាក្យខ្លះ ដើម្បីឱ្យស្រួលត្រចៀកឬស្រួលអាន ច្រើនកើតមានឡើងក្រោមឥទ្ធិពល នៃការសម្រួលសូរ នៃការសម្របសូរ ឬ នៃការបំប្លែកសូរ, ឧទាហរណ៍ :<br>- <u>ភាសាបារាំង</u> :<br>•pendant [pɑ̃dɑ̃] > [pɑ̃<u>n</u>ɑ̃],<br>•une heure et demie [ynœredəmi] > [ynœredmi] > [ynœre<u>**n**</u>mi], |

| | |
|---|---|
| | - <u>ភាសាខ្មែរ</u> :<br>• អាឯង > អាហ្អែង,<br>• សង្ឃរាជ > សង្គ្រាជ, ...<br><u>បញ្ជាក់</u> : ពាក្យខាងក្រៅឃ្នាបសរសេរជាអក្ខរាវិរុទ្ធ , ពាក្យខាងក្នុងឃ្នាប សរសេរជាសញ្ញាសូរវិធី។ |
| **៩- វាចាវិលាស**<br>អ. locution<br>បារ. locution (f.) | កន្សោមពាក្យផ្សារជាប់ (ដូចពាក្យសមាសដែរ) ប៉ុន្តែ វេយ្យាករណ៍បុរាណបារាំង ប្រើសម្រាប់កន្សោមផ្សារជាប់ដែលសម្គាល់ប្រភេទពាក្យ, ឧទាហរណ៍ :<br>- <u>locutions verbales</u> :<br>• prendre parole = parler ;<br>• mettre le feu = allumer.<br>- <u>locutions adverbiales</u> :<br>• de manière lente = lentement,<br>• avec rapidité = rapidement.<br>- <u>locutions prépositionnelles</u> :<br>• à l'aide de = avec,<br>• en dépit de = malgré , ...<br>យើងអាចនិយាយបានថា ភាសាខ្មែរក៏មានវាចាវិលាសដែរ, ឧទាហរណ៍ :<br>- <u>វាចាវិលាសកិរិយា</u> :<br>• ជ្រុលមាត់ = ជ្រុលសម្ដី (និយាយខុស ហើយ ស្ដាយក្រោយ),<br>• ចូលចិត្ត = ពេញចិត្ត , ស្រឡាញ់, និយម, ...។<br>- <u>វាចាវិលាសកិរិយាវិសេសន៍</u> :<br>• ដោយយកចិត្តទុកដាក់,<br>• យ៉ាងលឿន, ...។<br>(ប្រភព : តឺប យក់ ថាវ គន្ធ : វចនានុក្រម បារាំង-ខ្មែរ សង្ខេប, អាគារបោះផ្សាយវប្បធម៌, ឆ្នាំ១៩៨៩, ទំព័រ ៧៤៥។) |
| **១០- សំនួន/វិញ្ញត្តិ**<br>អ. expression<br>បារ. expression (f.) | តាមន័យទូទៅ គឺជាពាក្យឬកន្សោមពាក្យ ដែលបញ្ជាក់គំនិតឬមនោសញ្ចេតនា ដើម្បី រំលេចន័យគន្លឹះក្នុងល្បះ។<br><u>បញ្ជាក់</u> : ក្នុងភាសាវិទ្យារបស់លោក Louis Hjelmslev ពាក្យ expression មានន័យពិសេស ផ្សេងពីន័យខាងលើ។ |
| **១១- សម្ព័ន្ធវិទ្យា**<br>អ. syntax<br>បារ. syntaxe (f.) | ផ្នែកមួយនៃវេយ្យាករណ៍ ដែលក្នុងនោះ សទ្ទតាវិទ្យានិងវចនវិទ្យា ជាផ្នែកពីរទៀត។ សម្ព័ន្ធវិទ្យាសិក្សាអំពីវិធីចងក្រងពាក្យឱ្យទៅជាល្បះ ដែលក្នុងនោះ ប្រភេទពាក្យឥត មានលំដាប់ដូចគ្នាទេ ពីភាសាមួយទៅភាសាមួយ :<br>- ប្រភេទពាក្យនិងមុខងារវាក្នុងល្បះខ្មែរ មានលំដាប់ប្រហាក់ប្រហែលនឹងលំដាប់ក្នុង ល្បះនៃភាសាមួយចំនួន មាន បារាំងឬអង់គ្លេស ជាដើម, ឧទាហរណ៍ : |

| | |
|---|---|
| | • <u>ល្បះខ្មែរ</u> : គាត់ស្រឡាញ់កញ្ញាបុប្ផា.<br>• <u>ល្បះបារាំង</u> : Il aime Mademoiselle Bopha .<br>- ប្រភេទពាក្យនិងមុខងារវាក្នុងល្បះនៃភាសាម៉ាល់ហ្គាស ( នៅក្នុងក្រុមភាសាឥណ្ឌូណេស៊ី) មានលំដាប់ដូចខាងក្រោម :<br>• Miteny anglisy aho.<br>parle anglais je.<br>- ចំពោះភាសាមួយចំនួនទៀត ប្រភេទពាក្យមានលំដាប់និងមុខងារក្នុងល្បះផ្សេងៗគ្នា (ភាសាបាស្ក (basque) ប្លែកពីភាសាខ្លះទៀត, ...) ។<br>បើគេពិនិត្យមើលសម្ព័ន្ធពីភាសាមួយទៅភាសាមួយ គឺគេសិក្សាអំពីសម្ព័ន្ធវិទ្យាទូទៅ ។ បើគេសិក្សាអំពីសម្ព័ន្ធវិទ្យារបស់ភាសាណាមួយ សម្ព័ន្ធវិទ្យាមានឈ្មោះថា សម្ព័ន្ធវិទ្យានៃភាសានោះឯង ។ ដោយសម្ព័ន្ធវិទ្យាសិក្សាអំពីល្បះ និង ដោយល្បះមានច្រើនប្រភេទ ដូច្នេះ សម្ព័ន្ធវិទ្យាត្រូវសិក្សាអំពីប្រភេទល្បះ អំពីវាចកៈ ។ល ។ |
| **១២- អនុប្រយោគ/ ឃ្លា**<br>អ. clause<br>បារ. proposition (f.) | អនុប្រយោគជាផ្នែកមួយនៃល្បះ/ប្រយោគដែលមានកិរិយាសព្ទស្នូលតែមួយ ។<br>ឧទាហរណ៍ : - ខ្ញុំស្គាល់មនុស្សម្នាក់ ។<br>- ភ្នំពេញជារាជធានីប្រទេសកម្ពុជា ។<br>អនុប្រយោគអាចជា អនុប្រយោគគោល (proposition principale) ឬ អនុប្រយោគរណប (proposition subordonnée) ។<br>ឧ. ល្បះ "*ខ្ញុំបានជួបបុរសម្នាក់ដែលជាអ្នកកាសែត ។*" មានពីរអនុប្រយោគ គឺ<br>- អនុប្រយោគគោល : "*ខ្ញុំបានជួបបុរសម្នាក់*"<br>- អនុប្រយោគរណប : "*ដែលជាអ្នកកាសែត*" ។ |
| **១៣- ល្បះ /ប្រយោគ**<br>អ. sentence<br>បារ. phrase (f.) | ល្បះ/ប្រយោគ ជាបង្គុំពាក្យដែលមានន័យសេចក្តីពេញលេញស្តាប់បាន ។ ល្បះ/ប្រយោគត្រូវមានកន្សោមនាមប្រធាន និង កន្សោមកិរិយា ( ប្រណាប់ប្រធាន/បម្រាប់ប្រធាន) ។<br>ឧទាហរណ៍ : - សិស្សានុសិស្សទៅសាលារៀន ។<br>- គាត់បានជួបមិត្តសម្លាញ់របស់គាត់នៅក្នុងសុបិន ។<br>ល្បះ/ប្រយោគមានច្រើនប្រភេទ គឺ :<br>- ល្បះប្រកាស/ប្រយោគប្រកាស ( ល្បះបញ្ជាក់ ) (phrase déclarative)<br>- ល្បះសំណួរ/ប្រយោគសំណួរ (phrase interrogative)<br>- ល្បះបញ្ជា/ប្រយោគបញ្ជា (phrase impérative)<br>- ល្បះឧទាន/ប្រយោគឧទាន (phrase exclamative) ។<br>១- ល្បះប្រកាស/ប្រយោគប្រកាស : ល្បះ/ប្រយោគដែលគេប្រើសម្រាប់អះអាងឱ្យដឹងរឿងអ្វីមួយ ។<br>ឧទាហរណ៍ :<br>- *លោកគ្រូមកដល់ហើយ ។* |

| | |
|---|---|
| | - *លោកនាយកមិនទៅទេ ។*<br>២- ល្បះសំណួរ/ប្រយោគសំណួរ : ល្បះ/ប្រយោគដែលគេប្រើសម្រាប់សួរចង់ដឹង អំពីអ្វីមួយ ដោយប្រើពាក្យសួរ ( តើ..., ...ឬ...ឬទេ,...) ឬ លើកសំឡេង នៅខាងចុងល្បះ ។<br>ឧទាហរណ៍ :<br>- *(ឯង) យល់ព្រមឬទេ?*<br>- *ថ្ងៃនេះ វាមិនទៅរៀនទេ (ឬ) ?*<br>៣- ល្បះបញ្ជា/ប្រយោគបញ្ជា : ល្បះដែលគេប្រើសម្រាប់បង្គាប់បញ្ជា ផ្ដល់ដំបូន្មាន ឬ ហាមប្រាម ។<br>ឧទាហរណ៍ :<br>- *ចូរ(អ្នក) រៀបចំបន្ទប់ឱ្យបានស្អាត ។*<br>- *(អ្នកទាំងអស់គ្នា) ត្រូវខិតខំរៀនសូត្រ ។*<br>- *ហាមខាកស្ដោះ ។*<br>- *កុំជក់បារី ។*<br>៤- ល្បះឧទាន/ប្រយោគឧទាន : ល្បះដែលគេប្រើសម្រាប់សំដែងអំណរ ការរំជួលចិត្ត កំហឹង ការកោតសរសើរ ការងឿងឆ្ងល់ ការភ្ញាក់ផ្អើល... ដែលកើតឡើងភ្លាមៗ ។<br>ឧទាហរណ៍ :<br>- *យី! អស្ចារ្យណាស់!*<br>- *វងាណាស់!*<br>- *នាងឆ្លាតមែន!* |
| **១៤- ល្បះទោល/ប្រយោគទោល**<br>អ. simple sentence<br>បារ. phrase simple (f.) | ល្បះ/ប្រយោគ ដែលមានតែមួយអនុប្រយោគ ។<br>ឧទាហរណ៍ :<br>- *លោកគ្រូមកដល់ហើយ ។*<br>- *លោកនាយកមិនទៅទេ ។*<br>- *ឯងទៅណា?*<br>- *កុំជក់បារី ។* |
| **១៥- ល្បះល្បាយ/ប្រយោគល្បាយ ឬ ល្បះផ្សំ/ប្រយោគផ្សំ**<br>អ. complex sentence<br>បារ. phrase complexe / phrase composée (f.) | ល្បះ/ប្រយោគដែលកើតឡើងដោយសារការផ្សំរវាងឃ្លានិងឃ្លា ដែលក្នុងនោះ មានឃ្លាគោលនិងឃ្លារណប ។ "ឃ្លារណបភ្ជាប់នឹងឃ្លាគោលដោយសារ *ឈ្នាប់ឃ្លា* " ។<br>ឧទាហរណ៍ :<br>- *គាត់ខានមកធ្វើការអស់បីថ្ងៃ ពីព្រោះគាត់ឈឺ ។*<br>- *បើគាត់ត្រឡប់មកវិញ គាត់នឹងបង្ហើយកិច្ចការនេះ ។* |

| | |
|---|---|
| **១៦- ល្បះក្រុង/ប្រយោគក្រុង**<br>អ. juxtapose sentence<br>បារ. phrase juxtaposée (f.) | ល្បះ/ប្រយោគដែលកើតឡើងពីល្បះ/ប្រយោគទោលច្រើននៅបន្តបន្ទាប់គ្នា ឬ ភ្ជាប់គ្នាដោយឃ្នាប់ចង ។<br>ឧទាហរណ៍ : *មាន់រងាវ សេះកញ្ជ្រៀវ គោរោទិ៍ ...* ។ |
| **១៧- ល្បះបដិសេធ/ប្រយោគបដិសេធ**<br>អ. negative sentence<br>បារ. phrase négative (f.) | ល្បះ/ប្រយោគដែលក្នុងនោះគេប្រើអវិជ្ជមានបទ ( មិន....ទេ/ឡើយ, អត់....ទេ / ឡើយ,...) ដើម្បីសំដែងគំនិតអវិជ្ជមាន ។<br>ឧទាហរណ៍ :<br>- *លោកនាយកមិនទៅទេ* ។<br>- *វាអត់ទៅសាលាទេ* ។ |
| **១៨- ល្បះសង្កត់ន័យ/ប្រយោគសង្កត់ន័យ**<br>អ. emphazised sentence<br>បារ. phrase emphatique (f.) | ល្បះ/ប្រយោគដែលក្នុងនោះគេផ្ដោតអារម្មណ៍លើធាតុណាមួយ ( ប្រធានឬកម្មបទ កម្មទេសកាល) នៃល្បះ/ប្រយោគ ។<br>ឧទាហរណ៍ :<br>- *គឺសិស្សនេះហើយ ដែលចូលចិត្តអានសៀវភៅជាងគេ* ។ ( ផ្ដោតលើប្រធាន)<br>- *មនុស្សនេះ ខ្ញុំស្អប់វាណាស់* ។ ( ផ្ដោតលើកម្មបទ)<br>- *គឺទីនេះហើយ ដែលខ្ញុំធ្លាប់រស់នៅកាលពីក្មេង* ។ ( ផ្ដោតលើកម្មទេសកាល) |
| **១៩- វាចកៈ**<br>អ. voice<br>បារ. voix (f.) | ពាក្យប្រាប់នាទីឬដំណើររបស់កិរិយាសព្ទក្នុងសម្ព័ន្ធ ។ វាចកៈមានពីរបែប គឺ<br>- កត្តុវាចកៈ (voix active) គឺ ប្រធាននៃល្បះធ្វើអំពើ ។<br>- កម្មវាចកៈ (voix passive) គឺ ប្រធាននៃល្បះរងអំពើ ហើយ កម្មបទ (C. d'objt) ជាអ្នកធ្វើអំពើ ហៅថា កម្មភ្នាក់ងារ ។<br>ឧទាហរណ៍ក្នុងភាសាអង់គ្លេស :<br>- *John **kills** the dog.* ( កត្តុវាចកៈ)<br>- *The dog **is killed** by John.* ( កម្មវាចកៈ)<br>ឧទាហរណ៍ក្នុងភាសាខ្មែរ :<br>- *លោក នូ ហាច **និពន្ធ**រឿងផ្កាស្រពោន* ។ ( កត្តុវាចកៈ)<br>- *រឿងផ្កាស្រពោន (**ត្រូវបាន**) **និពន្ធ ដោយ** លោក នូ ហាច* ។ ( កម្មវាចកៈ) |
| **២០- ប្រធាន**<br>អ. subject<br>បារ. sujet (m.) | មុខងារនៃពាក្យក្នុងល្បះ/ប្រយោគដែលតាមធម្មតា ជាមុខងារនៃនាមសព្ទឬសព្វនាម ( ទោលឬមានរណប) ឈមនឹងមុខងារនៃកិរិយាសព្ទ ហៅថា *ប្រណាប់ប្រធាន /បម្រាប់ប្រធាន* ។<br>ឧទាហរណ៍ :<br>- ***មាន់**រងាវ* ។<br>- ***មាន់ឈ្មោលរបស់ខ្ញុំ**កំពុងរងាវ* ។<br>- ***វា**ដាស់កសិករឱ្យក្រោកធ្វើការ* ។<br>នាមសព្ទទោលឬមានរណប ***មាន់, មាន់ឈ្មោលរបស់ខ្ញុំ*** និង សព្វនាម ***វា*** ជាប្រធាន ។ |

| | |
|---|---|
| **២១- ប្រណាប់ប្រធាន / បម្រាប់ប្រធាន**<br>អ. predicate<br>បារ. prédicat (m.) | មុខងារនៃពាក្យក្នុងឃ្លា/ប្រយោគដែលតាមធម្មតា ជាមុខងាររបស់កិរិយាសព្ទ។<br>ឧទាហរណ៍ ៖<br>- *មាន់**រងាវ***។<br>- *គោ**ស៊ីស្មៅ***។<br>កិរិយាសព្ទ ***រងាវ, ស៊ីស្មៅ*** ជាប្រណាប់ប្រធាន/បម្រាប់ប្រធាន។ |
| **២២- គុណបទ**<br>អ. attributive adjective<br>បារ. épithète (f.) | មុខងារវេយ្យាករណ៍របស់គុណនាម ដែលប្រើផ្ទាល់ជាមួយនាមសព្ទ។<br>ឧទាហរណ៍ ៖<br>- ផ្ទះ *ធំ* នេះ សង់ជិតផ្លូវពេក។<br>- ខ្ញុំមិនចូលចិត្តមនុស្ស *ចាស់* ដែលខ្ជះខ្ជាទេ។ |



| | |
|---|---|
| **២៣- សូរ**<br>អ. sound<br>បារ. son (m.) | អ្វីដែលត្រចៀកយើងស្ដាប់ឮ បន្ទាប់ពីមានការប៉ះគ្នារវាងក្រដាសត្រចៀកនិងវត្ថុភ្ជោច(រលក) ដែលរសាត់តាមអាកាសចេញមកពីគ្រប់ទិសទី [(ដូចរលកលើទឹកដែលរាលធំទៅៗ កាលណាយើងចោលដុំថ្មឬដុំដី ទៅក្នុងទឹក) ហើយ រលកនោះត្រូវបានកើតចេញពីលំញ័រដែលកើតឡើងពីការប៉ះទង្គិចរវាងកម្លាំងអ្វីមួយ (ការទាញ/ការកូតចាប៉ី/ទ្រ), ការគោះ, ការផ្លុំ, ការជ្រុះ, ការបក់បោក,...) ទៅលើវត្ថុអ្វីមួយ (ខ្សែចាប៉ី/ទ្រ, ស្គរ, ខ្លុយ, កម្រាលឥដ្ឋ, ស្លឹកឈើ,...)]។ |
| **២៤- ផ្លូវខ្យល់**<br>អ. air exit<br>បារ. sortie de l'air (f.) | ផ្លូវដែលខ្យល់ក្នុងសួតចេញមកក្រៅនៅពេលបន្លឺសូរ។ នៅពេលបន្លឺសូរ ខ្យល់ក្នុងសួតធាក់ចេញមកក្រៅ ហើយ រនាំងក្រអូមបិទ ឬ បើកចំហផ្លូវច្រមុះ។<br>- កាលណារនាំងក្រអូមបិទផ្លូវច្រមុះ ខ្យល់ចេញតែតាមមាត់។ សូរដែលកើតឡើងជាសូរមាត់ឬមុខជៈ ដូចជា [p], [b], [f], [v], [s],... ។<br>- កាលណារនាំងក្រអូមបើកចំហ ខ្យល់ចេញតាមមាត់ផង តាមច្រមុះផង។ សូរដែលកើតឡើងជាសូរច្រមុះឬនាសិកជៈ ដូចជា [m], [n], [ɲ], [ŋ],... ។ |
| **២៥- សូរមាត់ / មុខជៈ**<br>អ. oral<br>បារ. orale (f.) | សូរព្យញ្ជនៈដែលពេលបន្លឺ រនាំងក្រអូមបិទផ្លូវច្រមុះ ដើម្បីឱ្យខ្យល់ក្នុងសួតចេញមកក្រៅតែតាមមាត់។ ព្យញ្ជនៈសូរមាត់ ឬ មុខជៈ មាន [p], [b], [f], [v], [s], [k], [kh], [c], [t], [dh], [g],... ។ |
| **២៦- សូរច្រមុះ / នាសិកជៈ**<br>អ. nasal<br>បារ. nasale (f.) | សូរព្យញ្ជនៈដែលពេលបន្លឺ រនាំងក្រអូមបើកចំហ ដើម្បីឱ្យខ្យល់ក្នុងសួតចេញមកក្រៅតាមច្រមុះផង តាមមាត់ផង។ ព្យញ្ជនៈសូរច្រមុះ ឬ នាសិកជៈ មាន [m], [n], [ŋ], [ɲ],... ។ |
| **២៧- សូរផ្ទុះ/សូរស្ទះ**<br>អ. plosive<br>បារ. occlusive (f.) | សូរព្យញ្ជនៈដែលបន្លឺឡើង ដោយមានដំណើរខ្យល់ចេញពីសួតមកប៉ះខ្លាំងនឹងគ្រឿងប្រដាប់បន្លឺសំឡេង បណ្ដាលឱ្យមានបន្ទុះ ដូចជា [p], [b], [t], [d], [k], [g], [m], [n], [ɲ], [ŋ], ជាដើម។ ព្យញ្ជនៈសូរផ្ទុះ ឬ សូរស្ទះ ជាព្យញ្ជនៈដែលមានរង្វះខ្យល់កម្រិតសូន្យ។ |
| **២៨- រង្វះខ្យល់/រង្វះបន្លឺ**<br>អ. aperture<br>បារ. aperture (f.) | រង្វះខ្យល់ដែលបិទ ឬ បើកចំហតូចឬធំ ក្នុងការបង្កើតសូរ។ គេចែករង្វះខ្យល់ជា៩កម្រិត គឺ<br>(១)- រង្វះខ្យល់កម្រិតសូន្យ : ដំណើរខ្យល់ដែលចេញពីសួត ត្រូវប៉ះខ្លាំងនឹងគ្រឿងប្រដាប់បន្លឺសំឡេង បណ្ដាលឱ្យមានបន្ទុះ ដូច្នេះសូរដែលកើតឡើង ជាសូរផ្ទុះ/សូរស្ទះ គឺសូរ [p], [b], [t], [d], [k], [g], [m], [n], [ɲ], [ŋ], ...។<br>(២)- រង្វះខ្យល់កម្រិតកន្លះ : ដំណើរខ្យល់ត្រដុសខ្លាំងនឹងផ្ទៃនៃគុហាមាត់ អណ្ដាត ធ្មេញ (ត្រដុសខ្លាំង ព្រោះរង្វះខ្យល់មានកម្រិតស្ទើរសូន្យ) |

| | |
|---|---|
| | ហើយ បង្កើតសូរផ្ទុះត្រដុស/ស្ទះត្រដុស ដូចជា [tʃ], [dʒ], ...។<br>(៣)- រង្វះខ្យល់កម្រិត១ : ដំណើរខ្យល់ត្រដុសនឹងផ្ទៃនៃគុហាមាត់ អណ្ដាត ធ្មេញ ហើយ បង្កើតសូរត្រដុស ដូចជា [f], [v], [s], [z], ...។<br>(៤)- រង្វះខ្យល់កម្រិត២ : ដំណើរខ្យល់ស្ទើរតែមិនត្រដុសនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ឡើយ ហាក់បីដូចជាមានលំហូរ ហើយ បង្កើតសូរលំហូរ ដូចជា [l], [r], ...។<br>(៥)- រង្វះខ្យល់កម្រិត៣ : ចាប់ពីរង្វះនេះទៅ ដំណើរខ្យល់ឈប់ប៉ះនឹងផ្ទៃ គុហាមាត់ អណ្ដាត ធ្មេញ ទៀតហើយ ហើយ គេបានសូរស្រៈកន្លះ ឬ ព្យញ្ជនៈកន្លះ គឺ [j], [w],...។<br>(៦)- រង្វះខ្យល់កម្រិត៤ : សូរដែលកើតឡើងគឺសូរស្រៈបិទ ដូចជា [i], [y], [u], ...។<br>(៧)- រង្វះខ្យល់កម្រិត៥ : សូរដែលកើតឡើងគឺសូរស្រៈបិទកន្លះ ដូចជា [e], [ø], [ɘ], [o], ...។<br>(៨)- រង្វះខ្យល់កម្រិត៦ : សូរដែលកើតឡើងគឺសូរស្រៈបើកកន្លះ ដូចជា [ɛ], [œ], [ɔ], ...។<br>(៩)- រង្វះខ្យល់កម្រិត៧ : សូរដែលកើតឡើងគឺសូរស្រៈបើក ដូចជា [a], [ɑ], ...។ |
| **២៩- សូរផ្ទុះត្រដុស/សូរស្ទះត្រដុស**<br>អ. affricative<br>បារ. affriquée (f.) | សូរព្យញ្ជនៈដែលបន្លឺឡើងដោយមានបន្សំចូលគ្នារវាងសូរផ្ទុះ/សូរស្ទះជាមួយនឹង សូរត្រដុស (fricative) ដូចជា ៖<br>- ព្យញ្ជនៈ [tʃ] ក្នុងពាក្យ [tʃaild] (child)<br>- ព្យញ្ជនៈ [dʒ] ក្នុងពាក្យ [dʒæm] (jam)<br>នៃភាសាអង់គ្លេស ជាដើម។ |
| **៣០- សូរត្រដុស**<br>អ. fricative<br>បារ. fricative (f.) | សូរព្យញ្ជនៈដែលពេលបន្លឺ ខ្យល់ដែលរត់ចេញពីសួត ត្រដុសនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ហើយ បង្កើតសូរត្រដុស ដូចជា ៖ [f], [v], [s], [z], ...។ ព្យញ្ជនៈសូរត្រដុសជាព្យញ្ជនៈ ដែលមានរង្វះខ្យល់កម្រិត១។ |
| **៣១- សូរលំហូរ/សូរបង្ហូរ**<br>អ. liquid<br>បារ. liquide (f.) | សូរព្យញ្ជនៈដែលពេលបន្លឺ ខ្យល់ដែលរត់ចេញពីសួត ស្ទើរតែមិនត្រដុសនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ឡើយ ហាក់បីដូចជាមានលំហូរ។ ព្យញ្ជនៈលំហូរ ជាព្យញ្ជនៈ ដែលមានរង្វះខ្យល់កម្រិត២។ ព្យញ្ជនៈលំហូរ មាន : [l], [r], ...។ |
| **៣២- អឌ្ឍព្យញ្ជនៈ/ព្យញ្ជនៈកន្លះ**<br>អ. semi consonant<br>បារ. semi-consonne (f.) | សូរព្យញ្ជនៈដែលពេលបន្លឺ ខ្យល់ដែលរត់ចេញពីសួតមិនប៉ះនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ទេ។ អឌ្ឍព្យញ្ជនៈ/ព្យញ្ជនៈកន្លះ ជាព្យញ្ជនៈដែលមានរង្វះខ្យល់ កម្រិត៣។ អឌ្ឍព្យញ្ជនៈ/ព្យញ្ជនៈកន្លះ មាន : [j], [w], ...។<br>គេអាចហៅវាម្យ៉ាងទៀតថា អឌ្ឍស្រៈ/ស្រៈកន្លះ។ |

| | |
|---|---|
| **៣៣- សូរបបូរមាត់/ឱស្ឋជៈ**<br>អ. labial<br>បារ. labiale (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅបបូរមាត់គឺបបូរមាត់លើនិងបបូរមាត់ក្រោមប៉ះគ្នា។<br>ព្យញ្ជនៈសូរបបូរមាត់ មាន : [p], [b], [m], ...។ |
| **៣៤- សូរធ្មេញ/ទន្តជៈ**<br>អ. dental<br>បារ. dentale (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅត្រង់ធ្មេញ គឺចុងអណ្តាតទល់នឹងធ្មេញ។ ព្យញ្ជនៈសូរធ្មេញមាន : [t], [d], [n], ...។ |
| **៣៥- សូរចន្លោះខ្សែសំឡេង**<br>អ. glottal stop<br>បារ. coup (m.) de glotte (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅចន្លោះខ្សែសំឡេង។<br>ព្យញ្ជនៈសូរចន្លោះខ្សែសំឡេង មាន : [ʔ], ...។ |
| **៣៦- សូរដើម ក** | សូរព្យញ្ជនៈដែលមានទីបន្លឺនៅដើម ក។ ព្យញ្ជនៈសូរដើម ក មាន : [h], ...។ |
| **៣៧- ខ្សែសំឡេង**<br>អ. vocal cords<br>បារ. cordes vocales (f.) | បន្ទះសាច់ដុំយឺតមួយគូដែលនៅក្នុងឡារ៉ាំង (larynx)។ នៅពេលបន្លឺសូរព្យញ្ជនៈ ខ្សែសំឡេងអាចញ័រ ឬ មិនញ័រ : បើខ្សែសំឡេងញ័រ ព្យញ្ជនៈនោះជាព្យញ្ជនៈឃោសៈ (voisée/sonore), បើខ្សែសំឡេងមិនញ័រ ព្យញ្ជនៈនោះជាព្យញ្ជនៈអឃោសៈ (non-voisée/sourde)។ ចំពោះការបន្លឺសូរស្រៈវិញ ខ្សែសំឡេងតែងតែញ័រជានិច្ច។ |
| **៣៨-ឃោសៈ**<br>អ. voiced<br>បារ. voisée/sonore (f.) | ព្យញ្ជនៈដែលនៅពេលបន្លឺ មានលំញ័រខ្សែសំឡេង។<br>ព្យញ្ជនៈ / l /, / d /, / b /,... ជាព្យញ្ជនៈឃោសៈ។ |
| **៣៩- អឃោសៈ**<br>អ. unvoiced<br>បារ. non-voisée/sourde (f.) | ព្យញ្ជនៈដែលនៅពេលបន្លឺ ពុំមានលំញ័រខ្សែសំឡេងទេ។<br>ព្យញ្ជនៈ / s /, / t /, / p /,...ជាព្យញ្ជនៈអឃោសៈ។ |
| **៤០- ព្យញ្ជនៈ**<br>អ. consonant<br>បារ. consonne (f.) | សូរដែលបន្លឺឡើងដោយមានទំនប់តិចឬច្រើន អាស្រ័យទៅតាមរង្វះខ្យល់ដែលចេញពីសួត។ នៅពេលដែលខ្យល់ចេញពីសួតទៅប៉ះនឹងទំនប់រង្វះខ្យល់កម្រិតសូន្យ វាបង្កើតបានជាព្យញ្ជនៈស្ទះឬផ្ទុះ ដូចជា [p], [b], [t], [d], [k], [g], [m], [n],...។ កាលណារង្វះខ្យល់មានកម្រិតលើសពីសូន្យ វាបង្កើតបានជាព្យញ្ជនៈស្ទះត្រដុស ដូចជា [tʃ], [dʒ],...។ សូរព្យញ្ជនៈមិនអាចបន្លឺបានច្បាស់ទេ បើសិនជាគ្មានសូរស្រៈនៅអាស្រ័យជាមួយ។ |
| **៤១- ស្រៈ**<br>អ. vowel<br>បារ. voyelle (f.) | សូរដែលបន្លឺឡើងដោយគ្មានទំនប់។<br>ឧទាហរណ៍ : [ɑ], [ɑ:], [ɔ], [ɔ:], [a], [a:], [e], [e:], [o], [o:], ...។ |
| **៤២- សិថិល**<br>អ. unaspirated<br>បារ. non-aspirée (f.) | ព្យញ្ជនៈដែលមិនមានសូរ [h] ផ្សំជាមួយ។ ក្នុងភាសាបាលី សំស្ក្រឹត ព្យញ្ជនៈសិថិលជាព្យញ្ជនៈ ទី១ និង ទី៣ ក្នុងវគ្គទាំង៥ រួមមាន១០តួគឺ ក [k] គ [g] , ច [c] ជ [j] , ដ [ ṭ ] ឌ [ḍ] , ត [t] ទ [d] , ប [p] ព [b]។ |

| | |
|---|---|
| **៤៣- ធនិត**<br>អ. aspirated<br>បារ. aspirée (f.) | ព្យញ្ជនៈដែលមានសូរ [h] ផ្សំជាមួយ ។ ក្នុងភាសាបាលី សំស្ក្រឹត ព្យញ្ជនៈធនិតមាន : [ក្ខ/kh] , [គ្ឃ/gh] ,[ច្ឆ/ch] , [ជ្ឈ/jh] , [ដ្ឋ/ ṭ h] , [ឌ្ឍ/ḍh] , [ត្ថ/th] , [ទ្ធ/dh] , [ប្ផ/ph] , [ព្ភ/bh] ។ |
| **៤៤- ទីបន្លឺ**<br>អ. place of articulation<br>បារ. point d’articulation (m.) | ចំណុចនៅផ្នែកខាងលើនៃគុហាមាត់ (ធ្មេញលើ ជើងធ្មេញលើ ក្រអូម រនាំងក្រ អូម ចុងរនាំងក្រអូម/កន្ទើត...) ដែលអណ្ដាតធ្វើចលនាទៅប៉ះ ដើម្បីបង្កើតសូរណាមួយ ។ |
| **៤៥- សូរជើងធ្មេញ/សូរគន្លាក់ក្រអូម**<br>អ. alveolar<br>បារ. alvéolaire (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅជើងធ្មេញ គឺចុងអណ្ដាតទល់នឹងជើងធ្មេញមុខ ។<br>ព្យញ្ជនៈសូរជើងធ្មេញ មាន : [ţ], [ɖ],... ។ |
| **៤៦- សូរមុខក្រអូម**<br>អ. pre-palatal<br>បារ. pré-palatale (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅមុខក្រអូម គឺខ្នងអណ្ដាតទល់នឹងផ្នែកនៃគុហាមាត់ដែលស្ថិតនៅមុខក្រអូម ។<br>ព្យញ្ជនៈសូរមុខក្រអូម មាន : [ ʃ ], [ ʒ ],... ។ |
| **៤៧- សូរក្រអូម**<br>អ. palatal<br>បារ. palatale (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅត្រង់ក្រអូម គឺខ្នងអណ្ដាតទល់នឹងក្រអូម ។<br>ព្យញ្ជនៈសូរក្រអូម មាន : [ c ], [ ɟ ], [ ɲ ],... ។ |
| **៤៨- សូររនាំងក្រអូម**<br>អ. velar/guttural<br>បារ. vélaire (f.) / gutturale (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅត្រង់រនាំងក្រអូម គឺអណ្ដាតក្រោយទល់នឹងរនាំងក្រអូម ។<br>ព្យញ្ជនៈសូររនាំងក្រអូម មាន : [ k ], [ g ], [ŋ], ... ។ |
| **៤៩- សទ្ទតា**<br>អ. phoneme<br>បារ. phonème (m.) | ឯកតាសូរតូចបំផុតរបស់ភាសា ដែលមិនអាចបំបែកបាន គ្មានន័យក្នុងខ្សែសម្ដី និងមានមុខងារសម្រាប់ធ្វើឱ្យពាក្យពីរក្នុងបរិបទតែមួយ មានន័យប្លែកគ្នា ។ |
| **៥០- អតិសទ្ទតា**<br>អ. archiphoneme<br>បារ. archiphonème (m.) | សទ្ទតាពីរផ្សេងគ្នា ដែលមានសូរច្រឡំគ្នាត្រង់ទីតាំងសូរខ្លះ ក្នុងពាក្យ ។ ឧទាហរណ៍ : ភាសាអាល្លឺម៉ង់ មានសទ្ទតា /t/ , /d/ ប្លែកគ្នា ប៉ុន្តែក្នុងពាក្យ *rad* និង ពាក្យ *rat* , *d* និង *t* មានសូរច្រឡំគ្នា ទើបគេសន្មតយក [T] សម្រាប់តាង ។ ដូច្នេះ ពាក្យ *rad* និង ពាក្យ *rat* តាងដោយ [raT] ។ |
| **៥១- កាឡាសូរ**<br>អ. allophone<br>បារ. allophone (m.) | សូរប្លែកគ្នារបស់សទ្ទតាតែមួយ (ស្រៈ ព្យញ្ជនៈ) តែគ្មានមុខងារធ្វើឱ្យពាក្យពីរមានន័យប្លែកគ្នាទេ ។ កាឡាសូរអាចជា កាឡាសូរចែកទីតាំងគ្នា (allophones en distribution complémentaire) ឬ ជាកាឡាសូរជំនួសគ្នាបាន/កាឡាសូរសេរី (allophones en variation libre) ។<br>ឧ. ក្នុងភាសាបារាំង តំបន់ខាងជើង<br>[o] & [ɔ] ជាកាឡាសូរចែកទីតាំងគ្នា : |

| | |
|---|---|
| | - [o] សម្រាប់ព្យាង្គបើក : la chaux [ʃo]<br>- [ɔ] សម្រាប់ព្យាង្គបិទ : la chose [ʃɔz] ;<br>ក្នុងភាសាខ្មែរ<br>[o] & [oː] ជាកាឡាសូរជំនួសគ្នាបាន/កាឡាសូរសេរី ព្រោះគេអាចនិយាយ ថា *សុំ* [som] ក៏បាន *សូម*[soːm] ក៏បាន។ |
| **៥២- សញ្ញាតាបន្លឺ**<br>អ. feature of articulation<br>បារ. trait articulatoire (m.) | លក្ខណៈបន្លឺរបស់សទ្ទតា ( ស្រៈ ព្យញ្ជនៈ ) ដែលផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួនដូចតទៅ :<br>- ផ្លូវខ្យល់<br>- រង្វះខ្យល់/រង្វះបន្លឺ<br>- ទីបន្លឺ<br>- មាន/គ្មាន លំញ័រខ្សែសំឡេង ( សម្រាប់ព្យញ្ជនៈ )<br>- ...<br>ឧទាហរណ៍ :<br>• សញ្ញាតាបន្លឺរបស់ព្យញ្ជនៈ [d] គឺ<br>- សូរមាត់/មុខជះ<br>- សូរស្ទះ/ផ្ទុះ<br>- សូរធ្មេញ/ទន្តជះ<br>- ឃោសៈ/ឮ<br>• សញ្ញាតាបន្លឺរបស់ស្រៈ [i] គឺ<br>- ស្រៈសូរមាត់<br>- ស្រៈបិទ<br>- ស្រៈមុខ<br>- ស្រៈបបូរមាត់រីង។ |

**II- បច្ចេកសព្ទអក្សរសិល្ប៍ :**

| | |
|---|---|
| ១- ចេតនារូបារម្មណ៍ | រូបារម្មណ៍ដែលកវី អ្នកនិពន្ធ បង្កើតឡើង ហើយ អធិប្បាយតាមរយៈការប្រើពាក្យពេចន៍ ឃ្លាប្រយោគ នៅក្នុងអត្ថបទពាក្យកាព្យ ពាក្យកម្រងកែវ ពាក្យរាយ ធ្វើឱ្យអ្នកអានមានចិត្តរំភើប ជឿស្លុងទៅដោយមនោសញ្ចេតនា ទុក្ខព្រួយ សប្បាយ កំហឹង ភ័យខ្លាច ត្រេកត្រអាល សង្ស័ម អស់សង្ឃឹម ស្រឡាញ់ ស្អប់ ឬ ការទទួលយកជំនឿណាមួយដោយពុំចាំបាច់ពិចារណាវែងឆ្ងាយឡើយ។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ<br>[...] *ទុំស្រែកថាឱព្រះពាយផាត់ ទាវអើយបែកបាត់ជុំពិដោរ*<br>*ជាប់តែក្លិនក្លែបអែបគន្ធ- សេរូបទាវចោរចើកចោលប្តី។*<br>*ឱ្យនៅតែឯងតែអញសោះ ទាវគ្មានស្រណោះកោតចិត្តស្រី*<br>*ចិត្តស្រស់ឥតញានគ្មានប្រណី បានងួនជាប្តីមិនខ្ចីទុំ។* |

| | |
|---|---|
| | *ឱ ! ទាវអើយទុក្ខបងចម្លែក         បងឡើងដល់ស្អែកទីត្បូងឃ្មុំ*<br>*ម្ល៉ះសមអរជូនគេគិតគុំ            ហៅក្មៀវជួបជុំសម្លាប់បង*[1] ។ [...] |
| **២- សច្ចៈ** | ព្រឹត្តិការណ៍ ហេតុការណ៍ ដំណើរ ជាក់នឹងភ្នែក។ |
| **៣- លោកិយសច្ចៈ** | ព្រឹត្តិការណ៍ ហេតុការណ៍ ជាក់ស្តែងមានក្នុងសង្គមមនុស្ស ដែលអ្នកនិពន្ធលើកយកមកបង្ហាញនៅក្នុងស្នាដៃ។<br>ឧទាហរណ៍ : នៅក្នុងរឿងភូមិតិរច្ឆាន ព្រឹត្តិការណ៍បាតុកម្មរបស់ប្រជាជននៅថ្ងៃទី១៨ មេសា ឆ្នាំ១៩២៥។ |
| **៤- ការផ្សំលោកិយសច្ចៈនិងអច្ឆរិយៈ** | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ លើកយករឿងពិតក្នុងសង្គមនិងរឿងអស្ចារ្យហួសពីការពិតមកបង្ហាញក្នុងស្នាដៃ។<br>ឧទាហរណ៍ទី១ : នៅក្នុងរឿងមហាវេស្សន្តរ ពរទី៥ ព្រះនាងសុបារសុប្បតីបានទទួលពរពីព្រះឥន្ទ្រ មុននឹងព្រះនាងជាព្រះមាតារបស់ព្រះវេស្សន្តរ គឺ "*ពេលមានគភ៌ សូមឱ្យមានផ្ទៃពោះរាបស្មើល្អដូចប្រក្រតី*"[2]។<br>ឧទាហរណ៍ទី២ : នៅក្នុងរឿងរាមកេរ្តិ៍ កាលព្រះរាមយាងទៅដល់ក្នុងព្រៃដើម្បីបួសជាបស្វី "*ព្រៃព្រឹក្សាប្រែសភាពពីក្តៅ ទៅត្រជាក់ ដើមឈើជ្រុះស្លឹកស្រពាប់ស្រពោន ទៅជាលាស់ស្លឹកមានផ្លែផ្កាដង្គុំដង្គោល មើមឈើពុលប្រែក្លាយទៅជាសាប ទទួលទានបាន រីឯសត្វកាចសាហាវ ប្រែក្លាយជាស្លូត*"[3]។ |
| **៥- បារមី**<br>អ. perfection<br>បារ. perfection (f.) | គុណជាតិដ៏ល្អដែលនាំឱ្យបានសម្រេចដល់ត្រើយ គឺព្រះនិព្វាន។ |
| **៦- គុណជាតិ** | គុណគ្រប់យ៉ាង មាន សីល សមាធិ បញ្ញា ជាដើម។ |
| **៧- ទសបារមី** | បារមីទាំង១០ ដែលព្រះពោធិសត្វបានបំពេញ ដើម្បីបានត្រាស់ជាព្រះពុទ្ធ។<br>ទសបារមីមាន : នេក្ខម្មបារមី វិរិយបារមី មេត្តាបារមី អធិដ្ឋានបារមី បញ្ញាបារមី សីលបារមី ខន្តិបារមី ឧបេក្ខាបារមី សច្ចបារមី ទានបារមី។ |
| **៨- នេក្ខម្មបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះតេមិយបានបំពេញ ដោយការចេញទៅសាងព្រះផ្នួស។ |
| **៩- វិរិយបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះមហាជនកបានបំពេញដោយការ**ព្យាយាម**។ |
| **១០- មេត្តាបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះសុវណ្ណ-សាមបានបំពេញដោយការផ្សាយ**មេត្តាធម៌**។ |

[1] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១៤ ទំព័រ ៩៤-៩៥។

[2] ញ៉ុក ថែម : ***មហាវេស្សន្តរជាតក*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៣៩ ព.ស. ១៩៩៥ ទំព័រ ៣៣។

[3] ពុទ្ធសាសនបណ្ឌិត្យ ***: រឿងរាមកេរ្តិ៍ខ្សែទី១*** ភ្នំពេញ ព.ស. ២៥៣៩ គ.ស. ១៩៩៥ ទំព័រ ៦០-៦៣, ខ្សែទី២ ទំព័រ ១-១៩។

| | |
|---|---|
| ១១- អធិដ្ឋានបារមី | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះនេមិរាជ បានបំពេញដោយការតាំងចិត្តមាំថា អាត្មាអញដល់ពេលសក់ស្កូវនឹងចេញទៅសាងព្រះផ្នួស ។ |
| ១២- បញ្ញាបារមី | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះមហោសថ បានបំពេញដោយការប្រើបញ្ញាដើម្បីដោះស្រាយបញ្ហា។ |
| ១៣- សីលបារមី | បារមីមួយក្នុងចំណោមបារមីទាំង១០ដែលព្រះពោធិសត្វក្នុងជាតិជាព្រះភូរិទត្តនាគរាជ បានបំពេញដោយការរក្សាឧបោសថសីល សូម្បីតែជីវិតក៏ហ៊ានលះបង់។ |
| ១៤- ខន្តីបារមី | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះចន្ទកុមារ បានបំពេញដោយការអត់ធ្មត់គ្រប់សង្កត់នូវសេចក្តីក្រោធ។ |
| ១៥- ឧបេក្ខាបារមី | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះនារទព្រហ្ម បានបំពេញដោយការតាំងចិត្តជាកណ្តាល បានដល់ឧបេក្ខាព្រហ្មវិហារ។ |
| ១៦- សច្ចបារមី | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះវិធុរបណ្ឌិត បានបំពេញដោយការកាន់ពាក្យសច្ចៈ។ |
| ១៧- ទានបារមី | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះវេស្សន្តរ បានបំពេញដោយការឱ្យមហាទាន។ |
| ១៨- ព្រះពោធិសត្វ | អ្នកដែលកំពុងបំពេញបារមី ដើម្បីត្រាស់ដឹងជាព្រះពុទ្ធ។ |
| ១៩- កន្សៃសារពេជ្ជ | ស្រីជាមហេសីឬភរិយារបស់ព្រះពោធិសត្វក្នុងបច្ឆិមជាតិ កាលនៅជាគ្រហស្ថ ឬដែលបានត្រាស់ហើយ។ |
| ២០- សរជាតិ | ដំណើរត្រឡប់ជាតិចេរវិលវិញ ពីជាតិមួយទៅជាតិមួយទៀត។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ការបញ្ចប់រឿងមហាវេស្សន្តរជាតក តួអង្គសរជាតិមានដូចតទៅ៖<br>- ព្រះបាទវេស្សន្តរ សរជាតិជាព្រះសម្មាសម្ពុទ្ធគោតម,<br>- នាងមទ្រី សរជាតិជានាងយសោធរា,<br>- ជាលីកុមារ សរជាតិជារាហុលកុមារ,<br>- នាងក្រឹស្នា(កណ្ហា) សរជាតិជានាងឧប្បលវណ្ណា។ |
| ២១- ពាហិរទាន | ទានខាងក្រៅខ្លួន មានទ្រព្យសម្បត្តិ លុយកាក់ ឬ របស់របរផ្សេងៗ។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ព្រះវេស្សន្តរបានឱ្យទានដល់ស្មូមយាចក តាំងពីទ្រព្យសម្បត្តិ របស់របរប្រើប្រាស់ប្រចាំថ្ងៃ រហូតដល់ដំរីបច្ច័យ-នាគេន្ទ្រ ដែលជាដំរីមង្គលរបស់ប្រទេស។ |
| ២២- អជ្ឈត្តិកទាន | ទានខាងក្នុងខ្លួន ដូចជា សាច់ ឈាម បេះដូង ថ្លើម ប្រមាត់ អវយវៈ (នៅក្នុងរឿងព្រះវេស្សន្តរ អជ្ឈត្តិកទាន គឺរាប់ទាំងការដាក់ទានរហូតដល់ប្រពន្ធកូន)។ |

| | |
|---|---|
| | ឧទាហរណ៍ : កាលព្រះពោធិសត្វយោនយកកំណើតជាសត្វទន្សាយ ព្រះអង្គបាន លោតចូលភ្លើង ដើម្បីប្រទានសាច់ព្រះអង្គឱ្យដល់ស្មូមដែលជាព្រះឥន្ទ្រកាឡាខ្លួន។ |
| ២៣- ជាតក | កម្រងនៃរឿងពីជាតិមុនៗ ដែលបុគ្គលណាមួយបានលុះញាណវិសេសសម្រាប់ដឹង ជាតិ ហើយយករឿងនោះមកសម្តែងប្រាប់អ្នកដទៃឱ្យបានដឹង។ |
| ២៤- ទសជាតក | រឿងដប់ជាតិចុងក្រោយរបស់ព្រះសក្យមុនីគោតមបរមសម្ពុទ្ធ។ រឿងនេះប្រភពដើម ជាភាសាបាលីមាននៅក្នុងគម្ពីរខុទ្ទកនិកាយ។ ឈ្មោះរឿងទាំងដប់មាន៖<br>១- រឿងតេមិយជាតក ២- រឿងមហាជនកជាតក ៣- រឿងសុវណ្ណសាមជាតក<br>៤- រឿងនេមិរាជជាតក ៥- រឿងមហោសថជាតក ៦- រឿងភូរិទត្តជាតក<br>៧- រឿងចន្ទកុមារជាតក ៨- រឿងនារទព្រហ្មជាតក ៩- រឿងវិធុរជាតក<br>១០- រឿងវេស្សន្តរជាតក។ |
| ២៥- ទសពរ | ពរដប់ប្រការ ដែលព្រះនាងសុបារសុប្បតីម្តាយព្រះវេស្សន្តរសូមពរពីព្រះឥន្ទ្រ។ ពរទាំងនេះ ចែងក្នុងកណ្ឌទី១ ឈ្មោះកណ្ឌទសពរក្នុងរឿងមហាវេស្សន្តរជាតក គឺ<br>១- សូមឱ្យបានជាអគ្គមហេសី នៃព្រះបាទស្រីសញ្ជ័យសោយរាជ្យនៅនគរ ជេតុត្តរ។<br>២- សូមឱ្យមាននេត្រាមូលខ្មៅយង់ មានភមោ(ចិញ្ចើម) កោងទ្រទេសទ្រទ្រួយ ដូចចង្កួយកៅទណ្ឌ(ធ្នូ)។<br>៣- សូមឱ្យមាននាមថា សុបារសុប្បតី (ផុស្សតី) ដដែល។<br>៤- សូមឱ្យមានបុត្រាដ៏ប្រសើរមួយអង្គ មានកិត្តិនាមល្បីល្បាញ ចូលចិត្តឱ្យទាន។<br>៥- ពេលទ្រង់គភ៌ សូមឱ្យមានឧទររាបស្មើល្អដូចប្រក្រតី។<br>៦- សូមកុំឱ្យមានដោះសណ្តាយ។<br>៧- សូមកុំឱ្យមានសក់ស្កូវ។<br>៨- សូមឱ្យមានសាច់សម្បុរល្អិតល្អបីដូចពពិលមាស។<br>៩- សូមឱ្យអាចដោះទុក្ខទោសរបស់មនុស្សសត្វទាំងឡាយ។<br>១០- សូមឱ្យមានសព្វសត្វ គឺហង្ស ក្រៀល ក្ងាន សឹងហើរឆ្វាត់ឆ្វៀលបន្លឺនូវសព្ទ នោះឮល្វេងល្វើយពីរោះឮដ៏ព្រះរាជមន្ទីរនិងសូមឱ្យមានអ្នកប្រាជ្ញរាជបណ្ឌិត ចេះធម៌អាថ៌កុំបីឱ្យដាច់អំពីព្រះរាជមន្ទីរ។ |
| ២៦- អក្សរសាស្ត្រ<br>អ. letters / humanities<br>បារ. lettres (f.) | វិទ្យាសាស្ត្រសង្គមមួយប្រភេទដែលសិក្សាពីភាសានិងអក្សរសិល្ប៍។ |
| ២៧- អក្សរសិល្ប៍<br>អ. literature<br>បារ. littérature (f.) | ផ្នែកមួយនៃអក្សរសាស្ត្រ ដែលអ្នកនិពន្ធលើកពីបញ្ហាមនុស្ស បញ្ហាសង្គម មកចោទ និងដោះស្រាយដោយប្រើសិល្បវិធី។ |
| ២៨- សិល្បវិធី<br>អ.<br>បារ. | សិល្បៈ វិធីសាស្ត្រ ឬ មធ្យោបាយផ្សេងៗរបស់អ្នកនិពន្ធក្នុងការសរសេររឿង ដើម្បី ទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្តាប់ អ្នកទស្សនា ឱ្យជក់ចិត្ត ចាប់អារម្មណ៍ ទៅ តាមដំណើររឿង។ |

| | |
|---|---|
| ២៩- ចលនាអក្សរសិល្ប៍ខ្មែរ<br>អ. movement of khmer literature<br>បារ. mouvement de la littérature khmère | ទម្រង់ផ្សេងៗគ្នានៃអក្សរសិល្ប៍ខ្មែរដែលស្ថិតនៅក្រោមឥទ្ធិពលនៃលទ្ធិឬលោក-ទស្សនៈណាមួយ។ ចលនាអក្សរសិល្ប៍ខ្មែរបែងចែកជា៖<br>- អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម,<br>- អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម,<br>- អក្សរសិល្ប៍ខ្មែរបែបខេមរនិយម,<br>- អក្សរសិល្ប៍ខ្មែរបែបបរទេសនិយម។ |
| ៣០- អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម<br>អ.<br>បារ. littérature khmère à caractère buddhiste | អក្សរសិល្ប៍ខ្មែរដែលទទួលឥទ្ធិពលពុទ្ធសាសនា។ ស្នាដៃប្រភេទនេះតែងលើកយកសកម្មភាពព្រះពោធិសត្វក្នុងការកសាងបារមីឬទស្សនៈសំខាន់ៗក្នុងព្រះពុទ្ធសាសនា ដូចជា បញ្ញាកម្មផល បុណ្យបាបជាដើម។ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមមានអក្សរសិល្ប៍បែបពុទ្ធនិយមសុទ្ធសាធ និង អក្សរសិល្ប៍បែបពុទ្ធនិយមក្លាយ។<br>ឧទាហរណ៍ : - រឿងព្រះវេស្សន្តរ ជាអក្សរសិល្ប៍បែបពុទ្ធនិយមសុទ្ធសាធ។<br>- រឿងក្រុងសុភមិត្រ ជាអក្សរសិល្ប៍បែបពុទ្ធនិយមក្លាយ។ |
| ៣១- អក្សរសិល្ប៍ខ្មែរបែបពុទ្ធ-និយមក្លាយ | អក្សរសិល្ប៍ខ្មែរ ដែលបញ្ហានៃរឿងមានជាប់ទាក់ទងទៅនឹងទ្រឹស្តីក្នុងព្រះពុទ្ធសាសនាតិចតួច។ តួអង្គនៃរឿងពុំមានកសាងបារមីអ្វីមួយច្បាស់លាស់ឡើយ។<br>ឧទាហរណ៍ : រឿងសព្វសិទ្ធិ រឿងសូរ្យវង្ស រឿងសុបិនកុមារ...។ |
| ៣២- អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម | អក្សរសិល្ប៍ខ្មែរ ដែលទទួលឥទ្ធិពលសាសនាព្រាហ្មណ៍។ ស្នាដៃប្រភេទនេះ តែងលើកយកភាពអច្ឆរិយៈរបស់ទេវៈឬអាទិទេព និង អសុរៈ មករៀបរាប់បង្ហាញ។<br>ឧទាហរណ៍ : រឿងរាមកេរ្តិ៍។ |
| ៣៣- អក្សរសិល្ប៍ខ្មែរបែបខេមរនិយម | អក្សរសិល្ប៍ខ្មែរ ដែលលើកឡើងនិងឆ្លុះបញ្ចាំងពីជីវភាពរស់នៅរបស់ខ្មែរពិតៗ។<br>ឧទាហរណ៍ : រឿងទុំទាវ រឿងសូផាត...។ |
| ៣៤- អក្សរសិល្ប៍ខ្មែរបែបបរទេសនិយម | អក្សរសិល្ប៍ខ្មែរ ដែលយកលំនាំតាមបរទេស។<br>ឧទាហរណ៍ : - រឿងជីវិតឥតន័យ របស់អ្នកនិពន្ធ សុទ្ធ ប៉ូលីន។<br>- រឿងថៅកែចិត្តចោរ របស់អ្នកនិពន្ធ ពៅ យូឡេង និង អ៊ុំ ឈឺន។ |
| ៣៥- សង្ខេបរឿង<br>អ. summary<br>បារ. résumé (m.) | សេចក្តីបំប្រួញដំណើររឿងឱ្យខ្លី ឱ្យអស់សេចក្តី ដោយរក្សាខ្លឹមសាររឿងឱ្យនៅដដែល។ |
| ៣៦- សង្គមដ្ឋាន<br>អ. social milieu ?<br>បារ. milieu social (m ) | មជ្ឈដ្ឋានប្រកបដោយសម្ភារៈ បញ្ញាញាណ ផ្លូវចិត្តរបស់មនុស្សក្នុងសង្គម នាសម័យកាលនៃរឿងដែលអ្នកនិពន្ធលើកយកមកបង្ហាញក្នុងស្នាដៃណាមួយ។ ជាតុសំខាន់ៗរបស់សង្គមដ្ឋានគឺ សង្គមបរិយាកាស សង្គមប្រវត្តិ និង សង្គមបញ្ហា។ |
| ៣៧- សង្គមបរិយាកាស<br>អ. social atmosphere<br>បារ. atmosphère sociale (f .) | ទិដ្ឋភាពនៃរឿង ដែលអ្នកនិពន្ធបានរៀបរាប់ពីការរស់នៅ ការប្រកបអាជីវកម្ម ជំនឿ ប្រពៃណី ទំនៀមទម្លាប់ ការគ្រប់គ្រង និង ទំនាក់ទំនងសង្គម ក្នុងសម័យកាលណាមួយ។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ការបង្ហាញពីការរស់នៅរបស់ប្រជាជន កាគោរព |

| | |
|---|---|
| | ព្រះពុទ្ធសាសនា ការជឿ លើមន្តអាគម ហោរាសាស្ត្រ ការប្រកាន់ប្រពៃណី ‹‹ នំមិនធំជាងនាឡិ ›› ប្រពៃណីចូលម្លប់ ទំនាក់ទំនងរវាងអ្នកមាននិងអ្នកក្រ អ្នកធំនិងអ្នកតូច និង ទំនាក់ទំនងក្នុងគ្រួសារ។ |
| **៣៨- សង្គមប្រវត្តិ**<br>អ. social history / social event / social fact<br>បារ. histoire sociale? / evènement social / fait social | ព្រឹត្តិការណ៍នានា ដែលអ្នកនិពន្ធបានលើកឡើង តាមរយៈដំណើររឿងណាមួយ ដោយជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសង្គម។<br>ឧទាហរណ៍ : - នៅក្នុងរឿងទុំទាវ សង្គមប្រវត្តិនៃរឿងទុំទាវ គឺទាក់ទងទៅនឹងសង្គមខ្មែរសម័យលង្វែក។<br>- នៅក្នុងរឿងភូមិតិរច្ឆាន សង្គមប្រវត្តិនៃរឿងភូមិតិរច្ឆាន គឺទាក់-ទងទៅនឹងសង្គមខ្មែរសម័យអាណានិគមនិយមបារាំង។ |
| **៣៩- សង្គមបញ្ហា**<br>អ. social problem<br>បារ. problème social (m.) | បញ្ហាទាំងឡាយដែលមានក្នុងសង្គម ដូចជា បញ្ហាជីវភាព បញ្ហាសុខុមាលភាព បញ្ហាគ្រប់គ្រងសង្គម... ដែលអ្នកនិពន្ធលើកមកបង្ហាញក្នុងដំណើររឿង។<br>ឧទាហរណ៍ : នៅក្នុងរឿងគូលីកំណែន ការបង្ហាញបញ្ហាមួយចំនួន ដូចជា អំណាចផ្ដាច់ការ ការកេងប្រវ័ញ្ច ការជំរិតទារពន្ធដារច្រើនហួសហេតុពីប្រជាជន...។ |
| **៤០- សង្គមារម្មណ៍**<br>អ. ...<br>បារ. ... | ផ្នត់គំនិតដែលកើតឡើងតាមរយៈការច្នៃប្រឌិតរបស់អ្នកនិពន្ធដោយផ្សារភ្ជាប់ទៅនឹងព្រឹត្តិការណ៍ជាក់ស្ដែងរបស់សង្គម។<br>ឧទាហរណ៍ : - នៅក្នុងរឿងទុំទាវ ទស្សនៈ ‹‹ នំមិនធំជាងនាឡិ ››,<br>- នៅក្នុងរឿងធនញ្ជ័យ ទំនាយហោរា។ |
| **៤១- កាលបរិច្ឆេទរឿង**<br>អ. composition date<br>បារ. date de la composition? | ថ្ងៃ ខែ ឆ្នាំ នៃការនិពន្ធរឿង។<br>- អត្ថបទអក្សរសិល្ប៍ខ្មែរមួយចំនួន ពេលខ្លះកាលបរិច្ឆេទនេះមានរៀបរាប់ក្នុងអារម្ភ-កថាខាងដើម,<br>ឧទាហរណ៍ : - នៅក្នុងរឿងកាកី ការបង្ហាញកាលបរិច្ឆេទនៅដើមរឿង ៖<br>*‹‹ពុទ្ធសាសនំ អតិក្កន្តំ អដ្ឋបញ្ញា*<br>*សតិសត ទ្វេសហស្សា មហាសករាជា*<br>*ឯកស័ប្តត្រីស័ប្ត៍*››។[៤]<br>- នៅក្នុងរឿងព្រេងនិទានខ្មែរ ការបញ្ជាក់កាលបរិច្ឆេទពុំមានឡើយ។ |
| **៤២- អរិយធម៌**<br>អ. civilisation<br>បា. civilisation (f.) | បណ្ដុំលក្ខណៈរួមរបស់សង្គម ដែលក្នុងនោះមានទាក់ទងនឹងជំនឿ សាសនា សីលធម៌ សីលវិជ្ជា វិទ្យាសាស្ត្រ បច្ចេកទេស ការគ្រប់គ្រង... ហើយ ដែលផ្ទុយនឹងសភាពអន់ថយ។ មែកជាងសំខាន់ៗនៃអរិយធម៌ មានវប្បធម៌និងសង្គមធម៌។ |
| **៤៣- វប្បធម៌**<br>អ. culture | មែកជាងនៃអរិយធម៌ដែលទាក់ទងនឹងការបណ្ដុះបណ្ដាលចំណេះវិជ្ជាប្រាជ្ញាស្មារតី ទំនៀមទម្លាប់ សិល្បៈ វិទ្យាសាស្ត្រ អក្សរសាស្ត្រ... ឱ្យបានលូតលាស់រីកចម្រើន។ |

[៤] ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះបរមកោដ្ឋ : ***រឿងកាកី*** ភ្នំពេញ, បោះពុម្ពគ្រាទី៦, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥៤១ គ.ស. ១៩៩៧ ទំព័រ២។

| | |
|---|---|
| បារ. culture (f.) | <u>សង្កេត</u> ៖ បើយើងមិនបែងចែកវប្បធម៌ឱ្យដាច់ពីសង្គមធម៌ យើងអាចឱ្យនិយមន័យ តាមគណៈកម្មការវប្បធម៌និងវិចិត្រសិល្បៈ ដូចនេះ « ការបណ្ដុះចំណេះវិជ្ជា ប្រាជ្ញា ស្មារតី និងរបៀបរស់នៅរបស់មនុស្សឱ្យបានល្អូតលាស់ចម្រើន ដើម្បីសម្របសម្រួលទៅនឹងបរិស្ថាន និងការអភិវឌ្ឍសង្គម ដោយវិទ្យាសាស្ត្រឬដោយសិល្បៈផ្សេងៗ ជាដើម »។ |
| **៤៤- សង្គមធម៌**<br>អ. social<br>បារ. social (m.) | មែកជាងនៃអរិយធម៌ ដែលទ្រទ្រង់ការរស់នៅនិងការបណ្ដុះបណ្ដាលតាមរយៈគ្រឿងសម្ភារៈ ប្រដាប់ប្រើប្រាស់ វិធីបច្ចេកទេស ការបង្កើតផលិតផល ការរៀបចំសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ...។ |
| **៤៥- រចនាបថ**<br>អ. style<br>បារ. style (m.) | បែបផែនដោយឡែកៗ ដែលអ្នកនិពន្ធ សិល្បករ វិចិត្រករ យកមកប្រើប្រាស់ដើម្បីនិពន្ធ រចនា រៀបរាប់ និង និយាយ ដោយបញ្ចេញសំនួនវោហារ សេចក្ដី គំនិត ទស្សនៈផ្ទាល់ខ្លួន ក្រោមរូបភាពជាអត្ថន័យ(គំនិត) និង អត្ថរូប(ភាសា) ទៅតាមសម័យកាលណាមួយច្បាស់លាស់។ |
| **៤៦- សាស្ត្រា** | គម្ពីរ ឬ ក្បួនច្បាប់ប្រដៅ ដែលចារលើស្លឹករឹត។ |
| **៤៧- សាស្ត្រាទេសន៍** | សាស្ត្រាដែលមានចែងអំពីការអប់រំប្រៀនប្រដៅទាក់ទងទៅនឹងសាសនា ហើយដែលគេយកទៅប្រើប្រាស់សម្រាប់សម្ដែងធម៌ទេសនា។<br>ឧទាហរណ៍ : សាស្ត្រាទសជាតក ជាសាស្ត្រាទេសន៍។ |
| **៤៨- សាស្ត្រាល្បែង** | សាស្ត្រាដែលជាកម្រងអត្ថបទរឿងរ៉ាវទាំងឡាយសម្រាប់អានកម្សាន្ត បំពេអារម្មណ៍ឱ្យរីករាយ។<br>ឧទាហរណ៍ : សាស្ត្រារឿងក្រុងសុភមិត្រ, សាស្ត្រារឿងហង្សយន្ត, ... ។ |
| **៤៩- សាស្ត្រាក្បួន** | សាស្ត្រា ដែលជាកម្រងក្បួនខ្នាតនានាមាន ក្បួនទាយ មន្តអាគម ក្បួនឱសថ និងចំណេះវិជ្ជាផ្សេងៗទៀត។ |
| **៥០- សាស្ត្រាច្បាប់** | សាស្ត្រា ដែលជាកម្រងសីលធម៌នានា សម្រាប់ប្រៀនប្រដៅមនុស្សឱ្យសាងអំពើល្អ និង យល់ត្រូវ។<br>ឧទាហរណ៍ : សាស្ត្រាច្បាប់កេរកាល, សាស្ត្រាច្បាប់ប្រុស, ច្បាប់ស្រី, ... ។ |
| **៥១- និម្មិត** | បង្កើតដោយឫទ្ធិ កាឡាខ្លួន ជំណែងខ្លួន។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ព្រះឥន្ទ្រនិម្មិតខ្លួនជាព្រាហ្មណ៍ មកសុំនាងមទ្រីពីព្រះវេស្សន្តរធ្វើជាភរិយា។ |
| **៥២- បុព្វនិមិត្ត** | ហេតុភេទ ប្រផ្នូល គ្រឿងសម្គាល់ ដែលនាំបណ្ដាលឱ្យឃើញមុន។<br>ឧទាហរណ៍ : ព្រះនាងសិរិមហាមាយាទ្រង់យល់បុព្វនិមិត្តឃើញថា មានដំរីសចុះមកជ្រៀតចូលក្នុងព្រះវរកាយព្រះនាង។ |
| **៥៣- សិប្បនិម្មិត**<br>អ. artificial<br>បារ. artificiel, elle (adj.) | ដែលតុបតែងរចនាឡើងដោយសិល្បៈ ដែលមិនមែនជាធម្មជាតិ។<br>ឧទាហរណ៍ : ដើងសិប្បនិម្មិត ផ្កាសិប្បនិម្មិត ផ្លែឈើសិប្បនិម្មិត ... ។ |
| **៥៤- អនុកម្ម**<br>អ. imitation | ការត្រាប់តាម ការចម្លងតាមស្នាដៃសិល្បៈ អក្សរសិល្ប៍ ដែលមានរួចមកហើយ មកពិពណ៌នា បង្ហាញ បញ្ចាំង គូរ ឆ្លាក់ ឱ្យឃើញឡើងវិញ។ |

| | |
|---|---|
| បារ. imitation (f.) | ឧទាហរណ៍ : - រឿងល្ខោន «អ្នកមានឃ្លានយស» ជាអនុកម្មស្នាដៃរបស់លោក Molière ក្នុងរឿង «Bourgeois gentil homme»។<br>- រឿងល្ខោន « កំណាញ់ក្រៅតម្រា » ជាអនុកម្មស្នាដៃរបស់លោក Molière ក្នុងរឿង « AVARE »។ |
| **៥៥- នវកម្ម**<br>អ. innovation<br>បារ. innovation (f.) | ការកែប្រែថ្មី ការផ្លាស់ប្តូរថ្មី ការបញ្ចូលថ្មី ការកែច្នៃ ក្នុងអ្វីដែលមានពីមុនមក។<br>ឧទាហរណ៍ : រឿងរាមកេរ្តិ៍ខ្មែរ កើតចេញពីការកែច្នៃរឿងរាមាយណៈ។ |
| **៥៦- សិល្បវិជ្ជា**<br>អ. aesthetics<br>បារ. esthétique (f.) | វិទ្យាសាស្ត្រដែលសម្រាប់ណែនាំ ឬ ពិនិត្យវាយតម្លៃលើសោភ័ណនៅក្នុងស្នាដៃអក្សរសិល្ប៍ សិល្បៈ ច្បាប់ឧបទេស ជាដើម។ |
| **៥៧- តួអង្គ**<br>អ. character<br>បារ. personnage (m.) | មនុស្ស អមនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលមានសកម្មភាពនៅក្នុងរឿង។<br>ឧទាហរណ៍ : - នៅក្នុងរឿងធនញ្ជ័យ តួអង្គមាន ធនញ្ជ័យ សេដ្ឋី ស្តេច ។ល។<br>- នៅក្នុងរឿងអ្នកតាទឹកអ្នកតាភ្នំ តួអង្គមាន អ្នកតាទឹក អ្នកតាភ្នំ យាយតា កូនក្រមុំរបស់យាយតា ។ល។ |
| **៥៨- តួអង្គឯក**<br>អ. main character<br>បារ. personnage principal (m.) | តួអង្គសំខាន់បំផុតនៃរឿង។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ទុំនិងទាវ ជាតួអង្គឯកក្នុងរឿងទុំទាវ។ |
| **៥៩- តួអង្គរង**<br>អ. secondary character<br>បារ. personnage secondaire (m.) | តួអង្គបន្ទាប់ពីតួអង្គឯក។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ពេជ្រ នាងនោ ម៉ឺនងួន ម្តាយទាវ អរជូន... ជាតួអង្គរង។ |
| **៦០- តួអង្គបន្ទាប់បន្សំ** | តួអង្គក្រៅពីតួអង្គឯកនិងតួអង្គរង ដែលមានវត្តមានក្នុងដំណើររឿង តែក្នុងមួយខណៈប៉ុណ្ណោះ។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ តួអង្គអ្នកស្រុកចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ម៉ឺនងួននិងនាងទាវ ជាតួអង្គបន្ទាប់បន្សំ។ |
| **៦១- តួអង្គរំឭក** | តួអង្គដែលអ្នកនិពន្ធលើកយកមកនិយាយ ក៏ប៉ុន្តែមិនមានវត្តមាននៅក្នុងរឿងទេ។<br>ឧទាហរណ៍ : នៅក្នុងរឿងព្រះអាទិត្យថ្មីរះលើដែនដីចាស់ តួអង្គសម្តេចឪជាតួអង្គរំឭក ព្រោះតួអង្គនេះពុំមានវត្តមានឬសកម្មភាពអ្វីនៅក្នុងរឿងទេ អ្នកនិពន្ធគ្រាន់តែលើកព្រះនាមនិងគោលនយោបាយរបស់ព្រះអង្គមកបង្ហាញតែប៉ុណ្ណោះ។ |
| **៦២- តួយ៉ាង**<br>អ. type<br>បារ. type (m.)/typique (m.) | បែប ឧទាហរណ៍ គំរូ តំណាង...។ |
| **៦៣- តួអង្គតួយ៉ាង**<br>អ. type character<br>បារ. personnage type (m.) | តួអង្គ ដែលតំណាងក្រុមមនុស្ស ឬ វណ្ណៈណាមួយក្នុងសង្គម។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ<br>- ទុំនិងទាវ ជាតួអង្គតួយ៉ាងរបស់យុវជនខ្មែរសម័យលង្វែក ដែលមានទស្សនៈថ្មីក្នុងការទាមទារសិទ្ធិសេរីភាពជ្រើសរើសគូស្រករ។<br>- ម្តាយទាវ ជាតួអង្គតួយ៉ាងរបស់អ្នកគ្រប់គ្រងគ្រួសារនាសម័យលង្វែក ដែលប្រកាន់គោលការណ៍ «នំមិនធំជាងនាឡិ»។ |

| | |
|---|---|
| **៦៤- ស្ថានភាពតួយ៉ាង**<br>អ. type situation<br>បារ. situation type (f.) | ស្ថានភាពណាមួយដែលអ្នកនិពន្ធជ្រើសរើសយកមកជាតំណាងស្ថានភាពទូទៅនៃសង្គម។<br>ឧទាហរណ៍ : នៅក្នុងរឿងភូមិតិរច្ឆាន ស្ថានភាពនៃការជំរឹតទារពន្ធហួសហេតុពីប្រជាជនខ្មែររបស់បារាំង ជាស្ថានភាពតួយ៉ាងនៃការជិះជាន់គាបសង្កត់របស់អាណានិគមបារាំងមកលើប្រជាជនខ្មែរ។ |
| **៦៥- វិភាគតួអង្គ** | ការរកឱ្យឃើញនូវលក្ខណសម្បត្តិរបស់តួអង្គ តាមរយៈសកម្មភាព កាយវិការ សម្លៀកបំពាក់របស់តួអង្គផ្ទាល់ ឬ តាមរយៈពាក្យសម្ដីតួអង្គដទៃទៀត។ |
| **៦៦- ទំនាស់**<br>អ. conflict<br>បារ. conflit (m.) | ការប្រឈមគ្នារវាងកម្លាំង ឬ សភាវៈពីផ្ទុយគ្នា។ ទំនាស់បង្កើតឱ្យដំណើររឿងមានភាពតានតឹងឬធូរស្រាល ធ្វើឱ្យអ្នកអានជក់ចិត្ត ជិតអារម្មណ៍ រំភើប សប្បាយ រីករាយ រំជួលចិត្ត។ ទំនាស់មាន ទំនាស់ក្នុងខ្លួន និង ទំនាស់ក្រៅខ្លួន។ |
| **៦៧- ទំនាស់ក្នុងខ្លួន**<br>អ. inner conflict<br>បារ. conflit intérieur (m.) | ការប្រឈមរបស់តួអង្គណាម្នាក់នឹងអារម្មណ៍ ចិត្តរបស់ខ្លួនផ្ទាល់។ ទំនាស់ក្នុងខ្លួនច្រើនកើតមានឡើងនៅពេលតួអង្គជួបប្រទះនឹងបញ្ហាស្មុគស្មាញ។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ពេលព្រះវេស្សន្តរដាក់ទានជាលីក្រីស្នាឱ្យទៅជូជកព្រាហ្មណ៍ ពេលឃើញកូនត្រូវជូជកវាយធ្វើបាប ព្រះវេស្សន្តរក៏គិតថានឹងយកព្រះកៅទណ្ឌនូវព្រះខាន់សរថ្លា តាមទៅសម្លាប់ជូជកឱ្យក្ស័យជីវិតនឹងយកកូនមកវិញ។ |
| **៦៨- ទំនាស់ក្រៅខ្លួន**<br>អ. outer conflict/<br>exterio conflict<br>បារ. conflit extérieur (m.) | ការប្រឈមមុខដាក់គ្នា រវាងតួអង្គណាម្នាក់ជាមួយនឹងតួអង្គដទៃទៀត ឬ មជ្ឈដ្ឋានសង្គមខាងក្រៅ។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ព្រះបាទទសរថមានទំនាស់ជាមួយព្រះនាងកៃកេសីពីបញ្ហារាជបល្ល័ង្ក ដោយព្រះនាងកៃកេសីទាមទារឱ្យព្រះបាទទសរថគោរពពាក្យសច្ចៈ ដែលព្រះអង្គបានសន្យាថានឹងឱ្យព្រះភិរុតជាបុត្រព្រះនាងឡើងគ្រង-រាជ្យ នៅពេលដែលព្រះអង្គច្បាំងឈ្នះព្រះអាទិត្យ។ តែក្រោយមក ព្រះបាទទសរថបែរជាចង់ឱ្យព្រះរាមគ្រងរាជ្យសម្បត្តិវិញ ដោយសំអាងលើប្រពៃណីក្សត្រថា បុត្រច្បងត្រូវសោយរាជ្យមុន។ |
| **៦៩- លក្ខណៈអក្សរសិល្ប៍**<br>អ. literature character<br>បារ. caractère littéraire (m.) | បញ្ហាផ្សេងៗជាគ្រឿងសម្គាល់ចរិតលក្ខណៈទាំងឡាយដែលមាននៅក្នុងអក្សរសិល្ប៍ ដូចជា៖ លក្ខណៈមនុស្ស លក្ខណៈសង្គម លក្ខណៈប្រវត្តិសាស្ត្រ លក្ខណៈវណ្ណៈ លក្ខណៈជាតិ លក្ខណៈអន្តរជាតិ។ |
| **៧០- លក្ខណៈមនុស្ស**<br>អ. human character<br>បារ. caractère humain (m.) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធលើកយកបញ្ហាមនុស្ស មកចោទនិងដោះស្រាយនៅក្នុងដំណើររឿង ទោះបីអ្នកនិពន្ធលើកយកតួអង្គសត្វក្ដី ធម្មជាតិក្ដី តួអង្គអច្ឆរិយៈក្ដី ក៏តួអង្គទាំងនោះនៅតែជាតំណាងមនុស្សនៅក្នុងសង្គម។<br>ឧទាហរណ៍ : តួអង្គក្នុងអក្សរសិល្ប៍ខ្មែរ<br>- ទន្សាយ តំណាងមនុស្សមានបញ្ញា ស្រឡាញ់យុត្តិធម៌...។<br>- ខ្លា ក្រពើ តំណាងមនុស្សកាច សាហាវ រមឹលគុណ...។ |

| | |
|---|---|
| | - ក្រុងរាពណ៍ តំណាងមនុស្សអាជ្ញានិយម ផ្ដាច់ការ អត្តនោម័តិ...។<br>- ហនុមាន តំណាងមនុស្សមានសមត្ថភាព ស្មោះត្រង់...។ |
| ៧១- លក្ខណៈសង្គម<br>អ. social character<br>បារ. caractère social (m.) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះអ្នកនិពន្ធលើកយកបញ្ហាសង្គមមនុស្សក្នុងសម័យកាលណាមួយមកបង្ហាញ ចោទនិងដោះស្រាយ ក្នុងដំណើររឿង។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ បង្ហាញពីលក្ខណៈសង្គមដែលប្រកាន់ប្រពៃណី ‹‹នំមិនធំជាងនាឡិ›› ...។ |
| ៧២- លក្ខណៈប្រវត្តិសាស្ត្រ<br>អ. historical character<br>បារ. caractère historique (m.) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះអ្នកនិពន្ធលើកយកដំណើររឿងទាក់ទងនឹងសម័យកាលខ្លះ ព្រឹត្តិការណ៍ផ្សេងៗខ្លះដែលមានក្នុងប្រវត្តិសាស្ត្រ មកបង្ហាញ។<br>ឧទាហរណ៍ : - នៅក្នុងរឿងទុំទាវ តាមប្រវត្តិសាស្ត្រ រឿងនេះកើតនៅសម័យលង្វែក។<br>- នៅក្នុងរឿងភូមិតិរច្ឆាន តាមប្រវត្តិសាស្ត្រ រឿងនេះកើតនៅសម័យអាណានិគមបារាំង។ |
| ៧៣- លក្ខណៈវណ្ណៈ<br>អ. cast character<br>បារ. caractère de classe sociale (m.) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធលើកយកការតស៊ូវណ្ណៈ ការការពារឧត្តមគតិ ចរិត គោលបំណង នៃវណ្ណៈណាមួយមកបង្ហាញ។<br>ឧទាហរណ៍ : នៅក្នុងរឿងធនញ្ជ័យ អ្នកនិពន្ធបង្ហាញពីបញ្ញាជនតំណាងវណ្ណៈថ្នាក់ក្រោមដែលប្រឆាំងនឹងវណ្ណៈថ្នាក់លើ។ |
| ៧៤- លក្ខណៈជាតិ<br>អ. national character<br>បារ. caractère national (m.) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធលើកយកតម្លៃពិសេសរបស់ជាតិមកបង្ហាញក្នុងដំណើររឿងដែលទាក់ទងនឹង សីលធម៌ ជំនឿ ទំនៀមទម្លាប់ សាសនា និង អ្វីៗដែលជាអត្តសញ្ញាណជាតិ ដើម្បីបណ្ដុះគំនិតស្រឡាញ់អភិរក្ស ការពារ អភិវឌ្ឍ អរិយធម៌ របស់ជាតិ។ |
| ៧៥- លក្ខណៈអន្តរជាតិ<br>អ. international character<br>បារ. caractère international (m.) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធបង្ហាញពីតម្លៃសកលនៃស្នាដៃនិពន្ធណាមួយ។<br>ឧទាហរណ៍ : - នៅក្នុងរឿង Romeo and Juliet របស់អ្នកនិពន្ធ Shakespeare។<br>- នៅក្នុងរឿងរាមាយណៈ របស់អ្នកនិពន្ធវាល្មីកិ។ |
| ៧៦- បុនរុត្តិវិធី<br>អ. repetition<br>បារ. répétition (f.) | វិធីតែងកាព្យដែលធ្វើឱ្យផ្ទួនពាក្យសម្ដីឬផ្ទួនមតិដដែលៗ ដែលកវី អ្នកនិពន្ធ ប្រើដើម្បីធ្វើឱ្យមាន ចលនា សកម្មភាព របស់តួអង្គកាន់តែជាក់ស្ដែងឡើង។ បុនរុត្តិ-វិធីចែកជា៤ប្រភេទគឺ<br>១- ការផ្ទួនសូរស្រៈ និង ព្យញ្ជនៈ។ |

| | |
|---|---|
| | ឧទាហរណ៍ :<br>[....]*ខុនខែងខឹងខួនខឹងខាំ មាត់ភ្លាងង៉ាំង៉ាំ ត្របាសត្របែងផ្លែងកាំ*[៥] ។[...]<br>២- វិធីផ្ទួនពាក្យសម្គាល់លក្ខណៈ ដោយប្រើគុណនាមផ្ទួនគ្នា<br>ឧទាហរណ៍ :<br>[...] *ចិត្តគិតថាអេះ នាងនេះល្អម្ល៉េះ នេះហៅល្អលន់ ត្រកាលឃើញម្ដង*<br>*នេះហោងហៅបុណ្យ គ្មានស្រីណាប៉ុន ល្អពន់ប្រមាណ*[៦] ។[...]<br>៣- វិធីផ្ទួនពាក្យសម្គាល់នូវសកម្មភាពឬចលនា<br>ឧទាហរណ៍ :<br>[...] *ស្ដេចដំស្ដេចដាន់ស្ដេចធាក់ ស្ដេចប្រានស្ដេចចាក់ ស្ដេចហែក*<br>*រុះរាយបោះបង់*[៧] ។[...]<br>៤- វិធីផ្ទួនគំនិតនិងបញ្ហាដដែលៗ<br>ឧទាហរណ៍ :<br>[...] *កន្លង់មាសមង្គលថ្លៃ ឆ្មៀលឆ្មាត់វិលវៃ ទ្រហឹងខ្ចាយខ្ចរ។*<br>*កន្លង់ត្រេចត្រង់កេសរ បងត្រេចចេរចរ ត្រង់ឋានប្អូនរ័តន៍។*<br>*កន្លង់មាសមង្គលក្លាត់ ហិចហើរប្រវាត់ គ្រប់ដងសព្វសា។*<br>*កន្លង់ត្រេចត្រង់បុប្ផា បងត្រេចលីលា ដល់ឋានប្អូនស្រី។*<br>*កន្លង់មាសមង្គលថ្លៃ ប្រវាត់ឯឡ វេហាស៍នភី។*<br>*កន្លង់ត្រេចត្រង់រកភ្ញី បងត្រេចរកស្រី ស្រីមាសបវរ*[៨] ។[...] |
| **៧៧- សញ្ច័យវិធី**<br>អ. accumulation<br>បារ. accumulation (f.) | វិធីដែល កវី ឬ អ្នកនិពន្ធ ប្រមូលផ្ដុំនូវភេទការណ៍ឬមតិផ្សេងៗ ក្នុងវគ្គឬប្រយោគតែមួយ។ ក្នុងវិធីនេះ គេច្រើនផ្ដុំកិរិយាសព្ទ ប្រធាន ដើម្បីបង្ហាញឱ្យឃើញនូវចលនាឆាប់រហ័ស រំភើបញាប់ញ័រ។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ខ្សែទី៤ ចលនាប្រហាររបស់ព្រះរាមទៅលើក្រុងខរ<br>[...] *ស្ដេចដំ ស្ដេចដាន់ ស្ដេចធាក់ ស្ដេចប្រាន ស្ដេចចាក់ ស្ដេចហែករុះ*<br>*រាយបោះបង់*[៩] ។[...] |
| **៧៨- វេសម្មវិធី**<br>អ. opposition and contrast<br>បារ. opposition (f.) et contraste (m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ចេះលើកយកគុណភាពពីរ ចលនា ឬសកម្មភាពពីរ សំនួនសេចក្ដីពីរ មតិទស្សនៈពីរ ឬ អត្ថៈខាងក្នុងនិងខាងក្រៅ របស់តួអង្គណាមួយ ដែលមានភាពផ្ទុយគ្នាមកដាក់ប្រៀបគ្នា ដើម្បីជាមធ្យោបាយពន្លេច |

[៥] ពុទ្ធសាសនបណ្ឌិត្យ : ***រឿងរាមកេរ្តិ៍ ខ្សែ៣*** ភ្នំពេញ ព.ស. ២៥៣៩ គ.ស. ១៩៩៥ ទំព័រ២០។

[៦] ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះបរមកោដ្ឋ : ***រឿងកាកី*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៤១ គ.ស. ១៩៩៧ ទំព័រ១៥។

[៧] ពុទ្ធសាសនបណ្ឌិត្យ : ***រឿងរាមកេរ្តិ៍ ខ្សែ៤*** ភ្នំពេញ ព.ស. ២៥៣៩ គ.ស. ១៩៩៥ ទំព័រ៣២។

[៨] លាង ហាប់អាន : ***ព្រះរាជសម្ភារអ្នកនិពន្ធខ្មែរ*** ភ្នំពេញ, បណ្ណាគារ សេង-ងួន-ហួត, បោះពុម្ពលើកទី៣, ព.ស. ២៥០៩ គ.ស. ១៩៦៦ ទំព័រ៥៨។

[៩] ពុទ្ធសាសនបណ្ឌិត្យ : ***រឿងរាមកេរ្តិ៍ ខ្សែ៤*** ភ្នំពេញ ព.ស. ២៥៣៩ គ.ស. ១៩៩៥ ទំព័រ៣២។

| | |
|---|---|
| | ឱ្យឃើញនូវតម្លៃអ្វីមួយ។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ការរៀបរាប់អំពីកូខ័ន បង្ហាញពីទំនាស់ខាងក្នុង និងខាងក្រៅ<br>- [...] *សក្តិស្លូនជាអ្នកថ្មើរព្រៃ ខ្លួនខ្មៅក្រៅវិស័យ នូវធ្មេញសស្គឹមភ្នែកប្រាល។*<br>*ខ្លួនខ្លោះខ្លាំងខែងពេញពាល ជាត់ជំមមារ មម្លូមមុលព្រឹក្សព្រៃ* [១០] ។[...]<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ការបង្ហាញទស្សនៈពីផ្ទុយគ្នា រវាងម្តាយនិងកូន<br>- [...] *អំណាចខ្លួបខ្លាចមានស័ក្តិយស ចំពោះជាត្រូវបុណ្យកូនឡើង*<br>*ម្តាយប្រាប់ប្រដៅកូនកុំឆ្មើង ចចេសចចើងណាថ្លៃម្តាយ។*<br>*ទាវឮម្តាយប្រាប់ចាប់ចាំទុក ស្ទើរធ្លាក់ថ្លើមក្តុកពុំសោយ*<br>*ទើបមានវាចាថាម៉ែអាយ ខ្ញុំកូនដូចស្តាយបាយចំណី។*<br>*ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី*<br>*លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ* [១១] ។[...] |
| **៧៩- វិលោមក្តវិធី**<br>អ. inversion<br>បារ. inversion (f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើឃ្លាល្បះដោយផ្លាស់ត្រឡប់ពាក្យ ដើម្បីឱ្យអ្នកអាន អ្នកស្តាប់ ចាប់អារម្មណ៍។<br>ឧទាហរណ៍ : [...] *ដែកដុលនាំង **តូចបួនជញ្ជាំង** **ជំសោអស្ចារ្យ*** [១២] ។[...] |
| **៨០- វឌ្ឍមានវិធី**<br>អ. progression<br>បារ. progression (f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ធ្វើឱ្យដំណើររឿងមានការរីកចម្រើនពីធូរស្រាលទៅតានតឹងឬពីតានតឹងទៅធូរស្រាលវិញ។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ<br>- ស្នេហាទុំទាវ ចេញដំណើរពីភាពធម្មតា ទៅរកភាពតានតឹងបន្តិចម្តងៗ រហូតបណ្តាលឱ្យតួអង្គទាំងពីរស្លាប់។<br>ឧទាហរណ៍ : នៅក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់<br>- ដំណើរជីវិតរបស់សម ចេញពីភាពតានតឹងខាងដើមរឿង ហើយធូរស្រាលនៅចុងបញ្ចប់នៃរឿង។ |
| **៨១- សំវាទវិធី**<br>អ. dialogue<br>បារ. dialogue (m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដោយធ្វើឱ្យតួអង្គជជែក សន្ទនាឆ្លងឆ្លើយគ្នាទៅវិញទៅមក។<br>ឧទាហរណ៍ : នៅក្នុងល្បើកដុចនិងត្រី ការសន្ទនាគ្នារវាងត្រីនិងដុច<br>[...] *ថ្លែងដោយទំនង ដំណើរត្រីផងយាត្រា*<br>*ពើបនឹងដុចណា ត្រីស្រែកថារឺយចៀសចេញ។*<br>*ដុចថាអីអើ បទអ្នកនេះតើម្តេចមិញ* |

---

[១០] ពុទ្ធសាសនបណ្ឌិត្យ : ***រឿងរាមកេរ្តិ៍ ខ្សែ១*** ភ្នំពេញ ព.ស. ២៥៣៩ ទំព័រ ៤២។

[១១] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១៤ ទំព័រ៤៩។

[១២] កេង វ៉ាន់សាក់ : ***គុកកាមកិលេស*** ភ្នំពេញ គ.ស. [?] ទំព័រ១។

| | |
|---|---|
| | *ក៏មកប្រើអញ បៀសចេញឱ្យអ្នកជាល្បែង* [១៣]។[...] |
| **៨២- ឯកវាទវិធី**<br>អ. monologue<br>បារ. monologue (m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដោយធ្វើឱ្យតួអង្គនិយាយថ្លែងទុក្ខព្រួយឬរៀបរាប់អំពីអនុស្សាវរីយ៍អ្វីមួយតែម្នាក់ឯង គ្មាននរណាចូលលាយឡំឡើយ។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ នាងទាវ ក្រោយពេលទុំត្រឡប់ទៅវត្តវិហារជំរិញ នាងនឹកទុំយ៉ាងខ្លាំង ហើយគិតម្នាក់ឯងថា៖<br>[...] *ថាអញស្តាយក្រហាយប្រាណ មិនក្សាន្តធូន់ខ្លួនប្រៀបហាក់ភ្នំ*<br>*រលើងបព្វតាផ្ការលំ សង្កត់សៀតក្រំណ្ដំខ្លាំង។*<br>*ខ្លោចផ្សាក្តៅក្តួលខ្នួលក្នុងថ្លើម ដង្ហើមផុតៗស្លុតកាន់កាំង*<br>*ម្ល៉េះហើយលោកអើយប្អូនមរណំ ខ្លួនស្លាំងស្តាំងស្តមទ្រមវេទនា* [១៤]។[...] |
| **៨៣- វណ្ណនាវិធី**<br>អ. narration<br>បារ. narration (f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដោយលើកយកតួអង្គមនុស្ស សត្វ រឿង ចម្បាំង ធម្មជាតិឬទេសភាព មកនិទានរៀបរាប់ឱ្យឃើញច្បាស់ ដូចបានឃើញនឹង ភ្នែកផ្ទាល់។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ការរៀបរាប់អំពីចម្បាំងរវាងទូភីនិងពាលី<br>[...] *សឹងសាញសោះសាដ៏ទីទៃ ទូភីនិរភ័យ លលេលលាំងរួសរង់។*<br>*ឆ្កៀលឆ្កឹសធរណីជ្រួយជ្រង រ៉ែវាត់ឈៀងឈ្នង រលើងរលំព្រឹក្សា។*<br>*ធ្លាយធ្លាក់បែកបាក់បព្វតា ងើយង្ហយងរងា រលាស់ស្រួចស្រិង្គ* [១៥] *ម៉ាយមៀង។*<br>*វិលវេះវ៉ៃវាត់ខ្លាំងខ្លៀង ស្ទុះស្ទះឆាបឆៀង ក្រឡេកក្រឡាស់ហាក់ហោះ។*<br>*ក្រុងពាលីលុះជាញឆ្ពោះ ខ្ទាត់ដូចគេបោះ ពុំដិតដល់អង្គមហិង្សា។*<br>*ស្នែងស្និទ្ធពីរពេជ្រផ្លាញផ្លា ពះលើសិល្បាពាលីរាជពុំអាចបីនូវមុត។*<br>*ដូចលំពែងពេជ្រមុតបីប្រាកដ អ្នកចាក់ដ៏ចំហុតទំលុះ* [១៦] *លើមហាពេជ្រឯង។*<br>*ព្រះខ័នពេជ្រពះពេជ្រស្នែង ពេជ្រនូវពេជ្រឯង ប្រកួតប្រកឹងចេស្តា។*<br>*ពាលីវ៉ៃវេះដ៏វេហាស៍ ទូភីវេងា ទន្ទាំទន្ទួយវិលវាត់* [១៧]។[...] |
| **៨៤ - សមន្តរត្តវិធី**<br>អ. parallelism<br>បារ. Parallélisme (m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើសម្រាប់អធិប្បាយពីសមត្តភាពឬទ្វានុភាព កលល្បិច មធ្យោបាយ ប្រហាក់ប្រហែលគ្នា រវាងតួអង្គបដិបក្ស ដើម្បីឱ្យមាននាដ្យភាព។ |

[១៣] ហ្លួងវិសេសអក្ខរា ដួង : ***ល្បើកជុំច ក្លាម*** ភ្នំពេញ, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពលើកទី២ ព.ស. ២៥៤៥ គ.ស.២០០១ ទំព័រ១។

[១៤] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១៤ ទំព័រ២៤។

[១៥] ពាក្យ ‹‹ស្រិង្គ›› នេះ ក្នុងវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧-៦៨ សរសេរ ‹‹ស្រឹង្គ››។

[១៦] ពាក្យ‹‹ទំលុះ›› នៅទីនេះសរសេរខុសពីវចនានុក្រមខ្មែរ បោះពុម្ព គ្រាទី៥ ឆ្នាំ១៩៦៧-៦៨។ ពាក្យនេះត្រូវសរសេរ‹‹ទម្លុះ›› វិញ។

[១៧] ពុទ្ធសាសនបណ្ឌិត្យ : ***រឿងរាមកេរ្តិ៍ ខ្សែ៤*** ភ្នំពេញ ព.ស. ២៥៣៩ គ.ស. ១៩៩៥ ទំព័រ៥៥។

| | |
|---|---|
| | ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ខ្សែទី៣ ក្នុងចម្បាំងរវាងព្រះរាមនិងក្រុងខរ មួយផ្លែងសរកើតជានាគ មួយទៀតផ្លែងសរកើតជាគ្រុឌ ម្ខាងផ្លែងសរជាភ្លើង ម្ខាងទៀតផ្លែងសរឱ្យកើតជាទឹក។ |
| **៨៥ - ឧបកថាវិធី**<br>អ. episode<br>បារ. épisode (m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដោយនិយាយរៀបរាប់ព្រឹត្តិការណ៍អ្វីមួយមិនទាន់ចប់សេចក្ដីផង ក៏ផ្អាកមួយខណៈ ហើយ ក៏ចាប់និយាយរៀបរាប់ព្រឹត្តិ-ការណ៍ថ្មីមួយទៀតបន្ត។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ខ្សែទី៤ ដើមដំបូងអ្នកនិពន្ធនិយាយពីព្រះរាមត្រាច់ចររកនាងសីតា បន្ទាប់ពីក្រុងរាពណ៍ឆក់យកទៅ។ ដំណើររឿងនេះមិនទាន់ដឹងសេចក្ដីអស់ផង ស្រាប់តែអ្នកនិពន្ធបែរទៅជានិយាយពីរឿងទូភីស្ដេចក្របីបង្កើតចម្បាំងជាមួយនឹងពាលីស្ដេចស្វាទៅវិញ។ |
| **៨៦- អវេក្ខណវិធី**<br>អ. observation<br>បារ. observation (f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដោយលើកយកហេតុការណ៍ សកម្មភាពផ្សេងៗ មកបង្ហាញរៀបរាប់ លាតត្រដាង ឱ្យឃើញជាក់ស្ដែង ហាក់ដូចជានៅនឹងភ្នែក។<br>ឧទាហរណ៍ : នៅក្នុងរឿងផ្កាស្រពោន<br>-[...] *នៅខែចេត្រនិងពិសាខ តាមផ្លូវពីក្រុងសៀមរាបទៅអង្គរវត្ត ផ្កាដ៏ល្អបញ្ចេញរីកើយពិដោរក្រអូបឈ្ងុយ។ បើជួនជាមានវាយោបក់បន្តិចៗផង អ្នកដែលដើរយកអាកាសពេលល្ងាចតាមថ្នល់នេះនឹងមានចិត្តសោប់សោយអណ្ដែតអណ្ដូង ប្រហែលជានឹងលាន់មាត់ថា ទោះជាឋានតុសិតក៏មិនសប្បាយជាជាងនេះ មើលទៅ*[១៨]។[...] |
| **៨៧- និយមេតិវិធី**<br>អ. enjambement<br>បារ. enjambement (m.) | វិធីតែងកាព្យមួយបែប ដែលកវីប្រើដោយធ្វើឱ្យព្យាង្គនៃពាក្យនៅចុងឃ្លាណាមួយទៅលោតទៅជាប់នឹងព្យាង្គដើមនៃឃ្លាបន្ទាប់ ដើម្បីបន្តគំនិតកុំឱ្យដាច់គ្នា និង ធ្វើឱ្យវិធីសាស្ត្រតែងកំណាព្យមានលក្ខណៈត្រឹមត្រូវក្នុងការរៀបចំឃ្លាឱ្យគ្រប់ចំនួនព្យាង្គ។<br>ឧទាហរណ៍ : នៅក្នុងរឿងកាកី<br>- [...] *ពាក្យពោលពុំពី- រោះរាប់នៃនី- ទានតាមបទបា- លីលោកដើមអាទិ៍*<br>*ត្បិតជាតិប្រាជ្ញា ចេះចងសាសនា ពុំសូវត្បួសេម*[១៩] ។ [...] |
| **៨៨- វិធីបំផ្លើស**<br>អ. hyperbole<br>បារ. hyperbole (f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដោយលើកយកពាក្យសម្ដីលើសហួសពីការពិត មករៀបរាប់ទិដ្ឋភាព សកម្មភាពអ្វីមួយ ក្នុងគោលបំណងបង្ហាញហេតុការណ៍ណាមួយធ្វើឱ្យមានកម្រិតខ្ពស់បំផុតឬទាបបំផុត ដោយបង្កប់ន័យក្នុងការទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្ដាប់ ឱ្យមានការពិចារណាទៅលើបញ្ហាដែលខ្លួនចង់បង្ហាញ។<br>ឧទាហរណ៍ : - នៅក្នុងកំណាព្យ «*មើលផែនដីខ្មែរសម័យ ប៉ុល ពត អៀង សារី*» |

[១៨] នូ ហាច : ***រឿងផ្កាស្រពោន*** ផ្សាយពីក្រសួងសិក្សាធិការជាតិ ភ្នំពេញ រោងពុម្ពរស្មី គ.ស. ១៩៦០ ទំព័រ៦១។

[១៩] ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះបរមកោដ្ឋ : ***រឿងកាកី*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៤១ គ.ស. ១៩៩៧ ទំព័រ២។

| | |
|---|---|
| | [...] អកទោចទូញយំ តាមដងព្រៃភ្នំ ឃើញភាពទារុណ<br>មនុស្សស្លាប់គរច្រើន *កើនហួសបូកគុណ* *រយមួសញាក់គ្រុន*<br>*ខ្លាចខ្មោចមនុស្សលង* [20]។[...] |
| ៨៩ - **វិធីពង្វាង**<br>អ. detour<br>បារ. détour (m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដើម្បីពង្វាងដោយមិនប្រើពាក្យកន្សោមពាក្យចំៗ ត្រង់ៗសម្រាប់សម្គាល់បញ្ញត្តិណាមួយ។<br>ឧទាហរណ៍ :<br>[...] *បិសាចក្អែកខ្មៅខ្លៅសាមាន្យ* ចិត្តជួតិរច្ឆានខ្មៅចំបែង<br>សម្លាប់ជាតិខ្មែរគ្មានរអែង បំផ្លាញជាតិឯងទៅជាផេះ ។[...] |
| ៩០ - **វិធីត្រឡប់**<br>អ. regression<br>បារ. régression (f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដោយលើកយកពាក្យផ្ទុះគ្នាមកបង្ហាញ ដើម្បីឱ្យពាក្យទាំងនោះមានន័យសេចក្ដីផ្សេងគ្នា។<br>ឧទាហរណ៍ : នៅក្នុងកំណាព្យ ‹‹*គុកកាមកិលេស*››<br>[...] ធ្វើបុណ្យបានបុណ្យ ធ្វើបាបពីមុន បាបវិលមកសង<br>*ស្អប់គេ គេស្អប់* មិនចប់សំណង ប្រសិនស្នេហ៍ស្នង<br>គេស្នេហ៍វិញដែរ[21] ។[...] |
| ៩១- **អត្ថរស**<br>អ. text values<br>បារ.valeurs (f.) du texte (m.) | តម្លៃល្អ មិនល្អ ពីរោះ ពុំពីរោះ ដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍។ ក្នុងអត្ថរសមាន បច្ចេករស វិសេសរស សព្ទរស ។ |
| ៩២- **បច្ចេករស**<br>អ. technical values<br>បារ. valeurs techniques (f.) | ផ្នែកមួយនៃអត្ថរស ដែលកវី អ្នកនិពន្ធ ប្រើដើម្បីជាវិធីពិសេសក្នុងការតែងនិពន្ធដើម្បីធ្វើឱ្យអត្ថបទមានសម្រស់ សម្រាប់ផ្នែកឬប្រភេទនៃរឿងនីមួយៗ។ ក្នុងបច្ចេក-រសមាន កាព្យរស ប្រលោមរស នាដករស ។ |
| ៩៣- **ប្រលោមរស**<br>អ. romantic<br>បារ. romantique (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ពិសេសអ្នកនិពន្ធប្រលោមលោក ចេះរៀបរៀង តុបតែងរឿងរបស់ខ្លួនតាមរយៈការបង្កើតដំណើររឿង សកម្មភាពនៃតួអង្គឱ្យមានស្នេហា ការផ្សងព្រេង... ប្រកបដោយលក្ខណៈអណ្ដែតអណ្ដូង សោកសង្រេង សប្បាយ កម្សត់... ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ មានអារម្មណ៍រំភើប សង្វេគ សប្បាយ ព្រួយ ជាមួយតួអង្គនិងដំណើររឿង។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ<br>[...] *ឱ ! ទាវអើយទៅពីព្រោះម្ដាយ មិនដឹងប្រែក្លាយមានប្រើស្មៀត*<br>*ទាវអើយទុក្ខទុំធំចង្អៀត ស្ពាត់ស្មៀតដូចភ្នំរលំលើ។*<br>*ទាវអើយទាវស្រីប្រណីបង មែនពិតជាម្ដងទើបហ៊ានធ្វើ*<br>*អក្ខរីទាវស្រីប្អូនចាត់ប្រើ ដំណឹងដំណើរឱ្យឆាប់ដល់។*<br>*ប្អូនអើយទុក្ខបងម្ដងហ្នឹងធ្ងន់ ពេញពៀបទូរន់សូន្យស្រងល់*<br>*ស្រងាត់ដូចហាក់អកុសល ខ្វាយខ្វល់ឡើនឡង់អង្គរាយមាយ។* |

[20] ជួន ម៉ែន : ***មើលផែនដីខ្មែរសម័យ ប៉ុល ពត អៀង សារី*** ភ្នំពេញ បោះពុម្ពលើកទី១ ដោយក្រសួងឃោសនាការ វប្បធម៌ គ.ស.១៩៨០ ទំព័រ៥ ។

[21] កេង វ៉ាន់សាក់ : ***គុកកាមកិលេស*** ភ្នំពេញ គ.ស. [?] ទំព័រ១៧។

| | |
|---|---|
| | *ទាវអើយប្រសិនខ្លួនបានគេ　បងនៅទទេមិនឈប់ងាយ*<br>*ស៊ូបង់ជីវិតដូចសឹកនាយ　ស្លាប់ក្នុងបន្ទាយចំណោមធំ*[២២] ។[...]<br>ឧទាហរណ៍ : នៅក្នុងរឿងផ្កាស្រពោន ការធ្វើដំណើរតាមរថភ្លើងរបស់ប៊ុនធឿនទៅស្រុកកំណើតដ៏កណ្តោចកណ្តែងម្នាក់ឯងក្នុងចំណោមមិត្តភក្តិដ៏សប្បាយ។<br>[...] *ពួកសិស្សវិទ្យាល័យ... យោលរិតតែញឹកញាប់ឡើង*[២៣] ។[...] |
| ៩៤- **នាដករស**<br>អ. theatrical values<br>បារ. valeurs théâtrales | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះតុបតែង រៀបរៀងដំណើររឿងឱ្យមានឆាក ឈុត ដើម្បីសម្តែងជាសិល្បៈទស្សនីយភាព។ |
| ៩៥- **វិសេសរស**<br>អ. particular values<br>បារ. valeurs particulières | ផ្នែកមួយនៃអត្ថរស ដែលកវី អ្នកនិពន្ធបង្កើតឡើងយ៉ាងប៉ិនប្រសប់ក្នុងការតែងនិពន្ធរឿងប្រលោមលោក ល្ខោន កំណាព្យ រឿងព្រេង រឿងល្បើក ឬ អត្ថបទផ្សេងៗ។ ក្នុងវិសេសរសមាន សុន្ទររស វិហាសរូបរស មហត្តរស វិសិដ្ឋរស វីររស ទារុណរស ហាសរស ទស្សនីយរស។ |
| ៩៦- **សុន្ទររស**<br>អ. pretty<br>បារ. le joli | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះពណ៌នារូបភាព លក្ខណៈសកម្មភាពនៃតួអង្គ ដំណើររឿង ធម្មជាតិ ឱ្យឃើញលក្ខណៈល្អត្រឹមត្រូវតាមការពិត ឬ រូបលក្ខណៈពិត ធ្វើឱ្យអ្នកអាន អ្នកស្តាប់ពេញចិត្ត។<br>ឧទាហរណ៍ : នៅក្នុងរឿងកាកី<br>[...]　*កាយកើតអស្ចារ្យ　អំពីផ្កាកា-　ណិកាសោភី*<br>*ភក្ត្រាសោភ័ណ　ដូចចន្ទ្របូណ៌មី　សក់ដូចភមរី*<br>*រលើបខ្មាញ់ខ្មៅ។*<br>*...............　..................　.............*<br>*កបកាយក្រអូប　ទោះទាំងរាងរូប　ប្រហើរពុំបាច់*<br>*រកផ្កាគ្រឿងអប់　ឈ្ងុយឈ្ងប់សព្វសាច់　ពិដោរបណ្តាច់*<br>*បណ្តូលអស់ស្រី*[២៤] ។ [...] |
| ៩៧- **វិហាសរូបរស**<br>អ. grotesque<br>បារ. grotesque (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះពណ៌នារូបអាក្រក់ សកម្មភាពចម្លែករបស់តួអង្គ ដើម្បីបង្កើតសោភ័ណ។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ការពណ៌នារូបអាក្រក់របស់តាជូជក<br>-[...] *មានព្រាហ្មណ៍ម្នាក់ឈ្មោះជូជកព្រឹទ្ធាចារ្យ រូបអន្ធការ ស្គមច្រដោងច្រមុះ-កោងទ្រូងសឹងតែផ្ទឹង សក់រឹងក្រញាង ពោះធំកំប៉ោង លោងសំពៀត ដំបារត្រចៀកយុរយារក្រាស់ដូចឈ្លង់ភ្លើង ជើងកោងដូចជើងសេក ភ្នែកស្រលៀង ស្រលើ សាច់ពកដូចគេផ្ញើរដើបរដុប យុរយារប៉ុនផ្លែក្រសាំងផ្លែសម៉ ធ្មេញស ក្បាលវែងតូចម្ខាងដូចផ្លែត្នោត*[២៥] ។[...] |
| ៩៨- **មហត្តរស**<br>អ. grandiose | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះរៀបរាប់ពីរូបរាង មហិទ្ធិឫទ្ធិ អំណាចរបស់តួអង្គណាមួយ ធ្វើឱ្យមានលក្ខណៈសម្បើមអស្ចារ្យ។ |

[២២] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥១៤, ទំព័រ៨៧-៨៨។

[២៣] នូ ហាច : ***រឿងផ្កាស្រពោន*** ភ្នំពេញ អគារបោះពុម្ពផ្សាយ វប្បធម៌ , បោះពុម្ពឡើងវិញលើកទី១, ឆ្នាំ១៩៨៩, ទំព័រ២-៦។

[២៤] សម្តេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះបរមកោដ្ឋ : ***រឿងកាកី*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥៤១, ទំព័រ៨-១០។

[២៥] ញ៉ុក ថែម : ***មហាវេស្សន្តរជាតក*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥៣៩, ទំព័រ១៧៣-១៧៤។

| | |
|---|---|
| បារ. grandiose (m.) | ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ នៅពេលហនុមានទៅរកឱសថព្យាបាលព្រះលក្ស្មណ៍ ហនុមានពុំស្គាល់ដើមថ្នាំ ក៏លើកភ្នំទាំងមូលមកតែម្តង<br>-[...] *បានមូត្រឧសភរាជហោះខ្ទី ទៅយកបុស្សវី កេសរបទុមសោភា។*<br>*វីព្រះសង្ករណីនោះណា ហនុមានមហិមា ពុំស្គាល់នៃដើមថ្នាំនោះ។*<br>*ជ្រងជ្រួយស្ងួយទាំងភ្នំហោះ នូវកម្លាំងនោះឆ្ពោះ វឹងដល់ពិភេកភរាជា។*<br>*ពិភេកទទួលទិព្វឱសថា បានគ្រប់តំរ៉ា*[២៦] *សម្តែងនូវគុណថ្នាំនោះ។*<br>*ហនុមានស្រេចលើកភ្នំនោះ វិលវឹងទៅឆ្ពោះ ក៏លុះនៃស្ថានដើមនាយ*[២៧]។[...] |
| **៩៩- វិសិដ្ឋរស**<br>អ. sublime<br>បារ. sublime (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះបង្ហាញនូវសកម្មភាពដ៏អស្ចារ្យរបស់តួអង្គ ក្នុងការបំពេញកិច្ចការអ្វីមួយ ដែលមនុស្សលោកធម្មតានៅក្នុងសង្គមពុំអាចធ្វើដូចឡើយ។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ការធ្វើទានរបស់ព្រះវេស្សន្តរ។ |
| **១០០-វីររស**<br>អ. heroic<br>បារ. héroïque (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះបង្ហាញនូវសកម្មភាពអាកប្បកិរិយា ចិត្តអង់អាចក្លាហាន មោះមុតរបស់តួអង្គ ក្នុងការប្រយុទ្ធតទល់ជាមួយគូបដិបក្ខដើម្បីការពារអំពើល្អ។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ រាមលក្សណ៍ ជបលក្សណ៍ ក្មេងតូចៗ ច្បាំងយ៉ាងអង់អាចក្លាហានជាមួយទ័ពព្រះរាម ដែលមានយុទ្ធសិល្ប៍ពូកែអស្ចារ្យ។ |
| **១០១-ទារុណរស**<br>អ. tragic<br>បារ. tragique (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះបង្ហាញឱ្យឃើញនូវការជិះជាន់ ការព្យាបាទ ការរំលោភ ការធ្វើទុក្ខទោស ការដាក់ទណ្ឌកម្មយ៉ាងឃោរឃៅរបស់តួអង្គខ្លាំងទៅលើតួអង្គទន់ខ្សោយគ្មានសមត្ថភាពឱ្យរងទុក្ខភ័យ រហូតបាត់បង់ជីវិតក៏សឹងមាន។<br>ឧទាហរណ៍ : - នៅក្នុងរឿងកាកី ព្រះបាទព្រហ្មទត្ត បានដាក់ទណ្ឌកម្មនាងកាកីដោយបណ្តែតពោងពាយនាងក្នុងមហាសាគរ។<br>- នៅក្នុងរឿងទុំទាវ ការស្លាប់របស់ទុំទាវ តម្លៃទារុណស្ថិតនៅត្រង់ទុំស្លាប់ គឺស្លាប់ដោយអំណាចអរជូននិងបក្សពួកចាប់យកទៅកាប់ចាក់ វាយប្រហារ រហូតដល់ស្លាប់បាត់បង់ជីវិតយ៉ាងទារុណបំផុត។ |
| **១០២ - ហាសរស**<br>អ. comic<br>បារ. comique (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះបង្ហាញសកម្មភាពកំប្លុកកំប្លែងធ្វើឱ្យអ្នកអាន អ្នកស្តាប់ សើចសប្បាយរីករាយ។<br>ឧទាហរណ៍ : នៅក្នុងរឿងធនញ្ជ័យ ធនញ្ជ័យរើសអាចម៍សេះ ប្រកថង់យាមយកទៅជូនសេដ្ឋីកណ្តាលចំណោមមន្ត្រី។<br>ឧទាហរណ៍ : នៅក្នុងរឿងអាឡេវ អាឡេវចាប់ម៉ែឪវារៀបការ ដើម្បីបានស៊ីនំគមនំអន្សម...។ |
| **១០៣ - ទស្សនីយរស**<br>អ. picturesque<br>បារ. pittoresque (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះរៀបរាប់អំពីទេសភាពធម្មជាតិ ព្រៃព្រឹក្សា មច្ឆា បក្សាបក្សី បង្កើតជាសិល្ប៍បរិយាកាស ដែលជាលម្អមួយចំពោះចក្ខុារម្មណ៍និងសោតារម្មណ៍របស់អ្នកអាននិងអ្នកស្តាប់។ |

[២៦] ពាក្យ ‹‹តំរ៉ា›› តាមវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ , គ.ស. ១៩៦៧ គឺសរសេរ ‹‹ **តម្រា** ››។

[២៧] ពុទ្ធសាសនបណ្ឌិត្យ : ***រឿងរាមកេរ្តិ៍ខ្មែរ*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥៣៩ គ.ស.១៩៩៥, ទំព័រ២០។

| | |
|---|---|
| | ឧទាហរណ៍ : នៅក្នុងរឿងក្រុងសុភមិត្រ ការរៀបរាប់អំពីធម្មជាតិ<br>-[...] *សម៉ពង្រេននូវផ្លែក ត្រៀលត្រាចប៉ប្រេក ខ្វាវខ្វិតខ្នុរខ្នារ។*<br>*ស្វាតស្វាយក្រូចក្រាយរកា ពពេលពពារ កប្បាសក្របៅ។*<br>*ផ្តកផ្តៀកកង្រៀកតាត្រៅ ចាកចេកត្នឹលឡៅ ផ្ទឹករាំងក្រកោះ។*<br>*គ្រើលគ្រង់លពង់លំពស់ រលួយរលោះ*[២៨] *រលាយរលា។*<br>*ផ្ការផ្គុងផ្កាផ្គង់ពុទ្រា ត្រួយត្រស់ត្រៀលស្វា ទ្រមូងទ្រមួច*[២៩] ។ [...] |
| **១០៤- សព្វរស**<br>អ. general values<br>បារ. valeurs générales | ផ្នែកមួយនៃអត្ថរស ដែលកវី អ្នកនិពន្ធបានលើកយកមកប្រើប្រាស់ក្នុងអត្ថបទរឿងរបស់ខ្លួន ដើម្បីបង្កើតតថរស អច្ឆរិយរស កុសលរស...។ |
| **១០៥- តថរស**<br>អ. the real<br>បារ. le réel | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះលើកយកបញ្ហា ឬព្រឹត្តិការណ៍ពិតមកបង្ហាញ។<br>ឧទាហរណ៍ : នៅក្នុងរឿងភូមិតិរច្ឆាន អ្នកនិពន្ធបានលើកយកតួអង្គ ព្រឹត្តិការណ៍ ទីកន្លែង ដែលមានពិតក្នុងសង្គមខ្មែរមកបង្ហាញ។ |
| **១០៦- អច្ឆរិយរស**<br>អ. the marvellous<br>បារ. le merveilleux | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះលើកយកតួអង្គអរូបី(ទេវៈ យក្ស ខ្មោច ព្រាយ បិសាច...) តួអង្គសត្វឬសកម្មភាពអស្ចារ្យផ្សេងៗមកបញ្ចូលក្នុងស្នាដៃរបស់ខ្លួន ដើម្បីធ្វើឱ្យដំណើររឿងមានលក្ខណៈអស្ចារ្យហួសពីការពិត ដូចជា តួអង្គចេះជ្រែកទឹក ជ្រែកដី ហោះហើរ ដើរលើអាកាស បែងភាគ កាឡាខ្លួន...។<br>ឧទាហរណ៍ : នៅរឿងកាកី គន្ធ័នបានកាឡាខ្លួនជាស្រមើលហើយតោងរោមគ្រុឌ<br>[...] *យាត្រាត្រង់ព្រះជ្រៃ គន្ធ័នវៃរឿងសំដៅ*<br>*លបលាក់ដើរតាមទៅ មើលដំណើរនៃគ្រុឌា។*<br>*ដើរដល់ដើមព្រះជ្រៃ ប្រែប្រាណវៃវិលរឹងជា*<br>*ក្រុងគ្រុឌរាជបក្សា គន្ធ័នសោតនិម្មិតអង្គ។*<br>*ជាស្រមើលទំនា រោមគ្រុឌាឬទ្ធីវង្គ*<br>*ស្ទុះហោះហើរពុំផ្សង សំដៅដល់ដើមសិម្ពលី*[៣០] ។[...] |
| **១០៧- កុសលរស**<br>អ. the good<br>បារ. le bien | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះលើកយកការអប់រំ ទូន្មានប្រៀនប្រដៅ មកបង្ហាញតាមរយៈសកម្មភាពតួអង្គឬដំណើររឿង។<br>ឧទាហរណ៍ : នៅក្នុងច្បាប់ស្រីហិតោបទេស, គតិលោក...។ |
| **១០៨- នាដ្យរស**<br>អ. the dramatic<br>បារ. le dramatique | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះបង្ហាញទំនាស់ វិបត្តិប្រឆាំងគ្នានៃតួអង្គបដិបក្ខ នៅក្នុងដំណើររឿង ជួនកាលបង្ហាញពីភាពតានតឹង ភាពធូរស្រាល ទុក្ខសោក ដែលនាំឱ្យអ្នកអាន អ្នកស្តាប់ កម្សត់ ក្តុកក្តួល រន្ធត់ អាណិតអាសូរ...។ |

[២៨] ពាក្យ ‹‹រលោះ›› តាមវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ គ.ស. ១៩៦៧ គឺសរសេរ ‹‹ **រលួស** ››។

[២៩] ឧកញ៉ាកោសាធិបតី កៅ : ***រឿងក្រុងសុភមិត្រ*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១៦ ទំព័រ៣៨។

[៣០] សម្តេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះបរមកោដ្ឋ : ***រឿងកាកី*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៤១ ទំព័រ៤២។

| | |
|---|---|
| | ឧទាហរណ៍ ៖ នៅក្នុងរឿងផ្កាស្រពោន សកម្មភាពទំនាស់វិបត្តិរបស់នាងវិធាវី និង យាយនួនជាម្ដាយ។ |
| **១០៩- សន្ទស្សន៍អក្សរសិល្ប៍** (អក្សរសិល្ប៍អធិប្បាយ) អ. literature of demonstrative genre បារ. littérature du genre démonstratif | អត្ថបទអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ បង្ហាញរូបភាព វត្ថុ ព្រឹត្តិការណ៍ណាមួយ ដើម្បីឱ្យអ្នកអាន អ្នកស្ដាប់ បានឃើញ បានយល់ដឹង ទៅតាមដំណើររឿង។ ក្នុងសន្ទស្សន៍អក្សរសិល្ប៍មាន ពិពណ៌នាកថា វណ្ណនាកថា បដិពិម្ពកថា វុត្តន្តកថា សារកថា។ |
| **១១០- ពិពណ៌នាកថា** អ. descriptive genre បារ. genre descriptif | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ រៀបរាប់ អធិប្បាយ ឱ្យអ្នកអាន អ្នកស្ដាប់ បានឃើញពីលក្ខណៈខាងក្នុង ខាងក្រៅ គុណសម្បត្តិ គុណវិបត្តិ សារប្រយោជន៍ រូបលក្ខណៈ ចរិយា សកម្មភាព មុខងារ នៃវត្ថុ មនុស្ស សត្វ រុក្ខជាតិ ... និង ការថែរក្សាវត្ថុ មនុស្ស សត្វ រុក្ខជាតិ ទាំងនោះ។<br>ឧទាហរណ៍ ៖ - ពិពណ៌នាអំពីរូបសម្ផស្សរបស់មនុស្ស,<br>- ពិពណ៌នាអំពីដើមឈើ...។ |
| **១១១- វណ្ណនាកថា** អ. narrative genre បារ. genre narratif | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ សរសេរ អធិប្បាយ រៀបរាប់ឡើងវិញនូវដំណើររឿងរ៉ាវជាក់ស្ដែងនៃជីវភាពសង្គម (ពិធីបុណ្យផ្សេងៗ ការធ្វើដំណើរ ឧបទ្ទវហេតុ ទំនាក់ទំនងរវាងគ្រួសារ រវាងខ្លួនឯង និង អ្នកដទៃ) ទោះជាដំណើររឿងទាំងនោះ កន្លងផុតទៅក្ដីឬកំពុងប្រព្រឹត្តទៅក្ដី មករៀបរាប់ ដើម្បីឱ្យអ្នកអាន បានដឹង បានយល់ ហាក់ឃើញនឹងភ្នែកផ្ទាល់។<br>ឧទាហរណ៍ ៖ វណ្ណនាកថាស្ដីពី *បុណ្យផ្កា បុណ្យកឋិន ពិធីរៀបការ ការធ្វើដំណើរ ការទៅលេងស្រុកកំណើត ខ្យល់ព្យុះ ទឹកជំនន់ រញ្ជួយដី* ...។ |
| **១១២- បដិពិម្ពកថា** អ. portrait បារ. portrait (m.) | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ រៀបរាប់ ពណ៌នា ពីរូបលក្ខណៈ (ខាងក្នុង និង/ឬ ខាងក្រៅ)របស់មនុស្ស(មនុស្សពិតប្រាកដ ឬ មនុស្សក្នុងរូបគំនូរ ក្នុងរូបថត រូបចម្លាក់ រូបសំណាក...។<br>ឧទាហរណ៍ ៖ - ការរៀបរាប់ពីព្រះបាទជ័យវរ្ម័នទី៧,<br>- ការរៀបរាប់ពីក្រឡាហោមគង់...។ |
| **១១៣- វុត្តន្តកថា** អ. report បារ. reportage (m.) | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ រៀបរាប់បញ្ជាក់ឡើងវិញនូវហេតុការណ៍ ឬ ពិធីផ្លូវការអ្វីមួយ ដែលកំពុងប្រព្រឹត្តទៅក្ដីឬកន្លងផុតទៅក្ដី ដើម្បីផ្សព្វផ្សាយតាមរយៈទស្សនាវដ្ដី វិទ្យុ ទូរទស្សន៍។<br>ឧទាហរណ៍ ៖ ការរៀបរាប់ពីទស្សនកិច្ចរបស់ប្រមុខរាជរដ្ឋាភិបាល ឬ វរជនសំខាន់ណាមួយ។ |
| **១១៤- សារកថា** អ. letter បារ. lettre*s* (f.) | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ សរសេរជាលក្ខណៈសំបុត្រឆ្លងឆ្លើយ(ក្នុងគ្រួសារ មិត្តភក្ដិ អ្នកដទៃ) ដើម្បីលាតត្រដាងបង្ហាញនូវបញ្ហាអ្វីមួយទាក់ទងនឹងការរស់នៅ ពិធីអ្វីមួយ មនោសញ្ចេតនា... របស់មនុស្ស។ |

| | |
|---|---|
| | ឧទាហរណ៍ : - សារកថារបស់លោកស្រី Sévigné,<br>- សារកថារបស់លោក Voltaire។ |
| **១១៥- នាដកអក្សរសិល្ប៍**<br>អ. literature of theatrical genre<br>បារ. littérature du genre théatral | អត្ថបទអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តែងឡើងដោយរៀបចំឱ្យមានឈុតនិងឆាក សម្រាប់យកទៅសម្តែងសិល្បៈល្ខោន។ នៅក្នុងនាដកអក្សរសិល្ប៍មាន នាដ្យកថា ហាសកថា ទារុណកថា។ |
| **១១៦- នាដ្យកថា** | នាដកអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តាក់តែងជារឿងល្ខោន ដោយលើកយករឿងវិបត្តិទំនាស់របស់មនុស្សក្នុងសង្គមនៃសម័យកាលណាមួយ ទោះជារឿងវិបត្តិទាំងនោះ ពិតក្តី មិនពិតក្តី មកធ្វើជាប្រធានរឿង ដោយបង្កើតបរិយាកាសតឹងតែង ធូរស្រាល ជ័យជម្នះ បរាជ័យ ស្លាប់រស់ កម្សត់ ភិតភ័យ តក់ស្លុត កំប្លែង។<br>ឧទាហរណ៍ : រឿងសំបុកឥតមេបា របស់លោក ហង្ស ធន់ហាក់។ |
| **១១៧- ហាសកថា**<br>អ. comedy<br>បារ. comédie (f.) | នាដកអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តាក់តែងជារឿងល្ខោន ដែលដំណើររឿងប្រកបដោយឈុត ឆាក កំប្លុកកំប្លែង ធ្វើឱ្យអ្នកអាន អ្នកស្តាប់ផ្ទុះសំណើច ។ |
| **១១៨- ទារុណកថា**<br>អ. tragedy<br>បារ. tragédie (f.) | នាដកអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តាក់តែងជារឿងល្ខោន បង្កើតជាដំណើររឿងរីករវ កម្សត់ ព្រាត់ប្រាស ធ្វើឱ្យអ្នកអាន អ្នកស្តាប់ ញាប់ញ័ររន្ធត់ចិត្តអាណិតអាសូរតួអង្គទន់ខ្សោយ ដែលត្រូវតួអង្គខ្លាំងសង្កត់សង្កិន ធ្វើទុក្ខទារុណកម្មបំពារបំពាន។<br>ឧទាហរណ៍ : នៅក្នុងរឿង Romeo and Juliet របស់អ្នកនិពន្ធ សេកស្ពៀរ។ |
| **១១៩ - ទារុណហាសកថា**<br>អ. tragi-comedy / melodrama<br>បារ. tragi-comédie ( f.)/ mélodrame (m.) | នាដកអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តាក់តែងជារឿងល្ខោន ដោយបង្ហាញឱ្យឃើញនូវការឈឺចាប់ ព្រួយបារម្ភ កម្សត់ ព្រាត់ប្រាស អស់សង្ឃឹម លាយឡំនឹងការរំភើប សប្បាយរីករាយ ទៅតាមសកម្មភាពតួអង្គនៃរឿង ធ្វើឱ្យអ្នកអាន អ្នកស្តាប់ មានអារម្មណ៍ញាប់ញ័ររន្ធត់ចិត្តអាណិតអាសូរផង និង មានអារម្មណ៍សប្បាយរីករាយផង។ |
| **១២០-ឧបទេសអក្សរសិល្ប៍**<br>អ. literature of didactic genre<br>បារ. littérature du genre didactique | អត្ថបទអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ រៀបរៀងឡើងសម្រាប់អប់រំទូន្មានប្រៀនប្រដៅជនានុជន កុលបុត្រ កុលធីតា ឱ្យប្រព្រឹត្តតាមក្រឹត្យក្រម សីលធម៌។ ឧបទេសអក្សរសិល្ប៍ពុំមានលក្ខណៈជាច្បាប់ ជាបទបញ្ជា ជាការដាក់កំហិត ជាការបង្ខិតបង្ខំនោះទេ។ ឧបទេសអក្សរសិល្ប៍មាន សុភាសិត ទូន្មានកថា ល្បើកកថា សុន្ទរកថា ឧបារម្ភកថា ។ |
| **១២១- សុភាសិត**<br>អ. proverb<br>បារ. proverbe (m.) | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តាក់តែងជាពាក្យឬកម្រងពាក្យចួនរណ្តំ(កម្រងកែវ) សម្រាប់អប់រំ ទូន្មាន ដោយលើកយកធម្មជាតិជីវភាពសង្គម ជាដើម មកប្រៀបធៀប។<br>ឧទាហរណ៍ : - ចេះពីរៀន មានពីរក,<br>- ចង្កឹះមួយបាច់ កាច់មិនបាក់,<br>- តក់ៗពេញបំពង់។ |
| **១២២- ទូន្មានកថា** | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តាក់តែងជាអត្ថបទ (ភាគច្រើនជាពាក្យកាព្យ) សម្រាប់អប់រំ ណែនាំជនានុជន កុលបុត្រ កុលធីតា ឱ្យដើរ |

| | |
|---|---|
| អ. advice<br>បារ. conseil (m.) | ក្នុងផ្លូវល្អ មានសីលធម៌ គុណធម៌ ក្នុងជីវភាពរស់នៅ។<br>ឧទាហរណ៍ : នៅក្នុងច្បាប់ពាក្យចាស់ ច្បាប់ប្រុស ច្បាប់ស្រី...។ |
| **១២៣- ល្បើកកថា**<br>អ. fable<br>បារ. fable (f.) | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ តាក់តែង ជារឿងនិទាន ដោយលើកយកគុណវិបត្តិមនុស្សនៅក្នុងសង្គម មកធ្វើជាប្រធានរឿង។ តួអង្គនៅក្នុងល្បើកកថា ភាគច្រើនជាតួអង្គសត្វ ដែលជានិមិត្តរូប ឬ គំរូមនុស្សប្រភេទណាមួយក្នុងសង្គម។ ល្បើកកថា ឆ្លុះបញ្ចាំងពីជីវភាព ទំនៀមទម្លាប់ បែបបទរស់នៅរបស់មនុស្ស និង បង្ហាញពីយុទ្ធវិធីផ្សេងៗក្នុងការដោះស្រាយបញ្ហាជីវិត។<br>ឧទាហរណ៍ : - ល្បើកជុច និង ត្រី របស់ហ្លួងវិសេសអក្ខរាជ្ជុង,<br>- គតិលោក របស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទ។ |
| **១២៤- សុន្ទរកថា**<br>អ. discourse / speech<br>បារ. discours (m.) | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ សរសេរអំពីអ្វីមួយ សម្រាប់អាន ថ្លែង ក្នុងពិធីអ្វីមួយ ដោយ ៖<br>- រៀបរាប់ពីលទ្ធផលការងារ,<br>- ណែនាំ តម្រែតម្រង់ ការអនុវត្តសកម្មភាពឬគម្រោងការអ្វីមួយ និង បញ្ចូលគំនិតរិះគន់។ |
| **១២៥- ឧបាម្ភកថា**<br>អ. satire<br>បារ. satire (f.) | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ សរសេរអត្ថបទជាពាក្យរាយ ឬជាពាក្យកាព្យ រិះគន់គុណវិបត្តិនៃសីលធម៌ នយោបាយ ជាពិសេសរិះគន់បុគ្គលក្នុងសង្គម។<br>ឧទាហរណ៍ : នៅក្នុងរឿងតាចេននិងចៅសន។ |

# បច្ចេកសព្ទស្នើពីមជ្ឈដ្ឋានខាងក្រៅ

## I- បច្ចេកសព្ទស្នើដោយលោកបណ្ឌិត សន ពៅ

លោកបណ្ឌិត សន ពៅ ទទួលបន្ទុកធ្វើសេចក្តីព្រាងច្បាប់ ដើម្បីត្រួតពិនិត្យ "រូបសញ្ញា" បានស្នើមក គ.ជ.ភ.ខ. ឱ្យជួយអនុម័តពាក្យមួយចំនួន។ គ.ជ.ភ.ខ.បានអនុម័តពាក្យទាំងនេះនៅថ្ងៃពុធ ទី២២ ខែធ្នូ ឆ្នាំ២០១០។ អង្គប្រជុំបានសម្រេចដូចតទៅ ៖

១- « **ផ្ទាំង** ន. បន្ទះធំ, ស្រទាប់ធំ, ផ្ទៃ : ជញ្ជាំងមួយផ្ទាំង។ » (វចនានុក្រមសម្តេច ជួន ណាត)។

២- **ផ្លាក**(ខ្ចីពីពាក្យបារាំង plaque) សន្លឹកធ្វើអំពីលោហៈ ឈើ ឬ របស់ផ្សេងៗទៀត ដែលមានលក្ខណៈរឹង សំប៉ែត ស្តើង តូចជាងផ្ទាំង និង មានរាងផ្សេងៗ ប៉ុន្តែ ជាទូទៅច្រើនមានរាងចតុកោណសម្រាប់ប្រើកត់ត្រាសម្គាល់លេខ រថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត គេហដ្ឋាន តួនាទី កន្លែងធ្វើការ។ល។

៣- « **ស្លាក** ន. សំបុត្រជាកំណត់តូចៗ ជាគ្រឿងសម្គាល់ឈ្មោះជាដើម; ឆ្នោត; ទីវ; ខ្ទាច់ : សរសេរស្លាក, បិទស្លាក ជាសម្គាល់; ចាប់ស្លាក; ដាក់ស្លាកជាសម្គាល់កុំឲ្យច្រឡំ។ » (វចនានុក្រមសម្តេច ជួន ណាត)។

ដោយយោងទៅលើនិយមន័យនៃពាក្យខាងលើ «ស្លាក» មិនអាចប្រើជំនួស «ផ្លាក» បានទេ ពីព្រោះ វាជា «កំណត់តូចៗ»រីឯ «ផ្លាកសញ្ញា» ដែលមានលក្ខណៈរឹង មិនអាចគ្របដណ្តប់លើ «បដា» ដែលមានលក្ខណៈ ទន់បានឡើយ។

៤- «**សញ្ញាណប័ដ**» ជា«ដំបារឬបន្ទះស្លាន់(...)» ដូច្នេះ ពាក្យនេះក៏មិនអាចគ្របដណ្តប់លើ«បដា» បានដែរ : គួរ យើងយកពាក្យ «រូបសញ្ញា» វិញ ដើម្បីគ្របដណ្តប់លើសញ្ញាផ្សេងៗ ដែលមាន «បដា»ផង ហើយ រូបសញ្ញា មាន : ផ្លាកយីហោ, ផ្លាកពាណិជ្ជកម្ម, ពាណិជ្ជនាម, ម៉ាក, និមិត្តសញ្ញា, លក្ខណសញ្ញា, បដា, ប៉ង់កាត, ប៉ាណូ, អាហ្វីស, ស្ទីគ័រ, បណ្ណប្រកាស, អក្សរចារឹក នៅតាមទីសាធារណៈ។ល។

៥- **រូបសញ្ញា**មាន :

៥.១- **ផ្លាកយីហោ** (អ. signboard បារ. enseigne, f.) ផ្លាកដែលដាក់នៅលើទ្វារចូលទៅហាងទំនិញ ភោជនីយ-ដ្ឋាន ជាដើម។

៥.២- **ផ្លាកពាណិជ្ជកម្ម** (អ. publicity hoarding បារ. panneau-réclame) ផ្លាកដែលគេដាក់ផ្សព្វផ្សាយ ពាណិជ្ជកម្មនៅតាមទីសាធារណៈ នៅតាមថ្នល់ដែលមានចរាចរណ៍ច្រើន ជាដើម ដូច ផ្លាកពាណិជ្ជកម្មទឹក បរិសុទ្ធវីតាល់, ស្រាបៀរអង្គរ ជាដើម។

៥.៣- **ពាណិជ្ជនាម** គឺជាឈ្មោះឬសញ្ញាសម្គាល់ ឬ ជាឈ្មោះនិងសញ្ញាសម្គាល់ សម្រាប់បញ្ជាក់និងសម្គាល់ លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ។

៥.៤- **ម៉ាក** គឺជាសញ្ញាដែលមើលឃើញ ហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញឬសេវានៃសហគ្រាស នីមួយៗ។ ម៉ាកដែលប្រើប្រាស់សម្រាប់ទំនិញហៅថា **ពាណិជ្ជសញ្ញា**ហើយម៉ាក ដែលប្រើប្រាស់សម្រាប់សេវា ហៅថា **សេវាសញ្ញា**។

៥.៥- **និមិត្តសញ្ញា** (អ. logo បារ. logo, m.) រូបរចនាក្បាច់ក្បូរ(មានឬគ្មានអក្សរ) សម្រាប់ជានិមិត្តរូបនៃស្ថាប័ន អង្គការ ឬ ក្រុមហ៊ុន ណាមួយ។

៥.៦- **លក្ខណសញ្ញា** (អ. badge បារ. insigne, m.) គឺផ្លាកសញ្ញាសម្គាល់សក្តិយស តួនាទី, ឧ.លក្ខណសញ្ញានៃអ្នកបើកយន្តហោះ។

៥.៧- **បដា**(អ. banderol, streamer បារ. banderole, f.) «ផ្ទាំងសំពត់ដែលគេសរសេរអក្សរជាពាក្យសុភាសិត, ពាក្យស្លោកឬពាក្យអ្វីផ្សេងៗ សម្រាប់កាន់ហែជាក្បួន ឬ ចងសន្ធឹងទទឹងផ្លូវ : ធ្វើបដា, កាន់បដា, យកបដា ទៅចងសន្ធឹងលើផ្លូវ។» (វចនានុក្រមសម្តេច ជួន ណាត)។

៥.៨- **ប៉ង់កាត** (អ. placard បារ. pancarte, m.) ផ្លាកធ្វើពីឈើឬក្រដាសក្រាស់។ល។ ដែលនៅលើនោះមានសរសេរអក្សរសម្រាប់លើកបង្ហាញព័ត៌មានទាក់ទងនឹងអ្វីមួយ។

៥.៩- **ប៉ាណូ** (អ. billboard/hoarding បារ. panneau, m.) ផ្ទាំងរាបស្មើ (ធ្វើពីឈើ, លោហ:, ...) ដែលគេប្រើសម្រាប់ចារឬសរសេរពីលើ។ គេច្រើនភ្ជាប់ឬព្យួរប៉ាណូនឹងជញ្ជាំងអគារដែលមានមនុស្សចេញចូលច្រើនឱ្យគេដឹងអំពីអ្វីមួយ។

៥.១០- **អាហ្វីស**(អ. poster បារ. affiche, f.) ផ្ទាំងបោះពុម្ពដែលបានរចនាឡើងជាអក្សរសុទ្ធ ឬ ជារូបភាពសុទ្ធ ឬក៏ជាអក្សរផងនិងរូបភាពផង សម្រាប់ដាក់ជាប់នឹងជញ្ជាំងឬនៅទីកន្លែងសាធារណៈ សម្រាប់ទាក់ទាញចំណាប់អារម្មណ៍អ្នកឆ្លងកាត់ដើម្បីឱ្យដឹងអំពីគោលបំណងនៃអ្នកផ្សព្វផ្សាយ។

៥.១១- **ស្ប៉ុត** (អ. spot បារ. spot, m.) អត្ថបទខ្លីសម្រាប់ ឃោសនាពាណិជ្ជកម្ម, អប់រំ,...។

៥.១២- **បណ្ណប្រកាស** (អ. leaflet បារ. dépliant, m.; prospectus, m.) បរិយាយបណ្ណជាក្រដាសឬសន្លឹកធ្វើអំពីវត្ថុធាតុផ្សេងៗដែលបានបោះពុម្ពនិងរចនាឡើង មួយឬច្រើនទំព័រ បត់ជាពីរបីផ្នត់(ជាពិសេស dépliant) សម្រាប់ចែកជូនដោយមិនគិតថ្លៃ ដើម្បីផ្តល់ព័ត៌មានអំពីអ្វីមួយ។

៥.១៣- **ខិត្តបណ្ណ** (អ. notice-leaf បារ. tract, m) បណ្ណក្រដាសបោះពុម្ពឡើងដើម្បីផ្សព្វផ្សាយដំណឹងឱ្យប្រជាជនអនុវត្តតាម ច្រើនបាចពីយន្តហោះ ឬ បោះពុម្ពដោយក្រុមប្រឆាំង ច្រើនបាចនៅពេលយប់។ ខិត្តបណ្ណច្រើនមានទំហំប្រហែលសន្លឹកសៀវភៅសរសេរ។

៥.១៤- **អក្សរចារឹក** (អ. notice-board បារ. écriteau, m.) អក្សរដែលគេចារនៅលើខ្លោងទ្វារ, ក្បាលស្ពាន, គោលសីមា ជាដើម។

៦- គ្រឹះស្ថានពាណិជ្ជកម្ម គឺផ្ទះជំនួញ, ហាងទំនិញ ជាដើម។

៧- គ្រឹះស្ថានឧស្សាហកម្ម គឺរោងចក្រ, រោងជាង, សិប្បកម្ម ជាដើម។

## II- បច្ចេកសព្ទស្នើដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានស្នើមកគ.ជ.ភ.ខ. ឱ្យជួយបកប្រែជាផ្លូវការនូវពាក្យអង់គ្លេស "virtual tribunal" ។ ក្រោយពីសមាជិក គ.ជ.ភ.ខ. ពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានអនុម័តទទួលយកពាក្យស្នើដោយស្ថាប័នសាមី គឺ "**សាលាក្តីទូរនិម្មិត**" ។ (អនុម័តនៅថ្ងៃពុធ ទី២៣ ខែកុម្ភៈ ឆ្នាំ២០១១)

## III- បច្ចេកសព្ទស្នើដោយលោកជំទាវបណ្ឌិតសភាចារ្យ ខួត ធីតា

លោកជំទាវបណ្ឌិតសភាចារ្យ ខួត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បានស្នើមក គ.ជ.ភ.ខ. ឱ្យជួយបកប្រែជាផ្លូវការនូវពាក្យអង់គ្លេស conference hall ។ ក្រោយពីសមាជិក គ.ជ.ភ.ខ. ពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានអនុម័តទទួលយកសំណើរបស់លោកជំទាវ គឺ "**សាលសន្និសីទ**" ។ (អនុម័តនៅថ្ងៃពុធ ទី០២ មីនា ២០១១)

## IV- បច្ចេកសព្ទស្នើដោយឯកឧត្តម ង៉ែត ប៊ូរី

ឯកឧត្តម ង៉ែត ប៊ូរី នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានស្នើមក គ.ជ.ភ.ខ. តាមរយៈលោកជំទាវបណ្ឌិតសភាចារ្យ ខូត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ឱ្យជួយអនុម័តពាក្យមួយចំនួន។ គ.ជ.ភ.ខ.បានអនុម័តពាក្យទាំងនេះ នៅថ្ងៃពុធ ទី១៦និងថ្ងៃពុធទី២៣ ខែមីនា ឆ្នាំ ២០១១ ដូចតទៅ ៖

| | |
|---|---|
| **១- សាកលភាវូបនីយកម្ម**<br>អ. globalization<br>បារ. mondialisation (f), globalisation (f) | ការរីកចម្រើននៃទំនាក់ទំនងជាសាកលលើវិស័យ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និង នយោបាយ ដោយសារការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យា ទូរគមនាគមន៍ និង ការអនុវត្តនូវសេរីភាវូបនីយកម្មសេដ្ឋកិច្ចនិងពាណិជ្ជកម្ម។ ការណ៍នេះស្តែងឡើងតាមរយៈពាណិជ្ជកម្ម ការវិនិយោគបរទេស ការផ្ទេរបច្ចេកវិទ្យា លំហូរនៃមូលធននិងកម្លាំងពលកម្ម។<br>ឧ. ពិភពលោកបច្ចុប្បន្ននេះ បានឈានចូលទៅយុគសម័យនៃសាកលភាវូបនីយកម្ម។ |
| **២- តម្លាភាព**<br>អ. transparency<br>បារ. transparence (f) | - បរិយាកាសនៃការបើកទូលាយដល់ការចូលរួម ការតាមដាន ការពិនិត្យ និង ការផ្តល់យោបល់គ្រប់ជ្រុងជ្រោយក៏ដូចការប្រកួតប្រជែងដោយសមធម៌ ដោយលក្ខណៈស្មើភាពនិងយុត្តិធម៌។<br>- បរិយាកាសនៃការប្រកួតប្រជែងដែលមានលក្ខណៈស្មើភាពនិងយុត្តិធម៌ អនុញ្ញាតឱ្យតួអង្គទាំងអស់មានឱកាសដូចគ្នា ដើម្បីការចូលរួម ប្រសិនបើគេមានបំណងចូលរួម។<br>ឧ. តម្លាភាពនៃការអនុវត្តថវិកាឃុំ សង្កាត់ អនុញ្ញាតឱ្យប្រជាពលរដ្ឋអាចចូលរួម តាមដាន ត្រួតពិនិត្យអំពីដំណើរការគម្រោងអភិវឌ្ឍន៍នៅតាមមូលដ្ឋានរបស់ខ្លួន។ |
| **៣- ហិរញ្ញប្បទាន**<br>អ. financing<br>បារ. financement (m.) | - ការផ្តល់ហិរញ្ញវត្ថុ ការឱ្យខ្ចី ការផ្តល់ប្រាក់ ការផ្តល់ទុន ឬ ការផ្តល់ឱ្យនូវធនធាន សម្រាប់ទ្រទ្រង់ដំណើរការអនុវត្តគម្រោងធុរកិច្ចណាមួយ។ ដំណើរនៃការធ្វើហិរញ្ញប្បទាន គឺជាប់ពាក់ព័ន្ធទាំងអ្នកផ្តល់និងអ្នកទទួលឬអ្នកសុំខ្ចី។ ដូច្នេះ ក្នុងការអនុវត្តជាក់ស្តែង ពាក្យ «ហិរញ្ញប្បទាន» គឺសំដៅដល់ការផ្តល់និងការទទួលប្រាក់ឬមូលនិធិ សម្រាប់គាំទ្រដំណើរការគម្រោងធុរកិច្ចអ្វីមួយ។<br>- តាមទស្សនាទានទំនើប ពាក្យ «ហិរញ្ញប្បទាន» មានពីរប្រភេទគឺ ហិរញ្ញប្បទានទ្រព្យម្ចាស់និងហិរញ្ញប្បទានបំណុល (equity financing and debt financing)។ ហិរញ្ញប្បទានទ្រព្យម្ចាស់ គឺសំដៅដល់ការកៀរគរធនធាន ហិរញ្ញវត្ថុតាមរយៈការបោះផ្សាយនិងលក់នូវមូលបត្រទ្រព្យម្ចាស់ (equity securities) ដូចជា សន្លឹកហ៊ុន ជាដើម។ ចំណែកឯហិរញ្ញប្បទានបំណុល គឺសំដៅដល់ការកៀរគរធនធានហិរញ្ញវត្ថុ តាមរយៈការបោះពុម្ពផ្សាយនិងលក់នូវមូលបត្របំណុល (debt securities) ដូចជា សញ្ញាបណ្ណ និង បណ្ណបំណុលដទៃទៀតនៅក្នុងទីផ្សារហិរញ្ញវត្ថុឬផ្សារទុន។ |
| **៤- គណនេយ្យភាព**<br>អ. accountability<br>បារ. responsabilité (f.) | ភាពអាចទទួលខុសត្រូវបាន ភាពអាចគណនាបាន ឬ ភាពអាចពន្យល់បាន។ ក្នុងន័យទូលាយ «**គណនេយ្យភាព**» គឺជាទស្សនាទានមួយនៃក្រមសីលធម៌និងអភិបាលកិច្ច (ethic and governance) ដែលមានអត្ថន័យទូលំទូលាយ និង អាចត្រូវបានគេប្រើទាំងនៅក្នុងវិស័យសាធារណៈ វិស័យឯកជន និង សង្គមស៊ីវិល។ ក្នុងន័យនេះ «**គណនេយ្យភាព**» គឺសំដៅទៅលើការទទួលស្គាល់និងការទទួលខុសត្រូវចំពោះសកម្មភាព ការសម្រេចចិត្ត និងគោលនយោបាយ ដែលបានអនុវត្តនៅក្នុងតួនាទី ភារកិច្ច និង ដែនសមត្ថកិច្ចរបស់ខ្លួន។ |

| | |
|---|---|
| **៥- អតិរេក**<br>អ. surplus, excess<br>បារ. surplus (m.) | អ្វីដែលលើសពីការកំណត់ ភាពច្រើនក្រៃ ភាពពិសេស ចំនួនបន្ថែម...។<br>• ក្នុងន័យសេដ្ឋកិច្ច «**អតិរេក**» ប្រើសំដៅដល់ភាពលើសនៃចំនួន ។ ឧ. បន្ទាប់ពីបានដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរួចមក រាជរដ្ឋាភិបាលសម្រេចបានជាមូលដ្ឋាននូវ «**ភាពជឿទុកចិត្តនៃថវិកា**» តាមរយៈការបង្កើនចំណូល និងការធ្វើវិចារណកម្មចំណាយជាពិសេសបង្កើនបាននូវ **អតិរេក** នៃថវិកាជាតិដែលអនុញ្ញាតឱ្យបង្កើនទុនវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធ សង្គមសេដ្ឋកិច្ច ក្នុងគោលដៅពង្រឹងនិងពង្រីកសេវាសាធារណៈ និង កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ |
| **៦- កាលានុវត្តភាព**<br>អ. opportunity<br>បារ. opportunité (f.) | កាលៈទេសៈដ៏សមគួរឬដំណើរវិវឌ្ឍត្រូវពេលវេលា ឱកាសដែលអនុគ្រោះសម្រាប់ចាប់យកប្រយោជន៍អំពីកិច្ចការអ្វីមួយ ឬ គុណសម្បត្តិអ្វីមួយដែលកំពុងលេចឡើង ក៏ប៉ុន្តែការទាញយកប្រយោជន៍នោះ គឺអាចប្រឈមនឹងហានិភ័យ ហើយ ចាំបាច់ត្រូវប្ដេជ្ញាចិត្តយ៉ាងមុតមាំ និងមានធនធានគ្រប់គ្រាន់ ទើបគេអាចទាញយកប្រយោជន៍នោះបាន។ ឧទាហរណ៍ : វិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ២០០៨-២០០៩ ផ្ដល់**កាលានុវត្តភាព**ដល់កម្ពុជាសម្រាប់អភិវឌ្ឍវិស័យកសិកម្មដ៏មានសក្ដានុពលរបស់ខ្លួន។ ដើម្បីសម្រេចកិច្ចការនេះ កម្ពុជាត្រូវការទាំងធនធានមនុស្ស ទាំងធនធានហិរញ្ញវត្ថុយ៉ាងច្រើនសន្ធឹកសន្ធាប់ សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់របស់ខ្លួន។<br>• ក្នុងន័យសេដ្ឋកិច្ច ប្រើផ្សំនឹងថ្លៃដើម (opportunity cost) ពាក្យនេះមានន័យថា ជាថ្លៃដើម កាលានុវត្តភាព ដែលសំដៅដល់ថ្លៃដើមនៃជម្រើសល្អផ្សេងទៀត ដែលត្រូវបានបោះបង់ចោល។ ពាក្យនេះប្រើក្នុងគោលដៅធានាឱ្យបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានដែលមាន។<br>• កាលានុវត្តភាព ក្នុងកាលៈទេសៈខ្លះអាចត្រូវបានគេប្រើជាវេវចនសព្ទជាមួយនឹងពាក្យ «ឱកាស» ប៉ុន្តែជាទូទៅគេប្រើពាក្យ «ឱកាស» សម្រាប់បញ្ជាក់ពីពេលវេលា ឬ កាលៈទេសៈ ធម្មតាប៉ុណ្ណោះ។ ឧ. ថ្ងៃនេះ មេឃស្រឡះល្អ។ ដូច្នេះ វាជាឱកាសល្អសម្រាប់កសិករហាលស្រូវអង្ករបស់ខ្លួន។ |
| **៧- បរិការណ៍**<br>អ. context<br>បារ. contexte (m.) | ការណ៍ទាំងឡាយដែលកើតមុននិងក្រោយព្រឹត្តិការណ៍មួយ។ ពាក្យនេះប្រើខុសពីបរិបទដែលសំដៅដល់ខ្លឹមសារណាមួយដែលត្រូវលើកឡើងនូវពីមុខឬពីក្រោយសេចក្ដីមួយ។<br>• ក្នុងន័យសេដ្ឋកិច្ច «**បរិការណ៍**» ប្រើសំដៅបង្ហាញការណ៍ណាមួយ ដែលកើតឡើងនៅជុំវិញព្រឹត្តិការណ៍មួយ។<br>ឧ. ក្នុងស្មារតីនេះ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤ នៃរដ្ឋសភាត្រូវបានរៀបចំឡើងនៅលើមូលដ្ឋានសំខាន់ៗ ដូចតទៅ ៖ ការវាយតម្លៃដកពិសោធន៍លើការអនុវត្តនៅក្នុងនីតិកាលទី៣កន្លងមក និង ការវាយតម្លៃលើ **បរិការណ៍** និង បញ្ហាប្រឈមទាំងឡាយ ទាំងក្នុងកម្រិតជាតិ ទាំងក្នុងកម្រិតអន្តរជាតិ ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងរយៈពេលមធ្យម (ខាងមុខ)។<br>• ដោយឡែក «**បរិបទ**» ប្រើយោងទៅតាមសេចក្ដីណាមួយ។ |

| | |
|---|---|
| | ឧ. តាមរយៈរបៀបវារៈនៃអង្គសន្និសីទ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលនឹងធ្វើបទបង្ហាញអំពី**បរិបទ** និង ស្ថានភាពវិស័យរ៉ែនៅកម្ពុជា ជូនអង្គសន្និសីទទាំងមូលឱ្យកាន់តែជ្រាបច្បាស់ថែមទៀត អំពីច្បាប់ លិខិតបទដ្ឋាន និង ស្ថានភាព នៃការគ្រប់គ្រងនិងការអភិវឌ្ឍរ៉ែនៅកម្ពុជា។ |
| **៨- សង្គតិភាព**<br>អ. consistency<br>បារ. consistance (f.) | ការរាប់អានគ្នា ការរួបរួមគំនិតគ្នា ការជួបប្រសព្វគ្នា សេចក្តីស្មោះស្មើទៅវិញទៅមករកគ្នា។<br>• ក្នុងន័យសេដ្ឋកិច្ច ពាក្យនេះប្រើសំដៅដល់ភាពចុះសម្រុងគ្នារវាងវិធីភាពផ្សេងគ្នា។<br>ឧ. រាជរដ្ឋាភិបាលទទួលស្គាល់នូវភាពចាំបាច់នៃការធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារ និង លំដាប់លំដោយនៃការអនុវត្តរវាង «**យុទ្ធសាស្ត្រចតុកោណ**» ជាមួយនឹង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**» ក៏ដូចជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ** ព្រមទាំងជាមួយនឹងឯកសារដែលមានលក្ខណៈជាផែនការគោល-នយោបាយកម្មវិធីវិនិយោគនិងថវិកាជាតិ។ |
| **៩- វិត្ថារកម្ម**<br>អ. expansion<br>បារ. expansion (f.)<br>augumentation (f.) | ការបង្កើន ការបន្ថែម ការពង្រីកទំហំ ចំនួន ឬ បរិមាណចំណាយ។<br>• ក្នុងវិស័យសេដ្ឋកិច្ច «**វិត្ថារកម្ម**» មានន័យថា ការបង្កើនឬការកើនឡើងនៃកម្រិតចំណាយ ដើម្បីបង្កើនសកម្មភាពសេដ្ឋកិច្ច និង ទំនិញ និង សេវាកម្មនៅក្នុងទីផ្សារ។ ជាទូទៅ ***វិត្ថារកម្មសេដ្ឋកិច្ច*** *(economic expansion)* កើតឡើងនៅខណៈពេលដែលមានការប្រែប្រួលនូវចង្វាក់ផលិតកម្មនិងការប្រើប្រាស់ធនធានសម្រាប់ជំរុញឱ្យសេដ្ឋកិច្ចងើបឡើងវិញ និង មានការរីកចម្រើន។ វិត្ថារកម្មសេដ្ឋកិច្ចអាចកើតឡើង ដោយសារកត្តាខាងក្នុង ដូចជា គោលនយោបាយសារពើពន្ធ គោលនយោបាយរូបិយវត្ថុ។ល។ និង កត្តាខាងក្រៅដូចជា ការប្រែ ប្រួលអាកាសធាតុ បច្ចេកវិទ្យា ។ល។<br>ឧ. កម្ពុជាធ្វើវិត្ថារកម្មសេដ្ឋកិច្ចរបស់ខ្លួន ដោយបង្កើនចំណាយថវិកាជាតិទៅលើវិស័យកសិកម្ម និង ធារាសាស្ត្រ សម្រាប់ពង្រីកផលិតផលកសិកម្ម និង មូលដ្ឋានកំណើន សេដ្ឋកិច្ច។ |

## V- បច្ចេកសព្ទស្នើដោយឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ

ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ អនុប្រធានគណៈកម្មការភាសាវិទ្យាខ្មែរអមទីស្តីការគណៈរដ្ឋមន្ត្រី បានស្នើមក គ.ជ.ភ.ខ. ឱ្យជួយអនុម័តពាក្យមួយចំនួន។ គ.ជ.ភ.ខ.បានអនុម័តពាក្យទាំងនោះ នៅថ្ងៃពុធ ទី០២ ខែមីនា, ថ្ងៃពុធ ទី០៩ ខែមីនា និង ថ្ងៃពុធ ទី០៣ ខែសីហា ឆ្នាំ២០១១ ដូចតទៅ :

| | |
|---|---|
| **១- ចក្ខុវិស័យ**<br>អ. vision | ការគិតទុកឬការប្រមើលមើលទៅមុខនូវផែនការឬអ្វីៗដែលកើតមានឡើងនៅថ្ងៃអនាគត។ (អនុម័តយកនិយមន័យរបស់ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ)។ |
| **២- គោលនយោបាយ**<br>អ. policy | ដំណើរឬគោលការណ៍នៃសកម្មភាពដែលបានអនុម័តឬស្នើឡើងដោយរដ្ឋាភិបាល ស្ថាប័ន គណបក្ស ក្រុមហ៊ុន ឬ បុគ្គល។ (អនុម័តយកនិយមន័យរបស់ឯកឧត្តម ច័ន្ទ សំណព្វ)។ |

| | |
|---|---|
| ៣- **គោលបំណង**<br>អ. goal<br>បារ. but (m.) | អ្វីៗដែលយើងសង្ឃឹមថាសម្រេចបាន។<br>(អនុម័តយកនិយមន័យរបស់ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ)។ |
| ៤- **គោលដៅ**<br>អ. target/objective<br>បារ. objectif (m.) | អ្វីៗដែលយើងសាកល្បងធ្វើឱ្យសម្រេច។<br>(អនុម័តយកនិយមន័យរបស់ឯកឧត្តម ច័ន្ទ សំណព្វ)។ |
| ៥- **យុទ្ធសាស្ត្រ**<br>អ. strategies<br>បារ. stratégies (f.) | សិល្បៈនៃការរៀបចំឬការដឹកនាំ ដើម្បីសម្រេចកិច្ចការឱ្យស្របតាមគោលបំណងនិងគោលដៅដែលបានកំណត់។<br>(អនុម័តយកនិយមន័យរបស់ឯកឧត្តម ច័ន្ទ សំណព្វ)។ |
| ៦- **ផែនការយុទ្ធសាស្ត្រ**<br>អ. strategies plan<br>បារ. plan de stratégies | ផែនការសកម្មភាពដើម្បីសម្រេចយុទ្ធសាស្ត្រដែលបានកំណត់។ (និយមន័យសំយោគចេញពីការស្នើរបស់សមាជិកមួយចំនួន)។ |
| **សំណើ** | **សេចក្តីសម្រេចរបស់ គ.ជ.ភ.ខ.** |
| ៧-បមាណីយ ឬ ស្តង់ដា ឬ ស្តង់ដារ ?<br>អ. standard<br>បារ. standard (m.) | គ.ជ.ភ.ខ.បានអនុម័តយកពាក្យ "**បមាណីយ**" និង "**ស្តង់ដា**"។ ពាក្យ "ស្តង់ដា" ជាពាក្យខ្ចីពីពាក្យបារាំង standard។ បើយើងចង់រក្សាជាតិសព្ទ យើងត្រូវសរសេរ "ស្តង់ដារដ៏" ហើយសំណេរ "ស្តង់ដារ" ជាសំណេរមិនស្របនឹងពាក្យដើមទេ ដូច្នេះ គ.ជ.ភ.ខ.យល់ឃើញថាគប្បីសរសេរ "ស្តង់ដា" តាមអំណាននិវិញ គឺមិនមែនតាមជាតិសព្ទទេ។ |
| ៨-មគ្គុទ្ទេសក៍ទេសចរណ៍ ឬ មគ្គុទ្ទេសក៍ទេសចរ (អ្នកនាំភ្ញៀវ)? | គ.ជ.ភ.ខ.បានអនុម័តយកពាក្យ "**មគ្គុទ្ទេសក៍ទេសចរ**" ពីព្រោះពាក្យ "ទេសចរណ៍" ជាសមមូលនឹងពាក្យបារាំង tourisme។ រីឯពាក្យ "ទេសចរ" ជាសមមូលនឹងពាក្យ touriste គឺជាភ្ញៀវ ដូច្នេះ "មគ្គុទ្ទេសក៍ទេសចរ" គឺជាអ្នកនាំភ្ញៀវ "ទេសចរ" ដើរកម្សាន្ត។ |
| ៩-នគរបាលទេសចរណ៍ /នគរបាលទេសចរ<br>(នគរបាលដែលទទួលបន្ទុកវិស័យទេសចរណ៍ ឬ នគរបាលការពារភ្ញៀវទេសចរ) | គ.ជ.ភ.ខ.បានអនុម័តយកពាក្យ "**នគរបាលទេសចរណ៍**" ផង និង "**នគរបាលទេសចរ**" ផង ពីព្រោះក្រសួងមហាផ្ទៃបានបង្កើត "នគរបាលទេសចរណ៍" សម្រាប់វិស័យ "ទេសចរណ៍"។ រីឯ "នគរបាលទេសចរ" គឺនគរបាលដែលមានភារកិច្ចជួយថែរក្សាសុវត្ថិភាពរបស់ទេសចរ។ |
| ១០-ក្បេត្រវិទ្យ ឬ ក្បេត្រវិទ? | គ.ជ.ភ.ខ.បានអនុម័តយកពាក្យ "**ក្បេត្រវិទ**" ពីព្រោះ "ក្បេត្រវិទ" ជាមនុស្សដូច "ក្បេត្រវិទូ" ដែរ។ រីឯ "ក្បេត្រវិទ្យ" មានជាប់ជាតិសព្ទជាមួយ "ក្បេត្រវិទ្យា" ទៅវិញទេ។ |

| | |
|---|---|
| ១១-ក្របខណ្ឌ ឬ ក្របខ័ណ្ឌ? | គ.ជ.ភ.ខ.បានអនុម័តយកពាក្យ "**ក្របខណ្ឌ**" ពីព្រោះពាក្យដែលមានតួប្រកបជាមួយនឹងព្យញ្ជនៈដែលមានជើងអក្សរនៅខាងក្រោមស្ទើរតែទាំងអស់ ត្រូវបានវចនានុក្រមរបស់សម្តេចសង្ឃរាជ ជួន ណាត អនុញ្ញាតឱ្យសរសេរដោយប្រើសំយោគសញ្ញាក៏បាន ឬ មិនចាំបាច់ប្រើសំយោគសញ្ញាឡើយ ហើយ ផ្ទុយទៅវិញ ពាក្យមួយចំនួនតូចត្រូវមានសំយោគសញ្ញា ដូចពាក្យ "ទូរស័ព្ទ" , "ក្របខ័ណ្ឌ" , ... ម្យ៉ាងទៀត ក្រៅពីពាក្យ "ក្របខ័ណ្ឌ" ធាតុ "ខណ្ឌ" នៅក្នុងកន្សោមពាក្យឯទៀត សុទ្ធតែអាចមានឬគ្មានសំយោគសញ្ញា ៖ ការប្រើសំយោគសញ្ញាក្នុងវចនានុក្រមខ្មែរឥតមានក្បួនជាក់លាក់ទេ  អាស្រ័យហេតុនេះ ដើម្បីឱ្យមានការងាយស្រួលក្នុងការសរសេរ សមាជិកគ.ជ.ភ.ខ.បានសម្រេចជាឯកច្ឆន្ទឱ្យឈប់ប្រើសំយោគសញ្ញាជាទូទៅចំពោះពាក្យដែលមានតួប្រកបដែលមានជើងអក្សរនៅខាងក្រោម ឧ. **ថ្ងៃចន្ទ , ទូរសព្ទ , ខណ្ឌ** (សង្កាត់), **ក្របខណ្ឌ , លក្ខខណ្ឌ , ខណ្ឌស្ការ , ខណ្ឌសញ្ញា** , ...។ |
| ១២- ទូរស័ព្ទ ឬ ទូរសព្ទ | គ.ជ.ភ.ខ.បានអនុម័តយកអក្ខរាវិរុទ្ធ "**ទូរសព្ទ**" ដូចមានការពន្យល់ខាងលើស្រាប់ ។ |
| ១៣- មន្ទីរពិសោធ , ស្ថានីយពិសោធ , វាលពិសោធ ឬ មន្ទីរពិសោធន៍ , ស្ថានីយពិសោធន៍ , វាលពិសោធន៍ | គ.ជ.ភ.ខ.បានអនុម័តយកអក្ខរាវិរុទ្ធ "**មន្ទីរពិសោធន៍**" , "**ស្ថានីយពិសោធន៍**" , "**វាលពិសោធន៍**" ពីព្រោះខ្លួនបានអនុម័តយកពាក្យ "កែវពិសោធន៍" និង "មន្ទីរពិសោធន៍" ដែលមាន "ន៍" នៅខាងចុងរួចមកហើយ ហើយ គប្បីសរសេរដោយមាន "ន៍" ដូចមុនៗដែរ ដើម្បីឱ្យមាននិរន្តរភាព។ ម្យ៉ាងទៀត ក្នុងភាសាខ្មែរ ពាក្យផ្សំអាចផ្សំជាមួយកិរិយាសព្ទ ដូច *បន្ទប់ដេក* , *សៀវភៅសរសេរ* ឬ ផ្សំជាមួយនាមសព្ទ ដូច *បន្ទប់ទឹក* , *ផ្ទះបាយ* , ... ដូច្នេះ យើងគ្មានហេតុផលអ្វីដើម្បីធ្វើ "ពិសោធន៍" នាមសព្ទឱ្យទៅជាកិរិយាសព្ទ "ពិសោធ" មុននឹងយកទៅផ្សំនោះឡើយ ។ ម្យ៉ាងទៀត ក្រសួងជាច្រើន សុទ្ធតែបានសរសេរ "មន្ទីរពិសោធន៍" ដោយមាន "ន៍" ជាទូទៅរួចទៅហើយ ។ |

# លិខិតឆ្លើយឆ្លងមួយចំនួន
# រវាង គ.ជ.ភ.ខ.  និង សាធារណជន

គោរពជូន

លោក ហ៊ី ម៉ារិត មន្ត្រីការិយាល័យសរុប និង ព័ត៌មាន

នៃទីចាត់ការរដ្ឋបាល សាលាខេត្តបន្ទាយមានជ័យ

ដោយបានសួរពីរសំណួរមកខ្ញុំ ខ្ញុំមានសេចក្ដីរីករាយឆ្លើយ ជូនទៅ :

១- ចំពោះសំណួរទាក់ទងនឹង "ឃាតកៈ" ឬ "ឃាតករ" សូមលោកអានកំណត់ហេតុនៃសម័យប្រជុំ កាលពីថ្ងៃពុធ ទី០៥ ខែឧសភា ឆ្នាំ២០១០ នៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) តាមការគួរ។ ខ្ញុំគ្រាន់តែសុំបន្ថែមថា ពាក្យ "ឃាតកៈ" អានថា [ឃា-តៈ-កៈ] ដែលមានក្នុងវចនានុក្រមរៀបរៀងក្រោមការដឹកនាំរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត នោះ ជាពាក្យបាលីបរិសុទ្ធ ប៉ុន្តែ ខ្មែរយើងមិនដែលប្រើពាក្យនេះទេ។ រីឯពាក្យ "ឃាតករ" អានថា [ឃា-ត-ក] វិញ ជាពាក្យដែលខ្មែរបានប្រើជាយូរលង់មកហើយ ដោយគ្រាន់តែខ្ចីធាតុបាលីមកបង្កើតពាក្យខ្មែរ ដែលគេហៅជាប្រព័ន្ធ ដូច "កសិករ" , "ពលករ" , "កម្មករ" ។ល។ ម្យ៉ាងទៀត សូមលោកជ្រាបថា "ឃាតករ" មានន័យដូច "ឃាតកៈ" របស់សម្ដេច ជួន ណាត ដូច្នេះដែរ។

២- ចំពោះពាក្យ "សិល្បករ" និង "សិល្បការិនី" ជាពាក្យដែលភាសាខ្មែរបានបង្កើតជាប្រព័ន្ធ ដូច "កម្មករ / កម្មការិនី" , "ពិធីករ/ពិធីការិនី" ។ល។ ពាក្យដែលបានស្រង់ជូនខាងលើនេះ ជាពាក្យគូនឹងគ្នា មួយសម្រាប់បុរស មួយសម្រាប់ស្ត្រី។ នេះជាលក្ខណៈពិសេសនៃភាសាខ្មែរបច្ចុប្បន្ន។ បើលោករកពាក្យណាមួយ ហើយ មិនឃើញមានក្នុងវចនានុក្រមសម្ដេច ជួន ណាត នោះ សូមលោកកុំប្រកាន់ ពីព្រោះភាសាណាក៏ដោយតែងតែមានពាក្យថ្មីដែលគ្មានក្នុងវចនានុក្រមចាស់ដែរ។ ប៉ុន្តែ ក្នុងវចនានុក្រមនៃបរទេសគេ តែងតែធ្វើបច្ចុប្បន្នភាព (update) រាល់ប្រាំឆ្នាំម្ដង ហើយ សូមជ្រាបថា វចនានុក្រមខ្មែរឥតបានធ្វើបច្ចុប្បន្នភាពអស់៥០ឆ្នាំមកហើយ។ ចំពោះកង្វះពាក្យ "សិល្បការិនី" ក្នុងវចនានុក្រមអក្សរាវិរុទ្ធរបស់វិទ្យាស្ថានភាសាជាតិ គឺជាការភ្លាំងភ្លាត់ពីសំណាក់អ្នកធ្វើ។

សូមលោកទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

ភ្នំពេញ , ថ្ងៃព្រហស្បតិ៍ ទី០៦ ខែមករា ឆ្នាំ២០១១

ជ.ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ

អនុប្រធានអចិន្ត្រៃយ៍

បណ្ឌិតសភាចារ្យ ហ្លី ចំង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


ទីស្ដីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិភាសាខ្មែរ
លេខាធិការដ្ឋានអចិន្ត្រៃយ៍ : វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា

Comité National de la Langue Khmère
Secrétariat permanent : Institut de la Langue Nationale de l'Académie Royale du Cambodge

ទូរស័ព្ទ : ០៩២ ៨៨ ១៣ ៤០ , ០១១ ៨៤ ៣៩ ៦១ , ទូរសារ : ០២៣ ៨០ ៣៣ ៣៦ , E-mail: nckl_secretariat@yahoo.com


លេខ : ០០១/១១ គជភខ/លខ

ភ្នំពេញ, ថ្ងៃច័ន្ទ ទី១០ ខែមករា ឆ្នាំ២០១១

**សូមគោរពជូន**

**លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា**
**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**កម្មវត្ថុ** : ចម្លើយទៅនឹងសំណួររបស់លោកជំទាវទាក់ទងនឹងពាក្យ៤ម៉ាត់

**យោង** : លិខិតរបស់លោកជំទាវ ចុះថ្ងៃច័ន្ទ ទី២០ ខែធ្នូ ឆ្នាំ២០១០

ខ្ញុំសូមជម្រាបលោកជំទាវថា លោក ជូរ គារី បានប្រគល់សំណួររបស់លោកជំទាវឱ្យខ្ញុំជាងមួយសប្ដាហ៍មកហើយ ប៉ុន្តែ ខ្ញុំមិនទាន់បានឆ្លើយ ដោយមានរវល់ច្រើន សូមលោកជំទាវអភ័យទោស ។

ចំពោះពាក្យទាំង ៤ ម៉ាត់ ខ្ញុំសុំជម្រាបលោកជំទាវ ដូចតទៅ :

១- ពាក្យ "សម្លឹងយល់" ជាពាក្យមួយ "ម៉ូល" ដែលគេប្រើតែជាមួយគ្នា ក្នុងន័យថា "រំពឹងគិតយល់ដោយប្រាជ្ញាដ៏ក្លៀវក្លា" (តាមវចនានុក្រមសម្ដេច ជួន ណាត) ។ ពាក្យនេះ គេប្រើតែសម្រាប់ព្រះមហាក្សត្រ ។

២- កន្សោមពាក្យ "ស្ទែងយល់" ជាកន្សោមពីរពាក្យដែលមាន "ស្ទែង" និង "យល់" នៅបន្ទាប់ពីគ្នា ។ "ស្ទែង" មានន័យថា "សង្កេតរក; ខំប្រឹងរកឱ្យបានដូចបំណង" ។ ដូច្នេះ "ស្ទែងយល់" គឺ ខំ ខិត ខំប្រឹងប្រែងឱ្យយល់អំពីអ្វីមួយ ។

៣- ពាក្យ "ផ្ទុះ" លោកជំទាវប្រាកដជាស្គាល់ន័យរបស់វាហើយ ហើយ ខ្ញុំជឿជាក់ថា លោកជំទាវ ឆ្ងល់អំពីពាក្យ "បន្ទុះ" ទៅវិញទេ ។

៤- ពាក្យ "បន្ទុះ" ឥតមានក្នុងវចនានុក្រមទេ (ដូចពាក្យ "បន្ទោក" ដែរ) ប៉ុន្តែ ជាពាក្យដែលគេអាចបង្កើតបានដោយយកគំរូតាមការបង្កើតពាក្យដែលមានស្រាប់ គឺ "ភ្លឺ > ពន្លឺ", "ផ្ទុក > បន្ទុក" ។ ដូច្នេះ គេអាចបង្កើតពាក្យដែលមិនទាន់មាន ដូចតទៅ : "ផ្ទុះ > បន្ទុះ", "ផ្ទោក > បន្ទោក" ។ល។

ខ្ញុំសូមបញ្ជាក់ជូនលោកជំទាវផងដែរថា ភាសាវិទ្យាបានវិភាគភាសាជាពីរស្រទាប់ធំៗ (ដែលស្រទាប់នីមួយៗត្រូវចែកជាពីរស្រទាប់តទៅទៀត) ប៉ុន្តែ ខ្ញុំសុំនិយាយតែត្រឹមស្រទាប់ធំទាំងពីរនុះ គឺ ១. ស្រទាប់ "វេយ្យាករណ៍" (ស្រទាប់ចលករ ឬ យន្តការ ឬ រោងចក្រ សម្រាប់ផលិតពាក្យ); ២. ស្រទាប់ "ទម្លាប់វាចា" គឺ "ឃ្លាំងសម្រាប់ដាក់អ្វីៗ" ដែលរោងចក្រផលិតបាន។ "ទម្លាប់" គឺមកពី "ធ្លាប់" : បើគេត្រូវការពាក្យណា គេបង្កើតពាក្យនោះ។ ចំពោះពាក្យណាដែលគេមិនទាន់ត្រូវការ គេក៏មិនទាន់បង្កើតវាដែរ ហើយ គេក៏មិនធ្លាប់ប្រើវាដែរ។ ទម្លាប់គ្រាន់តែជាអ្វីៗដែលគេធ្លាប់ប្រើ ធ្លាប់ឃើញ ប៉ុន្តែ "រោងចក្រវេយ្យាករណ៍" មានសក្តានុពលអាចឱ្យគេផលិតបានអ្វីៗថ្មីទៀតរាប់មិនអស់ ឥតគណនា (តាម Grammaire Générative et Transformationnelle របស់ភាសាវិទូដ៏ល្បីម្នាក់ ឈ្មោះ Noam Chomsky)។

ចំពោះការប្រើប្រាស់វិញ បើយើងដឹងថាពាក្យមួយជាកិរិយាសព្ទឬជាគុណនាម (កិរិយាសព្ទនិងគុណនាមអាចមានពាក្យក្លាយរបៀបគ្នា, ដូច "ផ្ទុះ (កិរិយាសព្ទ) > បន្ទុះ (នាមសព្ទ)", "ក្រី (គុណនាម) > កន្រី (នាមសព្ទ)") និង ពាក្យមួយទៀតជានាមសព្ទ យើងអាចប្រើវាតាមសេចក្តីត្រូវការក្នុងការបង្កើតល្បះ (ឧ. កុំដាក់ផាវជិតភ្លើងពេក ប្រយ័ត្នវាផ្ទុះ ហើយ បន្ទុះវាអាចធ្វើឱ្យឈើក្រជាសត្រសៀក។)។

សូមលោកជំទាវ មេត្តាទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

ជ.ប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ
អនុប្រធានអចិន្ត្រៃយ៍

បណ្ឌិតសភាចារ្យ ពុំ ទិត

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

លេខ: ៤១៥/១១ របសក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យ ហ្រុំ ម៉ល់**
**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**កម្មវត្ថុ៖** សំណើសុំបកស្រាយពាក្យ បណ្ឌិតសភាចារ្យ និងបកប្រែជាភាសាបារាំងនិងអង់គ្លេស។

ឯកឧត្តមបណ្ឌិតសភាចារ្យជាទីគោរពរាប់អាន!

ដោយមានសំណូមពរពីសាធារណៈជនចង់ស្វែងយល់អំពីខ្លឹមសារពាក្យ បណ្ឌិតសភាចារ្យ និងការបកប្រែជាភាសាបារាំងនិងអង់គ្លេសនោះ ខ្ញុំសូមស្នើសុំឯកឧត្តមបណ្ឌិតសភាចារ្យមេត្តាចេញលិខិតពន្យល់និងបកប្រែជាផ្លូវការដោយក្តីអនុគ្រោះ។

សូម ឯកឧត្តមបណ្ឌិតសភាចារ្យ មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិតសភាចារ្យ ឃ្លោត ធីតា**

អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180 Website: www.rac-academy.edu.kh E-mail: [illegible] P.O Box 531 Phnom Penh, Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាជាតិភាសាខ្មែរ

National Council of Khmer Language
Conseil National de la Langue Khmère

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ទូរស័ព្ទ : ០៨៩ ០៩ ៧៣ ៤៣, ០១២ ២៩ ២៩ ៨៣
ទូរសារ : ០២៣ ៨៨០ ០១៩, E-mail: nckl.nckl@yahoo.com គេហទំព័រ : www.pressocm.gov.kh, www.kiriveng.com


លេខ : ០៨៩/១១.គជភខ/រ

រាជធានីភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ទី០៨ ខែកញ្ញា ឆ្នាំ២០១១

ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)

សូមគោរពជូន

លោកជំទាវបណ្ឌិត្យសភាចារ្យ ខ្លូត ធីតា
ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

**កម្មវត្ថុ** : ការបកស្រាយពាក្យ **បណ្ឌិត្យសភាចារ្យ** និង បកប្រែទៅជាភាសាបារាំងនិងអង់គ្លេស

**យោង** : - លិខិតលេខ ៨១៧/១១ របសក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១ របស់លោកជំទាវបណ្ឌិត្យសភាចារ្យ ស្តីពីសំណើសុំបកស្រាយពាក្យ **បណ្ឌិត្យសភាចារ្យ** និង បកប្រែជាភាសាបារាំងនិងអង់គ្លេស

- លិខិតក្រុមលេខ០១២/១១.គជភខ/រ ចុះថ្ងៃព្រហស្បតិ៍ ទី០៣ ខែមករា ឆ្នាំ២០១១ ស្តីពីបកប្រែពាក្យ **បណ្ឌិត្យសភាចារ្យ** ទៅជាភាសាបារាំងនិងអង់គ្លេស

ចំពោះការបកស្រាយពាក្យ **បណ្ឌិត្យសភាចារ្យ** ខ្ញុំសូមជម្រាបលោកជំទាវបណ្ឌិត្យសភាចារ្យថា ពាក្យនេះកើតឡើងពីការផ្សំពាក្យ **បណ្ឌិត្យសភា** ជាមួយនឹងពាក្យ **អាចារ្យ** គឺ **បណ្ឌិត្យសភា + អាចារ្យ > បណ្ឌិត្យសភាអាចារ្យ > បណ្ឌិត្យសភាចារ្យ** ពីព្រោះស្រៈ [អា] របស់ពាក្យ "សភា" និង ស្រៈ [អា] របស់ពាក្យ "អាចារ្យ" ត្រូវបានរលាយចូលគ្នា (បណ្ឌិត្យសភាអាចារ្យ > បណ្ឌិត្យសភាចារ្យ[*] ជាដើម) ។ ពាក្យ **បណ្ឌិត្យសភាចារ្យ** នេះ ជាពាក្យនៅក្នុងក្រុម **គ្រឹស្តាចារ្យ សាស្ត្រាចារ្យ ឧទ្ទេសាចារ្យ យោធាចារ្យ**, ... ។

សូមលោកជំទាវបណ្ឌិត្យសភាចារ្យមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ ។

ឯកសារភ្ជាប់ជាមួយ : លិខិតក្រុមលេខ០១២/១១.គជភខ/រ ចុះថ្ងៃព្រហស្បតិ៍ ទី០៣ ខែមករា ឆ្នាំ២០១១ ហៅតាមក្រោយ។

ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

បណ្ឌិត្យសភាចារ្យ ជុំ ម៉ៅ

[*] ពាក្យ "បណ្ឌិត្យសភាចារ្យ" សរសេរដោយ "ៀ" ត្រូវបានប្រើ [illegible] "បណ្ឌិត្យសភាកម្ពុជា" សរសេរដោយ "ៀ" [illegible] "បណ្ឌិត្យសភាកម្ពុជា" សរសេរដោយ "ៀ" ដូច្នេះ "បណ្ឌិត្យសភាចារ្យ" ក៏ត្រូវសរសេរដោយ "ៀ" ដែរ ពីព្រោះ "បណ្ឌិត្យសភាចារ្យ" កើតពី "បណ្ឌិត្យសភា + អាចារ្យ" ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិភាសាខ្មែរ

National Commission of Khmer Language
Comité National de la Langue Khmère

ទូរស័ព្ទ : ០៨៦ ៨៤ ២៣ ០៣ , ០១៦ ៥១ ៧៤ ២១ , ទូរសារ : ០៨៦ ៨៨ ០០ ១៨ · E-mail:cnkl_secretariat@yahoo.com

លេខ : ០១២ /១១.គជភខ/វ

## សូមគោរពជូន

លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ថិតា
ប្រធានរាជបណ្ឌិត្យសភាកម្ពុជា

**កម្មវត្ថុ** : ការប្រែពាក្យ "បណ្ឌិតសភាចារ្យ" ទៅជាពាក្យបារាំង និង ទៅជាពាក្យអង់គ្លេស

**យោង** : ការស្នើរបស់លោកជំទាវ កាលពីថ្ងៃសុក្រ ទី២៨ ខែមករា ឆ្នាំ២០១១

ខ្ញុំមានកិត្តិយសជម្រាបលោកជំទាវថា ការបកប្រែពាក្យ "បណ្ឌិតសភាចារ្យ" ទៅជាពាក្យបារាំងជាការងាយ គឺ "académicien" ពីព្រោះពាក្យ "académicien" នេះ ត្រូវបានគេប្រើជាយូរមកហើយ ហើយ អ្នកណាក៏ធ្លាប់ស្គាល់ដែរ ។ រីឯការបកប្រែទៅជាពាក្យអង់គ្លេសវិញ ការសម្រេចចិត្តមានការលំបាកបន្តិច ពីព្រោះអ្នកខ្លះយល់ឃើញថា គ្មានអង់គ្លេសមានពាក្យ "academician" ទេ ហើយ គប្បីប្រែថា "academy member" វិញ ប៉ុន្តែ :

១- ពាក្យ "academician" មាននៅក្នុងវចនានុក្រម Collins Cobuild Advanced Learner's English Dictionary, Great Britain, 2006 ។ នេះជាសេចក្តីពន្យល់ : " academician /əkædəmɪʃᵊn, AM ækədə-/ (academicians) An academician is a member of an academy, usually one which has been formed to improve or maintain standards in a particular field".

២- វចនានុក្រម Dictionnaire classique Anglais-Français & Français - Anglais par Charles PETIT & William SAVAGE, Hachette, Paris 1950 បានប្រែនិងពន្យល់ពាក្យ "academician" ដូចតទៅ : "academician [ə kædə'mɪʃən] n. académicien m. : Royal Academican (R.A.), membre m. de la Royal Academy."

**សេចក្តីសង្កេត** : - ពាក្យ "academician" មាននៅក្នុងវចនានុក្រម Collins Cobuild និងក្នុងវចនានុក្រមពីរភាសាធ្វើដោយអ្នកជំនាញខាងភាសាអង់គ្លេសនិងភាសាបារាំង :
(១) - វចនានុក្រមទី១ប្រាប់ឱ្យដឹងថា នៅប្រទេសអង់គ្លេស មានការប្រើពាក្យ "academician" ;
(២) - តាមរយៈវចនានុក្រមទី២ យើងបានឃើញពាក្យ "Royal Academician" (ពាក្យ " Royal " សំដៅទៅប្រទេសអង់គ្លេសដែលមានស្តេច) ។

**សេចក្តីសន្និដ្ឋាន** : ពាក្យ "បណ្ឌិតសភាចារ្យ" ជាពាក្យត្រូវនឹងពាក្យបារាំងថា "académicien" និង ពាក្យអង់គ្លេសថា "academician"

**បញ្ជាក់** : បើមានឈ្មោះស្ថាប័នជាប់ជាមួយ គេមិនប្រើពាក្យ "académicien" ទេ, ឧ. " Membre de l'Académie Française" ។

សូមលោកជំទាវបណ្ឌិតសភាចារ្យ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ទី០៣ ខែមករា ឆ្នាំ២០១១
ជ.ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ
អនុប្រធានអចិន្ត្រៃយ៍

បណ្ឌិតសភាចារ្យ ពុំ ចំរើន

ពី : ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) (nckl.nck@yahoo.com)

ជូន : លោក ខេង ទីតូ (tito.kheng@gmail.com)

## <u>ជម្រាបមក</u>

**លោក ខេង ទីតូ**

(មន្ត្រីកងរាជអាវុធហត្ថលើផ្ទៃប្រទេស)

ខ្ញុំមានសេចក្ដីរីករាយឆ្លើយតបមកលោកទាក់ទងនឹងពាក្យ *កងរាជអាវុធហត្ថ* ដូចតទៅ :

- កង (ន.) ពួក , ក្រុម : កងទ័ព , កងសេនាជន , កងចល័ត ,...។
- រាជ (ន.) ព្រះរាជា , ស្ដេច ។ ពាក្យនេះអាចប្រើភ្ជាប់ខាងដើមពាក្យដទៃ ដើម្បីបញ្ជាក់ន័យថា ជារបស់ព្រះរាជា ឬ ស្ថិតក្រោមការគ្រប់គ្រងដឹកនាំរបស់ព្រះរាជា : រាជទូត , រាជធានី , រាជវាំង , ...។
- អាវុធ (ន.) គ្រឿងប្រហារឬគ្រឿងចម្បាំងផ្សេងៗ ដូចជា ធ្នូ , ស្នា , កាំភ្លើង , ...។
- ហត្ថ (ន.) ដៃ , ...។
- អាវុធហត្ថ : អ្នកកាន់អាវុធ , ទាហានដែលមានអាវុធក្នុងដៃ ។

ដូច្នេះ *កងរាជអាវុធហត្ថ* គឺ ក្រុមទាហានដែលមានអាវុធក្នុងដៃ នៃប្រទេសដែលមានព្រះរាជាសោយរាជ្យ សំដៅដល់ កងទាហានដែលប្រដាប់ដោយអាវុធ ជាអ្នកដើរត្រួតត្រា ការពារ និង រក្សាសេចក្ដីសុខសាន្ត ក្នុងប្រទេសដែលមានព្រះរាជាសោយរាជ្យ ។

ពាក្យនេះប្រើសងពាក្យបារាំងថា Gendarme (m.) ។

សូមលោកជួបប្រទះតែនឹងសេចក្ដីសុខចម្រើន និង ជោគជ័យគ្រប់ភារកិច្ច ។

ភ្នំពេញ , ថ្ងៃពុធ ទី១២ ខែតុលា ឆ្នាំ២០១១

ត.ប.ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

មន្ត្រីនៃផ្នែកបោះពុម្ព ផ្សព្វផ្សាយ និង បណ្ដុះបណ្ដាល

សេ អឿន , ប៊ី សុខគង់